ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៧ - ២០២៩

*"ដើម្បីការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី រក្សាលំនឹងជីវភាពប្រជាជន និងជំរុញសម្ទុះកំណើនរយៈពេលមធ្យម ក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាខ្ពស់ ដោយធានានូវលទ្ធភាពឆ្លើយតបគ្រប់គ្រាន់ និង ចីរភាពហិរញ្ញវត្ថុសាធារណៈ"*

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ
នាថ្ងៃព្រហស្បតិ៍ ៧ កើត ខែ ពិសាខ ឆ្នាំ មមី អដ្ឋស័ក ព.ស.២៥៦៩
ត្រូវនឹងថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០២៦

# បុព្វកថា

ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (Medium Term Fiscal Framework - MTFF) ឆ្នាំ ២០២៧ - ២០២៩ ត្រូវបានដាក់ចេញ ដោយផ្តល់នូវទស្សនវិស័យ និងការតម្រង់ទិសការគ្រប់គ្រងម៉ាក្រូ-សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម ព្រមទាំងសម្រួចទិសដៅអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងគោលការណ៍ប្រើប្រាស់ធនធានជាតិ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ។ ជាមួយគ្នានេះ, ឯកសារនេះ ក៏ដើរតួនាទីស្នូលក្នុងការពង្រឹងការផ្សារភ្ជាប់រវាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងការរៀបចំថវិកាប្រចាំឆ្នាំ ដើម្បីវិភាជធនធាន ឱ្យស្របតាមអាទិភាពគោលនយោបាយអភិវឌ្ឍជាតិ និងពង្រឹងសមត្ថភាពក្នុងការឆ្លើយតបបានទៅនឹងបញ្ហាប្រឈម ដែលកំពុងកើតមានឡើងជាបន្តបន្ទាប់ ។

មិនខុសពីបរិការណ៍សកល និងតំបន់, កម្ពុជា បាន និងកំពុងស្ថិតក្នុងអន្តរកាលនៃពហុវិបត្តិ ដែលបន្តហ៊ុមព័ទ្ធទៅដោយភាពមិនប្រាកដប្រជាខ្ពស់ បណ្តាលមកពីការកើនឡើងកាន់តែខ្លាំងនៃការអនុវត្តគោលនយោបាយគាំពារនិយម (Protectionism) និងសង្គ្រាមពាណិជ្ជកម្ម, ភាពតានតឹងនៃការប្រកួតប្រជែងភូមិសាស្ត្រសេដ្ឋកិច្ច និងនយោបាយ ព្រមទាំងផលប៉ះពាល់កាន់តែធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ។ ជាក់ស្តែង ក្នុងរយៈពេល ២ ឆ្នាំចុងក្រោយ កម្ពុជាបានទទួលរងនូវព្យុះកំបុតត្បូង ចំនួន ៣ ផ្ទួនៗគ្នា ពោលគឺ **១)**. ការអនុវត្តគោលនយោបាយពន្ធគយបដិការរបស់សហរដ្ឋអាមេរិក, **២)**.បញ្ហាជម្លោះព្រំដែនកម្ពុជា-ថៃ, និង **៣)**. សង្គ្រាមនៅមជ្ឈិមបូព៌ា ដែលបណ្តាលឱ្យមានវិបត្តិថាមពល ។ ទាំងអស់នេះបានបង្កើនភាពមិនប្រាកដប្រជា និងបង្កជាហានិភ័យដល់កំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេលខ្លី ទៅមធ្យមខាងមុខ ។

ជាក់ស្តែង, សង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា ដែលមិនទាន់ឃើញមានសញ្ញារលត់ទៅវិញ បានបង្កឱ្យមានការកើនឡើងយ៉ាងគំហុកនៃថ្លៃប្រេងឥន្ធនៈ និងឧស្ម័ន បណ្តាលឱ្យមានសម្ពាធអតិផរណា និងប៉ះពាល់ដល់គន្លងកំណើនសេដ្ឋកិច្ចកម្ពុជា ។ ក្នុងបរិការណ៍ថ្មីនេះ, ទស្សនវិស័យកំណើនសេដ្ឋកិច្ចកម្ពុជា ត្រូវបានកែសម្រួលមកត្រឹមអត្រា **៤,២%** សម្រាប់ ឆ្នាំ ២០២៦ និង **៥,០%** សម្រាប់ ឆ្នាំ ២០២៧ ព្រមទាំងជាមធ្យមប្រមាណ **៥,៥%** សម្រាប់រយៈពេលមធ្យម ឆ្នាំ ២០២៨ និង ២០២៩ ។ ទន្ទឹមនេះ, ចំពោះផ្នែកហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម ក៏រងនូវផលប៉ះទង្គិចមួយចំនួនផងដែរ ដែល **ម្ខាង**, មូលដ្ឋានចំណូលរងនូវផលប៉ះពាល់ ស្របគ្នាជាមួយនឹងការដាក់ចេញនូវវិធានការចំណាយសារពើពន្ធជាបន្តបន្ទាប់ លើផលិតផលតេលសិលា ក៏ដូចជាមុខទំនិញមួយចំនួនដែលជំរុញដល់ការប្រើប្រាស់អគ្គិសនីជំនួសប្រេងឥន្ធនៈ; និង **ម្ខាងទៀត**, តម្រូវការចំណាយក៏កាន់តែកើន ដើម្បីឆ្លើយតបទៅនឹងតម្រូវការពាក់ព័ន្ធនឹងការការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី, ការរក្សាលំនឹងជីវភាពរបស់ប្រជាជន, ការកសាង និងជំរុញមូលដ្ឋានកំណើនសេដ្ឋកិច្ច ដែលធន់នឹងវិបត្តិ ព្រមទាំងការត្រៀមចំណាយសម្រាប់គាំទ្រដល់កិច្ចដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាពេលខាងមុខ ។ ក្នុងន័យនេះ, **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩** នឹងចូលរួមគាំទ្រអាទិភាពគោលនយោបាយចម្បងៗ ចំនួន **៧** រួមមាន៖ **១)**. ការការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី ព្រមទាំងការធានាស្ថិរភាព

នយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ២). ការខិតខំធានាលំនឹងជីវភាពប្រជាជន, ៣). ការជំរុញពិពិធកម្មសេដ្ឋកិច្ច និងការអភិវឌ្ឍប្រភពថ្មីនៃកំណើន, ៤). ការពង្រឹងបរិយាកាសធុរកិច្ច និងការលើកកម្ពស់វិស័យឯកជន រួមទាំងការបន្តបង្ក្រាបសកម្មភាពឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា, ៥). ការអភិវឌ្ឍមូលធនមនុស្ស និងសង្គម, ៦). ការជំរុញបរិវត្តកម្មឌីជីថល និងការអភិវឌ្ឍបៃតង និង ៧). ការពង្រឹងអភិបាលកិច្ច និងស្ថាប័ន ។

ដូចគ្នាទៅនឹងឆ្នាំមុនដែរ, **«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៧-២០២៩»** ឬហៅខ្លីថា **«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩»** ត្រូវបានរៀបចំក្នុងទម្រង់ ៣ ឆ្នាំរំកិល ក្នុងគោលបំណងសំខាន់ៗចំនួន ៤ រួមមាន៖ ១). ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុសាធារណៈ, ២). គាំទ្រការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល, ៣). ពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូល និងការវិភាជថវិកា, និង ៤). បង្កើនតម្លាភាពនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរៀបចំ **ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩** និង **សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៧** ។

**ជារួម, ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩ ត្រូវបានរៀបចំដោយប្រកាន់ខ្ជាប់នូវ «ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈអព្យាក្រឹត (Neutral Fiscal Stance)» ដែលគ្រោងការប្រមូលចំណូលចរន្តឱ្យមានកំណើនជាមធ្យម ក្នុងរង្វង់ ៧,៣% សម្រាប់ឆ្នាំ ២០២៧-២០២៩ ដែលក្នុងនោះ សម្រាប់ឆ្នាំ ២០២៧ មានកំណើន ៧,២% សមមូលនឹង ១៤,៧២% នៃ ផ.ស.ស. ។ ចំណាយសាធារណៈសរុប ត្រូវបានគ្រោងឱ្យមានកំណើនជាមធ្យម ៣,១% ក្នុងមួយឆ្នាំ ដែលក្នុងនោះ ចំណាយចរន្តសម្រាប់ឆ្នាំ ២០២៧ គ្រោងក្នុងកំណើនប្រមាណ ៧,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៦ សមមូលនឹង ១២,៤១% នៃ ផ.ស.ស. ។ ជាលទ្ធផល, ឱនភាពថវិកានឹងស្ថិតក្នុងរង្វង់ -១,៥៣% នៃ ផ.ស.ស. ជាមធ្យម សម្រាប់ឆ្នាំ ២០២៧-២០២៩ ដែលក្នុងនោះ សម្រាប់ឆ្នាំ ២០២៧ មានទំហំប្រមាណ -១,៧៩% នៃ ផ.ស.ស. ដោយធានានូវអនុលោមភាពតាមសូចនាករសំខាន់ៗ ដែលត្រូវបានកំណត់ដោយវិធានហិរញ្ញវត្ថុសាធារណៈ ។**

ឈរលើមូលដ្ឋាននេះ, **«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៧-២០២៩»** នឹងបន្តជាឧបករណ៍ដ៏សំខាន់ សម្រាប់រាជរដ្ឋាភិបាល ក្នុងការអនុវត្តវិធានការគោលនយោបាយនានា ប្រកបដោយភាពម្ចាស់ការ ភាពជឿទុកចិត្ត និងប្រសិទ្ធភាព សំដៅការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី, រក្សានូវលំនឹងជីវភាពប្រជាជន, ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុសាធារណៈ ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ច ក្នុងគោលដៅពង្រឹង និងពង្រីកសសរស្តម្ភសេដ្ឋកិច្ចជាតិឱ្យកាន់តែមានធនភាព, ពិពិធភាព, ភាពរឹងមាំ និងភាពធន់ ។

តាងនាមរាជរដ្ឋាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ កិច្ចខិតខំប្រឹងប្រែងទាំងកម្លាំងកាយ និងកម្លាំងចិត្ត របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការដឹកនាំរៀបចំឯកសារនេះឡើង ប្រកបដោយស្មារតីប្រុងប្រយ័ត្ន, បុរេសកម្ម និងបត់បែនខ្ពស់ ត្បិតក្នុងបរិការណ៍ដែលស្ថានភាពសេដ្ឋកិច្ច ទាំងតំបន់ និងសកលពោរពេញទៅដោយភាពមិនប្រាកដប្រជាខ្ពស់ និងមិនអាចប៉ាន់ស្មានបាន។ ទីចុងបញ្ចប់, ខ្ញុំសូមអនុម័ត និង

ប្រកាសដាក់ឱ្យអនុវត្តនូវ **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៧-២០២៩** ចាប់ពីពេលនេះតទៅ ដោយរាជរដ្ឋាភិបាលនឹងបន្តធ្វើការតាមដានយ៉ាងយកចិត្តទុកដាក់ខ្ពស់ លើការវិវត្ត និងវាយតម្លៃសភាពការណ៍ឡើងវិញ និង កែសម្រួលក្របខ័ណ្ឌនេះតាមការចាំបាច់ មុនពេលរៀបចំ **សេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៧** ។

ថ្ងៃអង្គារ ១១កើត ខែពិសាខ ឆ្នាំ មមី អដ្ឋស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# មាតិកា


**បុព្វកថា** ........ i

**១. បរិការណ៍រួម** ........ ១

**២. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច** ........ ៤

**២.១. បរិការណ៍សេដ្ឋកិច្ចសកល** ........ ៤

**២.២. ទិដ្ឋភាពសេដ្ឋកិច្ចកម្ពុជា** ........ ៦

ក. សមិទ្ធផលសេដ្ឋកិច្ចឆ្នាំ ២០២៥ និងទស្សនវិស័យ ឆ្នាំ ២០២៦ ........ ៧

ខ. ទស្សនវិស័យសេដ្ឋកិច្ចរយៈពេលមធ្យម ឆ្នាំ ២០២៧-២០២៩ ........ ១៨

គ. ហានិភ័យ និងទិសដៅគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ........ ២៣

**៣. យុទ្ធសាស្ត្រហិរញ្ញវត្ថុសាធារណៈ** ........ ២៧

**៣.១. ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ** ........ ២៧

**៣.២. វិធានហិរញ្ញវត្ថុសាធារណៈ** ........ ២៨

ក. យុថ្កាហិរញ្ញវត្ថុសាធារណៈ ........ ២៩

ខ. វិធានប្រតិបត្តិ ........ ២៩

**៣.៣. អាទិភាពគោលនយោបាយ** ........ ៣០

**៤. ក្របខ័ណ្ឌគោលនយោបាយ ហិរញ្ញវត្ថុសាធារណៈ** ........ ៣២

**៤.១. ការអនុវត្តថវិកា ឆ្នាំ ២០២៥ និង ២០២៦** ........ ៣២

ក. ការអនុវត្តថវិកា ឆ្នាំ ២០២៥ ........ ៣២

ខ. ការប៉ាន់ស្មានការអនុវត្តថវិកាឆ្នាំ ២០២៦ ........ ៣៣

គ. លទ្ធផលអនុវត្តថវិកាធៀបទៅនឹងវិធានហិរញ្ញវត្ថុសាធារណៈ ........ ៣៤

**៤.២. ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៧-២០២៩** ........ ៣៥

ក. ក្របខ័ណ្ឌចំណូល ........ ៣៦

ខ. ក្របខ័ណ្ឌចំណាយសាធារណៈ ........ ៤១

គ. ឱនភាពថវិកា និងហិរញ្ញប្បទាន ........ ៤៦

ឃ. លទ្ធផលក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមធៀបទៅនឹងវិធានហិរញ្ញវត្ថុសាធារណៈ ........ ៤៧

**៥. ហានិភ័យហិរញ្ញវត្ថុសាធារណៈ** ........ ៤៩

ក. ហានិភ័យម៉ាក្រូសេដ្ឋកិច្ច ........ ៥០

ខ. ហានិភ័យពីវិស័យហិរញ្ញវត្ថុ ........ ៥៣

គ. ហានិភ័យនៃការធានារបស់រដ្ឋកើតចេញពីភាពជាដៃគូរវាងរដ្ឋ និងឯកជន ..................................៥៤
ឃ. ហានិភ័យបំណុលរបស់រដ្ឋាភិបាល.......................................................................................៥៥
ង. ហានិភ័យពីសហគ្រាសសាធារណៈ....................................................................................... ៥៦
ច. ហានិភ័យពីការវិនិយោគសាធារណៈ .................................................................................... ៥៧
ឆ. ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ......................................................................... ៥៨
ជ. ភាពជឿទុកចិត្តបាននៃក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ..........................................................៥៩
**សេចក្តីសន្និដ្ឋាន.......................................................................................................... ៦០**
**ឧបសម្ព័ន្ធ ............................................................................................................... ៦២**
ឧបសម្ព័ន្ធ កៈ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២៣-២០២៩................................................... ៦២
ឧបសម្ព័ន្ធ ខៈ ក្របខ័ណ្ឌចំណូល-ចំណាយរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៩ .......................... ៦៣
ឧបសម្ព័ន្ធ គៈ ការបែងចែកចំណាយថ្នាក់ជាតិតាមវិស័យ ........................................................... ៦៥

# ១

# បរិការណ៍រួម

ក្នុងរយៈពេលជាង ៣ ទសវត្សរ៍ចុងក្រោយនេះ, កម្ពុជាត្រូវបានផ្លាស់ប្តូរមុខមាត់ គួរឱ្យកត់សម្គាល់លើឆាកអន្តរជាតិ ពីប្រទេសដែលហ៊ុមព័ទ្ធដោយសង្គ្រាមរ៉ាំរ៉ៃ និងមូលដ្ឋានសេដ្ឋកិច្ចផ្តើមពីចំណុចសូន្យ មកជាប្រទេស ដែលមានសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ និងសន្តិសុខសង្គម ព្រមទាំងសម្រេចបានវឌ្ឍនភាពគួរជាទីមោទនៈ ស្ទើរគ្រប់វិស័យ ។ សមិទ្ធផលទាំងនេះ បានបង្កើតជាមូលដ្ឋានគ្រឹះចាំបាច់បំផុត ក្នុងការធានានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ចីរភាពកំណើន, និងរចនាសម្ព័ន្ធសេដ្ឋកិច្ច ដែលកាន់តែមានពិពិធភាព និងភាពធន់ខ្ពស់ ដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាល មានលទ្ធភាពជំរុញការអភិវឌ្ឍលើគ្រប់វិស័យ, ពង្រឹងភាពធន់សង្គម-សេដ្ឋកិច្ច និង លើកកម្ពស់ជីវភាព និងសុខុមាលភាពប្រជាជន តាមរយៈការអនុវត្តគោលនយោបាយអាទិភាពនានា និងការពង្រីកប្រព័ន្ធគាំពារសង្គម ដែលមានវិសាលភាពទូលំទូលាយ ប្រសិទ្ធភាព និងបរិយាប័ន្នជាងមុន ។ សមិទ្ធផលទាំងនេះ មិនមែនកើតឡើងដោយចៃដន្យនោះទេ តែជាផ្លែផ្កានៃការតស៊ូឥតងាករេ និងកិច្ចខិតខំប្រឹងប្រែងយ៉ាងមោះមុតរបស់រាជរដ្ឋាភិបាលគ្រប់នីតិកាល ក្នុងការកំណត់យកនូវរបៀបវារៈគោលនយោបាយអាទិភាពថ្មីៗជាបន្តបន្ទាប់ ស្របតាមតថភាពជាក់ស្តែង តួយ៉ាង **ការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងការតភ្ជាប់ទៅនឹងប្រវាក់ផ្គត់ផ្គង់តំបន់ និងសកល, ការកែសម្រួលបរិយាកាសវិនិយោគ និងកិច្ចសម្រួលពាណិជ្ជកម្ម, ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសារវន្ត ដើម្បីបង្កើនការតភ្ជាប់, ការបន្តអភិវឌ្ឍមូលធនមនុស្ស, ការកែទម្រង់ស្ថាប័ន និងអភិបាលកិច្ច, ការជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច, ការលើកកម្ពស់ភាពប្រកួតប្រជែង និងការពង្រឹងភាពធន់នៃសេដ្ឋកិច្ច** ដើម្បីធ្វើយ៉ាងណាអាចនាំឱ្យកម្ពុជាសម្រេចបាននូវបង្គោលចអភិវឌ្ឍថ្មីបន្ថែមទៀត ជាពិសេសការកសាងខែល ឬរបាំងការពារ ដែលធន់នឹងវិបត្តិ ដូចបានកំណត់ក្នុង**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ** ។ ស្នាដៃបុរេសកម្ម និងចក្ខុវិស័យវែងឆ្ងាយទាំងនេះ បានក្លាយជាមូលដ្ឋានគ្រឹះដ៏សំខាន់ ក្នុងការកសាងភាពធន់គន្លឹះ ចំនួន ៥ របស់កម្ពុជា រួមមាន៖ ភាពធន់នៃស្ថាប័នសាធារណៈ, ភាពធន់នៃសេដ្ឋកិច្ច, ភាពធន់នៃសង្គម និងប្រជាជន, ភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុ, និង ភាពធន់នៃបរិស្ថាន និងអាកាសធាតុ ដែលអនុញ្ញាតឱ្យកម្ពុជាអាចទប់ទល់ និងសម្របខ្លួនបានយ៉ាងមានប្រសិទ្ធភាព ទៅនឹងពហុវិបត្តិផ្ទួនៗ តួយ៉ាង វិបត្តិជំងឺកូវីដ-១៩, ភាពតានតឹងនៃភូមិសាស្ត្រសេដ្ឋកិច្ច និងនយោបាយ, ការអនុវត្តគោលនយោបាយពន្ធគយបដិការរបស់សហរដ្ឋអាម៉េរិក, ការផ្ទុះឡើងនូវសង្គ្រាមឈ្លានពានពីប្រទេសថៃ លើអធិបតេយ្យជាតិ និងបូរណភាពទឹកដី, និងថ្មីៗនេះ សង្គ្រាមនៅមជ្ឈិមបូព៌ា ជាដើម ។

អស់រយៈពេលជិត ៣ ឆ្នាំ, រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា, ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយថាមពលរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា,** បានបន្តបំពេញបេសកកម្មជាតិដ៏ថ្លៃថ្លាប្រកបដោយទស្សនៈវិស័យវែងឆ្ងាយ និងការប្តេជ្ញាចិត្តដ៏មោះមុតដើម្បីបន្តពុះពារបម្រើ និងការពារឧត្តមប្រយោជន៍ជាតិ និងប្រជាជនកម្ពុជាគ្រប់កាលៈទេសៈ ស្របតាមឆន្ទៈ

និងបំណងប្រាថ្នារបស់ប្រជាជន ក៏ដូចជាលើកស្ទួយកិត្យានុភាពជាតិទាំងនៅក្នុងតំបន់ និងលើឆាកអន្តរជាតិ ។ ក្រោយពីបានដាក់ចេញ និងអនុវត្តនូវ **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»** និងការពង្រឹងការដ្ឋានកែទម្រង់សំខាន់ៗ, រាជរដ្ឋាភិបាល បានបន្តខិតខំដោះស្រាយបញ្ហាប្រឈមនានា និងជំរុញកែទម្រង់កាន់តែមុតស្រួច ក្នុងការសម្របខ្លួនទៅតាមការវិវត្តនៃសភាពការណ៍សកល និងតំបន់ ប្រកបដោយស្មារតីបុរេសកម្ម, ជាពិសេសគឺការចាប់យកនូវកាលានុវត្តភាព ដែលលេចចេញក្នុងបរិការណ៍នៃការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃនិម្មាបនកម្មសង្គម-សេដ្ឋកិច្ចសកល ។ ក្នុងសភាពការណ៍នេះ រាជរដ្ឋាភិបាលបានបន្តរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាខិតខំស្តារ និងជំរុញកំណើនជាបណ្តើរៗឡើងវិញបន្ទាប់ពីវិបត្តិកូវីដ-១៩ ដោយសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រា ៥% និងប្រមាណ ៦% ក្នុងឆ្នាំ ២០២៣ និងឆ្នាំ ២០២៤ រៀងគ្នា, ជាពិសេស រក្សាបានកំណើនមួយប្រសើរ ក្នុងអត្រា ៥,៣% ក្នុងឆ្នាំ ២០២៥ ខណៈទទួលរងនូវវិបត្តិមិនស្រាកស្រាន្តក្តី ជាពិសេសព្យុះកំបុតត្បូងពីកន្លងមក ។ ជាអកុសល, ក្នុងឆ្នាំ ២០២៥ នេះកម្ពុជាបានទទួលរងនូវព្យុះកំបុតត្បូង ថ្មីមួយទៀត ពោលគឺ សង្គ្រាមនៅមជ្ឈិមបូព៌ា ដែលបង្កើនភាពមិនប្រាកដប្រជា និងហានិភ័យដល់កំណើនសេដ្ឋកិច្ចកម្ពុជា មួយកម្រិតបន្ថែមទៀត ។ កម្មវិបាកធំៗ ទាំង៣ នេះ បានធ្វើឱ្យកម្ពុជាប្រឈមនឹងការលំបាកទ្វេដង ក្នុងការបត់បែនគោលនយោបាយរបស់ខ្លួនទាំងផ្នែកសេដ្ឋកិច្ច ផ្នែកការទូត និងផ្នែកសង្គម ដើម្បីបញ្ចៀស និងកាត់បន្ថយនូវកម្មវិបាកនានា, ទាំងផ្ទាល់ និងប្រយោល, មកលើសង្គម និងសេដ្ឋកិច្ច ។ **ក្នុងបរិការណ៍នេះ, កំណើនសេដ្ឋកិច្ចកម្ពុជា ដែលគ្រោងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦ ថាអាចសម្រេចបាន ៥,០% ត្រូវបានវាយតម្លៃថានឹងអាចសម្រេចបានត្រឹម ៤,២%** ដោយសារកម្មវិបាក និងឥទ្ធិពលសាយភាយពីបញ្ហាជម្លោះព្រំដែនកម្ពុជា-ថៃផង, ការបង្ក្រាបការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និង ការកើនថ្លៃថាមពល ដែលធ្វើឱ្យមានសម្ពាធអតិផរណា និង បន្តដះឥទ្ធិពលដល់វិស័យ សំខាន់ៗ តួយ៉ាងកសិកម្ម, ដឹកជញ្ជូន, ទេសចរណ៍ និងលក់ដុំ-រាយ ជាដើម ។

**ទន្ទឹមនេះ, ការព្យាករកំណើនសេដ្ឋកិច្ច សម្រាប់ឆ្នាំ ២០២៧ ក៏ត្រូវបានកែសម្រួលពីអត្រា ៥,៥% មកត្រឹម ៥% ដោយសារកម្មវិបាក ដែលនៅសេសសល់ពីបញ្ហាប្រឈមនានា ក្នុងឆ្នាំ ២០២៦ និង ព្យាករថានឹងសម្រេចបានជាមធ្យមប្រមាណ ៥,៥% ក្នុងរយៈពេលមធ្យម (២០២៨-២០២៩)** ដោយសារ ការរំពឹងទុកការងើបឡើងវិញ នៃសកម្មភាពសង្គម-សេដ្ឋកិច្ច ដែលនឹងត្រលប់ទៅរកប្រក្រតីភាពវិញ ។ គួរគូសបញ្ជាក់ថា, ការវាយតម្លៃទម្លាក់ការព្យាករនេះ ក៏មាននិន្នាការស្រដៀងគ្នាទៅនឹងស្ថាប័នអន្តរជាតិធំៗ ដែលបានកែតម្រូវកំណើនសេដ្ឋកិច្ចកម្ពុជាពីការព្យាករគោល ដែលបានដាក់ចេញកាលពីចុងឆ្នាំ ២០២៥ ដោយនៅរក្សាបានកំណើនក្នុងកម្រិតសមរម្យ តួយ៉ាងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានកែតម្រូវកំណើនសេដ្ឋកិច្ចកម្ពុជា ពីអត្រា ៤,២% និង ៤,៧% មក **៤% និង ៤,៧%**, ធនាគារពិភពលោក ពីអត្រា ៤,៣% និង ៤,៩% មក **៣,៩% និង ៤,៩%**, និងការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូកបី (AMRO) ពីអត្រា ៥,១% និង ៥,៣% មក **៤,៩% និង ៥,២%** សម្រាប់ឆ្នាំ ២០២៦ និង ២០២៧ រៀងគ្នា ។

ឈរលើទស្សនវិស័យកំណើនខាងលើនេះ, គោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមត្រូវរៀបចំឡើងដោយឈរលើ **«ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈអព្យាក្រឹត (Netural Fiscal Stance)»** ដើម្បីធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម ដែលក្នុងនោះ, នៅផ្នែកចំណូល, រាជរដ្ឋាភិបាល នឹងបន្តពង្រឹងការកៀរគរ និងពង្រីកមូលដ្ឋានចំណូល ខណៈចាប់អនុវត្តឡើងវិញនូវអត្រាពន្ធដាធរមាន លើផលិតផលតេលសិលាឡើងវិញ ក្រោយពីមានការបញ្ចុះអត្រាក្នុងឆ្នាំ ២០២៦ ។ ចំណែក

ង, ផ្នែកចំណាយ, រាជរដ្ឋាភិបាល នឹងបន្តពង្រឹងស័ក្តិសិទ្ធិភាពថវិកា ទាំងកម្រិតវិភាជន៍ និងប្រតិបត្តិការ តាមរយៈការបន្តធ្វើអាទិភាវូបនីយកម្មចំណាយ ដោយរក្សានូវលម្ហថវិកាសម្រាប់ធ្វើអន្តរាគមន៍សង្គម-សេដ្ឋកិច្ច នៅពេលកាលៈទេសៈតម្រូវ និងធានាលទ្ធភាពក្នុងការទ្រទ្រង់ដំណើរការនៃកិច្ចអភិវឌ្ឍ, និរន្តរភាពប្រតិបត្តិការការងារ និងការអនុវត្តកម្មវិធីគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ព្រមទាំងរក្សាកម្រិតប្រាក់សន្សំរបស់រាជរដ្ឋាភិបាល ពុំឱ្យមានការស្រុតស្រុត លើកលែងតែករណីចាំបាច់បំផុត ។

ជាការពិត, សភាពការណ៍សកល និងតំបន់ក្នុងពេលបច្ចុប្បន្ននេះ មានការវិវត្តយ៉ាងរហ័ស ពោរពេញទៅដោយភាពមិនប្រាកដប្រជាខ្ពស់ និងមិនអាចប៉ាន់ស្មានបាន ហើយភាគច្រើន មិនចំណុះក្រោមការគ្រប់គ្រងរបស់កម្ពុជាទាំងស្រុងនោះទេ ។ កម្ពុជា, ក្នុងនាមជាប្រទេសតូច បើកចំហ និងផ្អែកខ្លាំងលើពាណិជ្ជកម្មអន្តរជាតិ, ពិតជាមិនអាចត្រៀមវិធានការគោលនយោបាយ សម្រាប់គ្រប់សេណារីយ៉ូ ដែលអាចកើតឡើងបានឡើយ, **ក៏ប៉ុន្តែ កម្ពុជា នៅបន្តពង្រឹង និងពង្រីកខ្លួនឯង ពីមួយពេលទៅមួយពេល ដោយបានប្រកាន់ខ្ជាប់នូវអភិក្រមចំនួន ២** នោះគឺ ១). **វិធានការឆ្លើយតបទៅនឹងបញ្ហាបន្ទាន់ចំពោះមុខ និងក្នុងរយៈពេលខ្លី** ដោយផ្តោតលើការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ការរក្សាលំនឹងជីវភាព និងនិរន្តរភាពសកម្មភាពសង្គម-សេដ្ឋកិច្ច និង ២). **វិធានការគោលនយោបាយរយៈពេលមធ្យម និងវែងខាងមុខ** ដោយផ្តោតលើការបន្តដោះស្រាយជារចនាសម្ព័ន្ធក្នុងការជំរុញពិពិធកម្មសេដ្ឋកិច្ច, ការលើកកម្ពស់ភាពប្រកួតប្រជែង និងការកសាងភាពធន់សម្រាប់សង្គម-សេដ្ឋកិច្ច ដើម្បីត្រៀមលក្ខណៈឆ្លើយតបទៅនឹងវិបត្តិ ។ បន្ថែមពីនេះ, រាជរដ្ឋាភិបាល នឹងបន្តគ្រប់គ្រងស្ថានការណ៍ជាប្រចាំដោយប្រុងប្រយ័ត្ន តាមរយៈការក្តាប់ឱ្យបាននូវជីពចរនៃសេដ្ឋកិច្ច និងសង្គម ដើម្បីអាចដាក់ចេញវិធានការអន្តរាគមន៍ចាំបាច់ បុរេសកម្ម និងទាន់ពេល ឆ្លើយតបទៅនឹងភាពចលតនៃសភាពការណ៍ ។ ក្នុងស្ថានភាពនេះ, គោលនយោបាយហិរញ្ញវត្ថុសាធារណៈ (Fiscal Policy) ស្ថិតក្នុងភាពប្រុងប្រយ័ត្នជាប្រចាំ រក្សាភាពបត់បែនខ្ពស់ និងខិតខំឆ្លើយតបឱ្យចំគោលដៅ ដើម្បីធានាឱ្យបាននូវចីរភាពផ្នែកហិរញ្ញវត្ថុសាធារណៈ ដែលជាបុរេលក្ខខណ្ឌមិនអាចខ្វះបាន ។

ក្នុងន័យនេះ, ការដាក់ចេញនូវ «**ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៧-២០២៩**» ឬ ហៅខ្លីថា «**ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩**» ដែលអនុលោមតាម**ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ** និងស្របតាម **កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២០២៣-២០២៧** ក៏ដូចជា **យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាបច្ចុប្បន្នកម្ម ឆ្នាំ ២០២៥-២០២៨** បង្ហាញពីបច្ចុប្បន្នភាពនៃការព្យាករទស្សនវិស័យសេដ្ឋកិច្ច និងស្ថានភាពហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម, ការកំណត់យុទ្ធសាស្ត្រហិរញ្ញវត្ថុសាធារណៈ (Fiscal Strategy) និងការកំណត់នូវ **ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ (Fiscal Policy Stance)** ដោយប្រកាន់ខ្ជាប់នូវ **វិធានហិរញ្ញវត្ថុសាធារណៈមួយចំនួន (Fiscal Rules)** ព្រមទាំងធ្វើការវិភាគនូវ **ហានិភ័យហិរញ្ញវត្ថុសាធារណៈ (Fiscal Risks)** ។ លើសពីនេះ, ក្របខ័ណ្ឌនេះ នឹងក្លាយជាមូលដ្ឋានសម្រាប់ការរៀបចំនូវ «**ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩**» និង «**សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៧**» ។ ក្របខ័ណ្ឌនេះ ចែកចេញជា ៦ ផ្នែកសំខាន់ៗ រួមមាន ៖ ១). បរិការណ៍រួម (ផ្នែកនេះ), ២). ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច, ៣). យុទ្ធសាស្ត្រហិរញ្ញវត្ថុសាធារណៈ, ៤). ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ, ៥). ហានិភ័យហិរញ្ញវត្ថុសាធារណៈ, និង ៦). សេចក្តីសន្និដ្ឋាន ។

# ២

# ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

## ២.១. បរិការណ៍សេដ្ឋកិច្ចសកល

បើទោះបីជាស្ថានភាពនៃសេដ្ឋកិច្ចសកល បន្តស្ថិតក្នុងភាពចល័ត និងភាពមិនប្រាកដប្រជាខ្ពស់យ៉ាងណាក្តី ពិសេសដោយសារការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃរបបពាណិជ្ជកម្មសកល តួយ៉ាង តាមរយៈការដាក់ចេញនូវពន្ធគយបដិការ ក្នុងខែ មេសា ឆ្នាំ ២០២៥ ជាដើម ក៏កំណើនសេដ្ឋកិច្ចសកលនៅបន្តរក្សាបានចលនការល្អ ពុំអាក្រក់ខ្លាំងដូចការរំពឹងទុកក្រោយពីការប្រកាសដាក់ចេញនូវពន្ធគយបដិការភ្លាមៗនោះទេ ។ បើផ្អែកតាមរបាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចសកល របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលបានបោះផ្សាយក្នុងខែ មេសា ឆ្នាំ ២០២៦ នេះ សេដ្ឋកិច្ចសកល ក្នុងឆ្នាំ ២០២៥ ត្រូវបានវាយតម្លៃថា សម្រេចបានកំណើន ក្នុងអត្រា ៣,៤% ដែលចូលរួមគាំទ្រដោយកត្តាសំខាន់ៗ ទាំងបី ជាអាទិ៍ ***ទី១.*** ការពន្លឿនការនាំចេញ (Front-loading) នៅក្នុងឆមាសទី១ ឆ្នាំ ២០២៥, ***ទី២.*** ការបន្តនិន្នាការល្អនៃការវិនិយោគលើវិស័យបច្ចេកវិទ្យាពិសេសបញ្ញាសិប្បនិម្មិត (AI) និងថាមពលស្អាត ពីបណ្តាប្រទេសអភិវឌ្ឍន៍ តួយ៉ាងសហរដ្ឋអាម៉េរិក, និង ***ទី៣.*** ការបន្តបន្ធូរបន្ថយជាសន្សឹមៗនៃគោលនយោបាយរឹតបន្តឹងរូបិយវត្ថុ គួបផ្សំនឹងការអនុវត្តគោលនយោបាយវិត្តារកម្មថវិកា ដើម្បីគាំពារកំណើនសេដ្ឋកិច្ច របស់បណ្តាប្រទេសមួយចំនួន តួយ៉ាង ចិន, កូរ៉េខាងត្បូង និងអាល្លឺម៉ង់ ជាដើម ។ ការវាយតម្លៃចុងក្រោយបានបង្ហាញថា សន្ទុះកំណើនសេដ្ឋកិច្ចសកល ជារួម ក្នុងឆ្នាំ ២០២៥ បានខិតទៅរកល្បឿននៃកំណើន ដូចការវាយតម្លៃក្នុងបរិការណ៍មុនការប្រកាសដាក់ឱ្យអនុវត្តពន្ធគយបដិការ ពោលគឺការវាយតម្លៃក្នុងខែ មករា ឆ្នាំ ២០២៥ កន្លងទៅ ។

សម្រាប់ឆ្នាំ ២០២៦, កំណើនសេដ្ឋកិច្ចសកល ត្រូវបានប៉ាន់ស្មានថាមានកំណើនថមថយ មកត្រឹមអត្រា ៣,១% ទាបជាងការព្យាករដើមឆ្នាំ ដោយសារកម្មវិបាកនៃសង្គ្រាមក្នុងតំបន់មជ្ឈិមបូព៌ា ដែលបណ្តាលឱ្យមានការកើនឡើងយ៉ាងគំហុកនៃថ្លៃប្រេងឥន្ធនៈអន្តរជាតិ មកលើសកម្មភាពសេដ្ឋកិច្ច ខណៈមានការបន្ទចំបង្អាក់ដល់រំហូរពាណិជ្ជកម្ម និងទំនុកចិត្តវិនិយោគ ជារួម ។ ទោះជាយ៉ាងនេះក្តី, ផលរំខាននៃសង្គ្រាមនេះ មកលើកំណើនសេដ្ឋកិច្ច ក្នុងឆ្នាំ ២០២៦ គឺមានភាពខុសៗគ្នាទៅតាមបណ្តាប្រទេសនីមួយៗ ។ ជាក់ស្តែង សហរដ្ឋអាម៉េរិក នៅតែបន្តរក្សាបានភាពធន់ ក្នុងឆ្នាំ ២០២៦ ពោលគឺបន្តកើនឡើង បើធៀបនឹងឆ្នាំ ២០២៥ កន្លងទៅ ដោយសារនិន្នាការល្អនៃការប្រើប្រាស់ក្នុងស្រុក និងសកម្មភាពវិនិយោគ ដែលជាផលជះវិជ្ជមានពី ការបន្តបន្ធូរបន្ថយគោលនយោបាយរឹតបន្តឹងរូបិយវត្ថុ តាមរយៈការទម្លាក់អត្រាការប្រាក់គោល ក្នុងឆ្នាំកន្លងទៅ គួបផ្សំនឹងការលើកទឹកចិត្តផ្នែកគោលនយោបាយសារពើពន្ធ ដើម្បីជំរុញសកម្មភាពវិនិយោគ និងបង្កើនការងារក្នុងស្រុក ខណៈដែលចរន្តនៃការប្រើប្រាស់នៅបន្តរក្សាបាននិន្នាការរឹងមាំ ។ ដោយឡែក សេដ្ឋកិច្ចតំបន់ចាយប្រាក់អឺរ៉ូ ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនថមថយ ក្រោមការរំពឹងទុកពីផលប៉ះពាល់នៃការកើនថ្លៃថាមពលមកលើចំណូលពិត និងបន្ទចំបង្អាក់ដល់អំណាចទិញរបស់ប្រជាជន ជារួម ស្របពេលដែលទំនុកចិត្តវិនិយោគិន ក៏

រំពឹងថានឹងទទួលការប៉ះទង្គិច ពីភាពមិនប្រាកដប្រជាខ្ពស់នៃស្ថានភាពសេដ្ឋកិច្ចសកល ផងដែរ ។ សេដ្ឋកិច្ចចិន ក៏រំពឹងថានឹងមាននិន្នាការថមថយផងដែរ ដោយសារការរំពឹងទុកកំណើនយឺតនៃសកម្មភាពចាយ និងប្រើប្រាស់ក្នុងស្រុក ស្របពេលដែលនិន្នាការនៃការវិនិយោគក្នុងវិស័យអចលនទ្រព្យ ក៏នៅមានល្បឿនយឺត ។ ប៉ុន្តែ, កំណើនសេដ្ឋកិច្ចជារួម ក៏នៅតែស្ថិតក្នុងកម្រិតនៃគោលដៅកំណើនរបស់រាជរដ្ឋាភិបាលចិន ដែលបន្តទ្រទ្រង់ដោយការវិនិយោគដ៏សម្បើម ក្នុងវិស័យបច្ចេកវិទ្យា និងថាមពលបៃតង តួយ៉ាងឧស្សាហកម្មបច្ចេកវិទ្យាកម្រិតខ្ពស់ និងរថយន្តអគ្គិសនី ជាដើម ។

## តារាងទី១៖ កំណើនសេដ្ឋកិច្ចសកល និងតំបន់

| | សេដ្ឋកិច្ចសកល | ប្រទេសអភិវឌ្ឍន៍ | សេដ្ឋកិច្ចកំពុងរីកលូតលាស់ និងប្រទេសកំពុងអភិវឌ្ឍ | សហរដ្ឋអាមេរិក | តំបន់ចាយប្រាក់អឺរ៉ូ | ចក្រភពអង់គ្លេស | ជប៉ុន | ចិន | អាស៊ាន-៥ |
|---|---|---|---|---|---|---|---|---|---|
| 2024 | 3.4 | 1.8 | 4.5 | 2.8 | 0.9 | 1.1 | -0.2 | 5.0 | 4.8 |
| 2025 | 3.4 | 1.9 | 4.4 | 2.1 | 1.4 | 1.3 | 1.2 | 5.0 | 4.5 |
| 2026 | 3.1 | 1.8 | 3.9 | 2.3 | 1.1 | 0.8 | 0.7 | 4.4 | 4.1 |
| 2027 | 3.2 | 1.7 | 4.2 | 2.1 | 1.2 | 1.3 | 0.6 | 4.0 | 4.4 |
| 2028 | 3.2 | 1.7 | 4.2 | 2.1 | 1.4 | 1.6 | 0.6 | 4.0 | 4.5 |
| 2029 | 3.2 | 1.6 | 4.1 | 1.9 | 1.2 | 1.6 | 0.6 | 3.7 | 4.5 |

*ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ, ទស្សនវិស័យសេដ្ឋកិច្ចសកល ខែ មេសា ឆ្នាំ ២០២៦*

ក្នុងឆ្នាំ ២០២៧ និងរយៈពេលមធ្យមខាងមុខ (ឆ្នាំ ២០២៨-២០២៩) កំណើនសេដ្ឋកិច្ចសកល ជារួមនៅបន្តរក្សាបានស្ថិរភាពកំណើន ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំ ប្រមាណ ៣,២% ក្រោមការរំពឹងទុកការត្រលប់ទៅរកប្រក្រតីភាពវិញនៃច្រវាក់ផ្គត់ផ្គង់សកល, ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ប្រេងឥន្ធនៈ គួបផ្សំនឹងនិន្នាការនៃការបន្តវិនិយោគលើបញ្ញាសិប្បនិម្មិត (AI) និង បច្ចេកវិទ្យាកម្រិតខ្ពស់ដទៃទៀត ដើម្បីបង្កើនផលិតភាពគួបផ្សំនឹងការបន្តជំរុញការវិនិយោគលើថាមពលបៃតង ក្នុងគោលដៅលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាពសកល ។ ត្បិតថាសេដ្ឋកិច្ចសកល នៅបន្តបង្ហាញពីភាពធន់ក៏ពិតមែន ប៉ុន្តែទស្សនវិស័យសេដ្ឋកិច្ចនៅតែបន្តហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់ ដែលធ្វើឱ្យស្ថានភាពជារួម នៅបន្តមានភាពផុយស្រួយខ្លាំង ។ ហានិភ័យ និងភាពមិនប្រាកដប្រជាទាំងនេះរួមមាន៖ ***ទី១.*** ភាពមិនប្រាកដប្រជា និងភាពចល័តខ្ពស់នៃស្ថានការណ៍នៅតំបន់មជ្ឈិមបូព៌ា, ***ទី២.*** ការបន្ទច់បង្អាក់លើច្រវាក់ផ្គត់ផ្គង់សកល និងការហក់ឡើងវិញនៃថ្លៃទំនិញអន្តរជាតិ ពិសេសថ្លៃប្រេងឥន្ធនៈ និងលទ្ធភាពនៃការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុឡើងវិញ សំដៅបន្ធូរបន្ថយសម្ពាធអតិផរណា, និង ***ទី៣.*** ការប្រើប្រាស់ឧបករណ៍គោលនយោបាយពាណិជ្ជកម្មជាខែល ដើម្បីការពារផលប្រយោជន៍នេះ ដែលបាននិងកំពុងជំរុញឱ្យមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស និងពុំអាចប៉ាន់ស្មានទុកមុនបាននៃរបបពាណិជ្ជកម្មសកល ។

ទន្ទឹមនឹងហានិភ័យ និងភាពមិនប្រាកដប្រជាខាងលើនេះ, និន្នាការថ្មីៗមួយចំនួនក៏បានលេចឡើងជាបន្តបន្ទាប់ផងដែរ ដែលចង្អុលបង្ហាញឱ្យឃើញកាន់តែច្បាស់ថែមទៀតថា របៀបវារៈគោលនយោបាយ និងរបៀបរបបចាស់ ពុំអាចយកមកអនុវត្តបានក្នុងបរិការណ៍ថ្មីនេះបានឡើយ ។ និន្នាការថ្មីៗទាំងនោះរួមមាន៖ ***ទី១.*** ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃរបបពាណិជ្ជកម្មសកល ក៏ដូចជាភាពតានតឹងភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចបាននិងកំពុងបង្ហាញពីនិន្នាការឈានឆ្ពោះកាន់តែលឿនទៅរកបដិសកលភាវូបនីយកម្ម និងគោលនយោបាយគាំពារនិយម និងឯកតោភាគីនិយម ដែលនឹងជំរុញឱ្យកើតនូវ **«ប្រព័ន្ធប្រតិបត្តិការថ្មីនៃសកលលោក New**

Global Operating system» ជាមួយនឹងពិភពលោកពហុប៉ូល (Multipolar world), ***ទី២.*** ការបង្វែរប្រវាក់ផលិតកម្ម និងរោងចក្រ ដើម្បីពង្រាយមូលដ្ឋានផលិតកម្ម សំដៅពង្រឹកខ្សែប្រវាក់ផ្គត់ផ្គង់ ទាំងក្នុងសកល និងតំបន់, ***ទី៣.*** ការបន្តវិនិយោគដ៏សម្បើមទៅលើបច្ចេកវិទ្យា និង បញ្ញាសិប្បនិម្មិត (AI) ដើម្បីជំរុញកំណើនផលិតភាពសេដ្ឋកិច្ច, និង ***ទី៤.*** ការបន្តជំរុញការវិនិយោគ និងយកចិត្តទុកដាក់ទៅលើថាមពលស្អាត និងកកើតឡើងវិញ ដើម្បីលើកកម្ពស់ការផ្សារភ្ជាប់រវាងសង្គម-សេដ្ឋកិច្ច និងចីរភាពបរិស្ថាន ។

## ២.២. ទិដ្ឋភាពសេដ្ឋកិច្ចកម្ពុជា

ក្នុងឆ្នាំ ២០២៥ កន្លងទៅ សេដ្ឋកិច្ចកម្ពុជាបានទទួលរងព្យុះកំបុតត្បូង (headwind) ចំនួន ២ ចម្បងៗ នោះគឺ ការដាក់ឱ្យអនុវត្តពន្ធគយបដិការរបស់សហរដ្ឋអាម៉េរិក និង ភាពតានតឹងនៃបញ្ហាព្រំដែនកម្ពុជា-ថៃ រហូតឈានដល់ការប៉ះទង្គិចប្រដាប់អាវុធចំនួន ២ លើក ។ ជាកុសលសម្រាប់កម្ពុជា, ការអនុវត្តពន្ធគយបដិការរបស់សហរដ្ឋអាម៉េរិក ពុំបានរំលេចនូវបច្ច័យអវិជ្ជមាន ណាមួយធំដុំលើសកម្មភាពសេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ ២០២៥ នោះទេ, ដោយផ្ទុយទៅវិញ បានជំរុញការនាំចេញរបស់កម្ពុជាទៅទីផ្សារសហរដ្ឋអាម៉េរិក ដោយសារការពន្លឿនការនាំចេញ (Front-loading) មុនអត្រាផ្លូវការចូលជាធរមាន ពេលក្នុងឆមាសទី១ ឆ្នាំ ២០២៥ ។ ក្រោយអត្រាពន្ធគយបដិការ ១៩% ដែលជាកម្រិតប្រហាក់ប្រហែលទៅនឹងបណ្តាប្រទេសក្នុងតំបន់ ចូលជាធរមាន ចាប់តាំងពីអំឡុងខែ សីហា ឆ្នាំ ២០២៥ កន្លងមក ក៏ពុំបានបន្ថយបង្អាក់ដល់ការនាំចេញកម្ពុជាទៅទីផ្សារសហរដ្ឋអាម៉េរិកនោះដែរ ពោលទាំងផលិតផលកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ខណៈដែលទីផ្សារផ្សេងទៀត ដូចយ៉ាងសហភាពអឺរ៉ុប ក៏នៅតែមានស្ថានភាពល្អប្រសើរ ។

យ៉ាងណាមិញ, ការបិទខ្ទប់ព្រំដែនគោកកម្ពុជា-ថៃ ដោយឯកតោភាគីរបស់ថៃ និងភាពតានតឹងជុំវិញបញ្ហាព្រំដែននេះ បានបង្កជាបច្ច័យអវិជ្ជមានគួរឱ្យកត់សម្គាល់ដល់សកម្មភាពសេដ្ឋកិច្ចកម្ពុជា ជាអាទិ៍ សកម្មភាពផលិតកម្មថៃបូកមួយ (Thailand+1), សកម្មភាពទេសចរណ៍ ដែលពឹងផ្អែកច្រកព្រំដែនកម្ពុជា-ថៃ, ការនាំចេញផលិតផលកសិកម្ម និងផ្ទៃដីដាំដុះ រួមមាន ពោតក្រហម និងដំឡូងមី, រំហូរនៃប្រាក់បង្វែរឯកជនដោយសារការវិលត្រលប់មកវិញនៃទេសន្តរប្រវេសន៍កម្ពុជា, និងបច្ច័យមកលើសកម្មភាពដឹកជញ្ជូន និង វិស័យហិរញ្ញវត្ថុ ជាដើម ។ ទោះយ៉ាងនេះក្តី, កម្ពុជា មានការលេចចេញនូវនិន្នាការថ្មីៗគួរឱ្យកត់សម្គាល់មួយចំនួន រួមមាន៖ ការងាកមកគាំទ្រ និងប្រើប្រាស់ផលិតផលក្នុងស្រុក និងការបង្កើនសមត្ថភាព និងកម្លាំងផលិតកម្មក្នុងស្រុក, ការបង្វែរទិសដៅដឹកជញ្ជូន (Re-routing) និងការផ្លាស់ប្តូរមធ្យោបាយដឹកជញ្ជូន, និងការធ្វើពិពិធកម្មនៃប្រវាក់តម្លៃពីទីផ្សារថៃ ពោលទាំងក្នុងវិស័យផលិតកម្ម និងសេវាកម្ម ពិសេសទេសចរណ៍ ។ ជារួម, បញ្ហាព្រំដែនកម្ពុជា-ថៃនេះ នឹងផ្តល់កម្មវិបាក ទាំងវិជ្ជមាន និងអវិជ្ជមានដល់ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ ២០២៦ និងក្នុងរយៈពេលខ្លី និងមធ្យម ខាងមុខ ។

**ជារួម, ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ, កម្ពុជា បានទទួលរងនូវបញ្ហាប្រឈមផ្ទួនៗ បង្កឡើងដោយកត្តាខាងក្រៅ និងកត្តាខាងក្នុង ដែលមានកម្មវិបាកដល់សេដ្ឋកិច្ចកម្ពុជាទាំងផ្ទាល់ និងប្រយោល** ។ ក្នុងនោះ, **កត្តាខាងក្រៅ** រួមមាន៖ ១). ការផ្ទុះសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា ដែលបង្កឱ្យថ្លៃប្រេងឥន្ធនៈកើនយ៉ាងគំហុក, ២). ការអនុវត្តពន្ធគយបដិការរបស់សហរដ្ឋអាម៉េរិក, ៣). ការថមថយសន្ទុះសេដ្ឋកិច្ចសកល ជាពិសេសប្រទេសជាដៃគូពាណិជ្ជកម្មជាមួយកម្ពុជា និង ៤). បញ្ហាជម្លោះព្រំដែនកម្ពុជា-ថៃ ។ រីឯ, បញ្ហាប្រឈម ដែលបង្កឡើងដោយ **កត្តាខាងក្នុង** រួមមាន៖ ១). សន្ទុះកំណើនយឺតក្នុងវិស័យមួយចំនួន ជាអាទិ៍ សំណង់, អចលនទ្រព្យ និងទេសចរណ៍, ២). ការនាំចេញនៅមានលក្ខណៈប្រមូលផ្តុំខ្លាំង តែទៅកាន់ទីផ្សារមួយចំនួន, ៣). បញ្ហា

បំណុលឯកជន ដែលស្ថិតក្នុងកម្រិតខ្ពស់ និងការបន្តកើនឡើងនៃឥណទានមិនដំណើរការ (NPL), និង ៤). ការកៀរគរចំណូលបន្តមានកំណើនទាប និងការថមថយនៃហិរញ្ញប្បទានក្រៅប្រទេស ។ បន្ថែមលើនេះ, កម្ពុជាក៏នៅតែបន្តប្រឈមនឹង **បញ្ហាជារចនាសម្ព័ន្ធផ្ទៃក្នុងមួយចំនួន** ដែលទាមទារការបន្តពង្រឹងការដ្ឋានកែទម្រង់ស៊ីជម្រៅ ដែលមានដូចជា៖ ១). ល្បឿនយឺតនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច, ២). ថ្លៃដើមធុរកិច្ចនៅមិនទាន់មានភាពប្រកួតប្រជែង, ៣). ភាពមានកម្រិតនៃគុណភាពនៃកម្លាំងពលកម្ម ដែលមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និង ៤). កង្វះខាតនូវឧស្សាហកម្មដើមខ្សែ (Upstream industries) និងឧស្សាហកម្មប្រតិគមន៍ គួបផ្សំនឹងភាពមានកម្រិតនៃការថ្លក់ភ្ជាប់ឧស្សាហកម្មទាំងនោះ ទៅនឹងខ្សែច្រវាក់ផលិតកម្មក្នុងស្រុក ។

ទោះជាយ៉ាងនេះក្តី, **កម្ពុជាក៏បានពូនជ្រំនូវមូលដ្ឋានគ្រឹះសំខាន់ៗ ដែលជាចលករជំរុញការប្រែក្លាយបញ្ហាប្រឈម ទៅជាកាលានុវត្តភាព សំដៅបន្តពង្រឹងកម្លាំងសេដ្ឋកិច្ចក្នុងស្រុក និងគាំពារចលនការកំណើន** ។ មូលដ្ឋានគ្រឹះដ៏រឹងមាំទាំងនោះ រួមមាន៖ ១). ការរក្សាបាននិន្នាការរឹងមាំ និងការបន្តរីកធំនៃសកម្មភាពនៃវិស័យកម្មន្តសាល ជាពិសេសវិស័យកសិ-ឧស្សាហកម្មកែច្នៃ និងឧស្សាហកម្មធុនធ្ងន់មួយចំនួន ជាអាទិ៍ ឧស្សាហកម្មគ្រឿងបង្គុំអេឡិចត្រូនិក, ព្រមទាំងឧស្សាហកម្មផ្គុំ និងដំឡើងរថយន្ត, និងឧស្សាហកម្មសំបកកង់រថយន្ត, ២). ការបន្តកើនឡើងជាលំដាប់នៃផលិតកម្មកសិកម្ម ដែលផ្តល់លក្ខខ័ណ្ឌល្អដល់ការជំរុញឧស្សាហកម្មកែច្នៃ, ៣). ការវិលត្រលប់មកវិញនៃពលករទេសន្តរប្រវេសន៍ ដែលនឹងជំរុញកម្លាំងប្រមូលផ្តុំនៃសន្និធិមូលធន ដែលជាមូលដ្ឋានចាំបាច់ក្នុងការលើកកម្ពស់ឧស្សាហកម្ម និងក្នុងការទាក់ទាញការវិនិយោគ, ៤). ភាពប្រសើរនៃលម្ហថវិកា និងការបន្តរក្សាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ និងនិរន្តរភាពនៃបំណុលសាធារណៈ បើទោះត្រូវឆ្លើយតបទៅនឹងការបន្តកើនឡើងជាលំដាប់នៃតម្រូវការចំណាយ ដើម្បីទ្រទ្រង់កិច្ចអភិវឌ្ឍន៍, និង ៥). ភាពរឹងមាំ និងស្ថិរភាពនៃវិស័យហិរញ្ញវត្ថុ ទោះជាមានកម្មវិបាកពីការបង្ក្រាបសកម្មភាពឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុសកលនាពេលកន្លងមក ។

## ក. សមិទ្ធផលសេដ្ឋកិច្ចឆ្នាំ ២០២៥ និងទស្សនវិស័យ ឆ្នាំ ២០២៦

សេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ ២០២៥ សម្រេចបានកំណើនក្នុងអត្រា ៥,៣% ដែលក្នុងនោះ វិស័យបម្រើការនាំចេញសំខាន់ៗទាំងពីរ ពោលគឺវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ រក្សាបានចលនការរឹងមាំ បើទោះបីរងកម្មវិបាកពីការអនុវត្តពន្ធគយបដិការក្តី ។ វិស័យកសិកម្ម ក៏សម្រេចបានកំណើនល្អ ដែលជំរុញដោយកត្តាថ្លៃល្អ និងការបង្កើនផលិតកម្ម ក្នុងឆមាសទី១ ឆ្នាំ ២០២៥ ពិសេស ស្រូវ, ស្វាយចន្ទី, ដំឡូងមី, និងពោត បើទោះបីមានបញ្ហាព្រំដែន និងនិន្នាការធ្លាក់ចុះថ្លៃអន្តរជាតិ ចាប់តាំងពីអំឡុងឆមាសទី២ ឆ្នាំ ២០២៥ យ៉ាងណាក្តី ។ ជាមួយគ្នានេះ, វិស័យលក់ដុំ-រាយ (ការប្រើប្រាស់ក្នុងស្រុក) ក៏នៅបន្តរក្សាបាននិន្នាការរឹងមាំ ឆ្លុះបញ្ចាំងតាមរយៈកំណើនល្អប្រសើរនៃសកម្មភាពចាយវាយក្នុងស្រុក ពោលទាំងលើទំនិញចាំបាច់ និងទំនិញប្រណិត ឧទា. រថយន្ត, គួបផ្សំនឹងការងាកមកគាំទ្រ និងប្រើប្រាស់ផលិតផលក្នុងស្រុក ។ ដោយឡែក, វិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ (ទេសចរណ៍) សម្រេចបានកំណើនទាប ដោយសារទទួលរងនូវកម្មវិបាកអវិជ្ជមាន ពីការបិទខ្ទប់ព្រំដែនគោកកម្ពុជា-ថៃ ដែលធ្វើឱ្យបាត់បង់មូលដ្ឋានទេសចរធ្វើដំណើរតាមផ្លូវគោកទាំងស្រុង ស្របពេលទេសចរមានលក្ខណៈជាកញ្ចប់ទូរថៃបូកមួយ ក៏បានទទួលរងផលប៉ះពាល់ ខណៈបញ្ហាអស្ថិរភាពដែលបង្កឡើងដោយការប៉ះទង្គិចប្រដាប់អាវុធ បានធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តដំណើរកំសាន្ត ជារួម ។ ទន្ទឹមនេះ, ការបិទខ្ទប់ព្រំដែនគោកកម្ពុជា-ថៃ ក៏បានធ្វើឱ្យច្រវាក់ផលិតកម្មថៃបូកមួយ ព្រមទាំងផលិតកម្ម និងសកម្មភាពពាណិជ្ជកម្មដែលស្ថិតនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ទទួល

វេងផលប៉ះពាល់ដែរ ដោយសារភាពអាក់អួលនៃការផ្គត់ផ្គង់វត្ថុធាតុដើម ។ ពិតណាស់, ការអនុវត្តវិធានការអន្តរាគមន៍ភ្លាមៗ ពីសំណាក់រាជរដ្ឋាភិបាល ឆ្លើយតបទៅនឹងបញ្ហាចម្បងៗ ចំពោះមុខទាំងពីរនេះ ក៏បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការសម្រួលដល់ដំណើរការផលិតកម្ម និងសកម្មភាពសេដ្ឋកិច្ចពាក់ព័ន្ធ សំដៅកាត់បន្ថយផលប៉ះពាល់ឱ្យបានជាអតិបរមា ក៏ដូចជាធានានូវស្ថិរភាពសង្គម-សេដ្ឋកិច្ច ជារួម ។

ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ ២០២៦ នេះ នៅតែបន្តជួបប្រឈមនឹងអន្តរកាលនៃពហុវិបត្តិ, ក្នុងន័យថា ខណៈដែលការប្រែប្រួលរបបពាណិជ្ជកម្មសកល, ពោលគឺ ការដំឡើងពន្ធជាសកល (Global Tariff) របស់សហរដ្ឋអាមេរិក, ការបង្ក្រាប និងទប់ស្កាត់សកម្មភាពឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams), និង បញ្ហាព្រំដែនកម្ពុជា-ថៃ មិនទាន់មានភាពច្បាស់លាស់ផង, បញ្ហាសង្គ្រាមនៅតំបន់មជ្ឈិម-បូព៌ា ក៏បានផ្ទុះឡើងទៀត ។ ព្រឹត្តិការណ៍នេះ បាន និង កំពុង បង្កើនមិស្សភាពកាន់តែខ្លាំងឡើង ដល់ទស្សន-វិស័យសេដ្ឋកិច្ច, ទាំងកម្រិតសកល, តំបន់ និង រួមទាំងកម្ពុជា ផង, ស្របពេលដែលស្ថានភាពជារួម បន្តមានភាពមិនប្រាកដប្រជា និង ប្រែប្រួលលឿន ។ នេះ បានសេចក្តីថា ស្ថានការណ៍អាចវិវត្តក្នុងទិសដៅណាមួយនោះ យ៉ាងរហ័ស ក្នុងរយៈពេលមួយដ៏ខ្លី, ហើយអាចនឹងមានការប្រែប្រួលជាបន្តបន្ទាប់ទៀត ដោយពិបាកប៉ាន់ប្រមាណទុកមុនបាន ។ ដោយផ្អែកលើស្ថានភាពមួយដែលមានភាពមិនប្រាកដប្រជា និងភាពចល័តខ្ពស់, ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ ២០២៦ និងរយៈពេលមធ្យមខាងមុខ ត្រូវបានរៀបចំឡើងដោយ ការគិតគូរក្នុងសុទិដ្ឋិនិយមប្រយ័ត្នប្រយែង និងមិនទុទិដ្ឋិនិយមជ្រុល ។ ក្នុងន័យនេះ, ការប៉ាន់ស្មានកំណើនសេដ្ឋកិច្ច ក្នុងឆ្នាំ ២០២៦ នេះ ក៏ដូចជាព្យាករក្នុងរយៈពេលមធ្យមខាងមុខ ឈរលើមូលដ្ឋានសម្មតិកម្ម និងការសន្មតគន្លឹះចំនួន ៣ ចម្បងៗ សម្រាប់សេណារីយ៉ូនៃបន្ទាត់មូលដ្ឋាន (Baseline), រួមមាន៖ ***ទី១.*** សង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា បានជំរុញឱ្យថ្លៃប្រេងឥន្ធនៈអន្តរជាតិ (Brent crude oil) ជាមធ្យមប្រចាំឆ្នាំ ២០២៦ កើនឡើង ក្នុងរង្វង់ ៨០ ដុល្លារអាមេរិក/បារ៉ែល បើធៀបនឹងកម្រិតមុនសង្គ្រាម (ប្រមាណក្នុងរង្វង់ ៦០ ដុល្លារអាមេរិក/បារ៉ែល), ហើយបន្តត្រលប់ទៅរកកម្រិតថ្លៃមុនសង្គ្រាមជាសន្សឹមៗ ប្រមាណ ក្នុងរង្វង់ ៦០-៧០ ដុល្លារអាមេរិក/បារ៉ែល ក្នុងឆ្នាំ ២០២៧ និងក្នុងរយៈពេលមធ្យមខាងមុខ; ***ទី២.*** បញ្ហាព្រំដែនកម្ពុជា-ថៃ នៅរក្សាបាននូវស្ថានភាពដូចបច្ចុប្បន្ន ពោលគឺពុំមានភាពតានតឹង ឬការប៉ះទង្គិចប្រដាប់អាវុធ ឬការដាក់វិទ្ធង្សនាសេដ្ឋកិច្ចមកលើកម្ពុជា, និង ***ទី៣.*** ទស្សនវិស័យសេដ្ឋកិច្ចសកល ពោលគឺកំណើនសេដ្ឋកិច្ចក្នុងឆ្នាំ ២០២៦ ពិសេសបណ្តាប្រទេសដែលជាដៃគូពាណិជ្ជកម្មរបស់កម្ពុជា បើទោះបីមានការថមថយនូវសន្ទុះកំណើន ប៉ុន្តែនឹងមិនបង្កផលប៉ះពាល់ធំដុំពេកដល់តម្រូវការសកលឡើយ ។ ការជ្រើសយកសេណារីយ៉ូបន្ទាត់មូលដ្ឋានសម្រាប់ការរៀបចំក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម ផ្អែកលើការសន្មតថ្លៃប្រេងឥន្ធនៈអន្តរជាតិ គឺជាកត្តាកំណត់ (Determining factors) ។ កំណើនសេដ្ឋកិច្ចរលាស់ទៅតាមការប្រែប្រួលថ្លៃប្រេង ពីព្រោះថ្លៃប្រេងប៉ះពាល់ដល់លំហូរពាណិជ្ជកម្មសកល, ការវិនិយោគផ្ទាល់ពីបរទេសសកល, តម្រូវការសកល និងការផ្លាស់ប្តូរលក្ខខណ្ឌហិរញ្ញវត្ថុ (Financial conditions) ។ ក្រោមក្របខ័ណ្ឌនេះ, ការសន្មតថ្លៃប្រេងឥន្ធនៈអន្តរជាតិ និងសម្មតិកម្មផ្សេងទៀត ក៏មានសង្គតិភាពទៅនឹងការគិតគូររបស់ស្ថាប័នអន្តរជាតិធំៗ តួយ៉ាងដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF), ធនាគារពិភពលោក (World Bank) និងការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចតំបន់អាស៊ានបូកបី (AMRO) ជាដើម ។ ប្រាកដណាស់, ក្នុងករណីស្ថានការណ៍នេះវិវត្តទៅកាន់តែអាក្រក់ជាង ការរំពឹងទុកក្នុងបន្ទាត់មូលដ្ឋាន នោះក៏នឹងធ្វើឱ្យកំណើនសេដ្ឋកិច្ច រលាស់ទៅក្នុងនិន្នាការថមថយ ផងដែរ (**ការវិភាគវេទយិតភាព មានលម្អិតក្នុងផ្នែកហានិភ័យ**) ។

ផ្អែកលើបន្ទាត់មូលដ្ឋាននេះ, សេដ្ឋកិច្ចកម្ពុជា ត្រូវបានវាយតម្លៃនឹងសម្រេចបានកំណើន ក្នុងអត្រា ៤,២% ប៉ុណ្ណោះ ក្នុងឆ្នាំ ២០២៦ ដែលថមថយពី អត្រា ៥,៣% ឆ្នាំ ២០២៥ និងពីអត្រា ៥,០% ពីការរំពឹងទុកក្នុងច្បាប់ថវិកាកន្លងទៅ ដោយសារកម្មវិបាកផ្ទួនៗគ្នាជាអវិជ្ជមានពីបញ្ហា ៣ ធំៗ នោះគឺ **១.** ការកើនឡើងថ្លៃប្រេងឥន្ធនៈ ពិសេសមកលើវិស័យដែលពឹងផ្អែកលើប្រេងជាកត្តាផលិតកម្ម តួយ៉ាង កសិកម្ម, ដឹកជញ្ជូន, និងទេសចរណ៍ ជាដើម គួបផ្សំនឹងការកើនឡើងនៃសម្ពាធអតិផរណា ដែលអាចបន្ទច់បង្អាក់ដល់សកម្មភាពចាយ និងប្រើប្រាស់ជារួម, **២.** កម្មវិបាក និងឥទ្ធិពលសាយភាយពីបញ្ហាព្រំដែនកម្ពុជា-ថៃ ពិសេសលើប្រាក់បង្វែរឯកជន, ទេសចរណ៍ ដែលពឹងផ្អែកច្រកព្រំដែនអន្តរជាតិកម្ពុជា-ថៃ និង ការនាំចេញកសិផល ជាដើម និង **៣.** ផលប៉ះពាល់ក្នុងរយៈពេលខ្លី នៃការបង្ក្រាបសកម្មភាពឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា មកលើសេដ្ឋកិច្ច ពិសេសវិស័យសំណង់-អចលនទ្រព្យ និងការប្រើប្រាស់ក្នុងស្រុក ដោយសារការបាត់បង់ចំណូលពីសកម្មភាពនេះ ។ ក្នុងនោះ, វិស័យកសិកម្ម រំពឹងថានឹងមាននិន្នាការ ថមថយ, ***ម្ខាង***, ដោយសារផលប៉ះពាល់ពីការប៉ះទង្គិចប្រដាប់អាវុធលើផ្ទៃដីបង្កបង្កើនផល និងការមិនទាន់វិលត្រលប់ទៅលំនៅឋានវិញបាន របស់ប្រជាពលរដ្ឋភៀសសឹក ផង, និង***ម្ខាងទៀត***, និន្នាការធ្លាក់ចុះថ្លៃអន្តរជាតិ ដែលអាចបន្ទច់បង្អាក់ដល់ការបង្កើនទំហំផលិតកម្ម ខណៈដែលថ្លៃដើមនៃធាតុចូលកសិកម្ម ក៏មាននិន្នាការកើនឡើងជារួម ផង ។ វិស័យទេសចរណ៍ រំពឹងថានឹងបន្តមានកំណើនយឺត ដោយសារឥទ្ធិពលអវិជ្ជមាននៃបញ្ហាព្រំដែនកម្ពុជា-ថៃ, ការបង្ក្រាបសកម្មភាពឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា, និងសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា មកលើទំនុកចិត្តការធ្វើដំណើរ និងលំហូរទេសចរអន្តរជាតិមកកម្ពុជា ជារួម, ប៉ុន្តែវិស័យនេះនៅបន្តគាំទ្រដោយនិន្នាការទេសចរក្នុងស្រុក ។ វិស័យលក់ដុំ-រាយ (ការប្រើប្រាស់ក្នុងស្រុក) រំពឹងថានឹងមាននិន្នាការថមថយ ពិសេសសកម្មភាពប្រើប្រាស់លើទំនិញប្រណីត ដោយសារភាពប្រុងប្រយ័ត្នខ្ពស់លើការចាយ ក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជានៃកត្តាសេដ្ឋកិច្ច, ប៉ុន្តែវិស័យនេះ ជារួមនៅបន្តគាំទ្រដោយការប្រើប្រាស់លើទំនិញចាំបាច់ គួបផ្សំនឹងចរន្តនៃការប្រើប្រាស់ផលិតផលក្នុងស្រុក ។ ដោយឡែក, វិស័យបម្រើការនាំចេញ (កាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ) រំពឹងថានឹងបន្តមានកំណើនល្អ ក្នុងបរិការណ៍ដែលថាពុំមានការប្រែប្រួលអត្រាពន្ធគយ និង/ឬ ពុំមានការបំផុសនូវរបាំងពាណិជ្ជកម្មថ្មីខ្លាំងក្លាគួរឱ្យកត់សម្គាល់បន្ថែមទៀត ហើយសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា និងមិនបង្កផលប៉ះពាល់ធ្ងន់ធ្ងរពេកដល់តម្រូវការសកល ។




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (២០១៩-២០២៥) និងការព្យាករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២៦-២០២៩)*

## ■ វិស័យឧស្សាហកម្ម

**វិស័យឧស្សាហកម្ម** ត្រូវបានវាយតម្លៃថាបន្តរក្សាចលនការកំណើនរឹងមាំ ក្នុងអត្រា ៨,៧% ក្នុងឆ្នាំ ២០២៥ ដែលបន្តគាំទ្រដោយកំណើនរឹងមាំនៃអនុវិស័យកាត់ដេរ និងអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ បើទោះបីរងកម្មវិបាកពីពន្ធគយបដិការ និងបញ្ហាព្រំដែនកម្ពុជា-ថៃ យ៉ាងណាក្តី ខណៈដែលអនុវិស័យសំណង់នៅបន្តមានកំណើនទាប ។ ដោយឡែក ក្នុងឆ្នាំ ២០២៦, វិស័យឧស្សាហកម្ម រំពឹងថានឹងមានកំណើនថមថយ មកត្រឹមប្រមាណ ៦,៧% ដោយសារកំណើនថមថយជាងការរំពឹងទុកនៃអនុវិស័យសំណង់ ខណៈដែលអនុវិស័យកាត់ដេរ និងមិនមែនកាត់ដេរ នៅរក្សាបានស្ថិរភាពកំណើន ប៉ុន្តែមានសន្ទុះថមថយ ដោយសារមូលដ្ឋានខ្ពស់ពីឆ្នាំចាស់ (២០២៥) ។



**អនុវិស័យកាត់ដេរ** ត្រូវបានវាយតម្លៃថា មានកំណើនល្អ ក្នុងអត្រា ១២,៥% ក្នុងឆ្នាំ ២០២៥ បើទោះបីទទួលរងកម្មវិបាកពីការដាក់ឱ្យអនុវត្តពន្ធគយបដិការ របស់សហរដ្ឋអាម៉េរិកយ៉ាងណាក្តី ដែលជំរុញដោយការពន្លឿនការនាំចេញ (Front-loading) ក្នុងឆមាសទី១ ឆ្នាំ ២០២៥ ពោលគឺមុនអត្រាពន្ធគយផ្លូវការចូលជាធរមាន ។ បើទោះបីអត្រាពន្ធគយ ១៩% *(ដែលមានកម្រិតប្រហាក់ប្រហែលទៅនឹងបណ្តាប្រទេសក្នុងតំបន់)* ត្រូវបានដាក់ឱ្យអនុវត្តក្នុងអំឡុងខែ សីហា ឆ្នាំ ២០២៥, ការនាំចេញផលិតផលកាត់ដេរ ទៅសហរដ្ឋអាម៉េរិក ក៏នៅតែបន្តមាននិន្នាការល្អ ពិសេសក្នុងត្រីមាសទី៣ និងទី៤ ឆ្នាំ ២០២៥ ខណៈដែលទីផ្សារផ្សេងទៀត ដូចយ៉ាង សហភាពអឺរ៉ុប ក៏នៅតែមាននិន្នាការរឹងមាំផងដែរ ឆ្លុះបញ្ចាំងពីចលនការល្អនៃតម្រូវការសកល ជារួម ។ ជាក់ស្តែង, ការនាំចេញផលិតផលកាត់ដេរ ក្នុងឆ្នាំ ២០២៥ មានកំណើនប្រមាណ ១៦,៣% ស្របពេលដែលការនាំចូលវត្ថុធាតុដើមកាត់ដេរ ក៏កើនឡើងក្នុងអត្រា ៥,២% ដែលឆ្លុះបញ្ចាំងពីការបន្តសកម្មភាពផលិតកម្ម និងការនាំចេញក្នុងរយៈពេលខាងមុខ ។ សម្រាប់ឆ្នាំ ២០២៦, អនុវិស័យនេះ ក៏ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនល្អក្នុងអត្រា ៨,៦% ប៉ុន្តែមានសន្ទុះថមថយបើធៀបនឹងឆ្នាំ ២០២៥ ដោយសារ មូលដ្ឋានធំពីឆ្នាំចាស់ គួបផ្សំនឹងភាពមិនប្រាកដប្រជាខ្ពស់នៃតម្រូវសកល ។ ទោះជាយ៉ាងនេះក្តី, ក្នុងករណីដែលថានិន្នាការចម្បងៗមួយចំនួន ពិសេសរបបពាណិជ្ជកម្មសកល ពុំវិវត្តទៅក្នុងទិសដៅអវិជ្ជមានខ្លាំងជាងនេះបន្តទៀត ហើយកម្មវិបាកនៃសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា ពុំបង្កការប៉ះពាល់ធំដុំពេកដល់តម្រូវការសកល អនុវិស័យនេះនឹងបន្តរក្សាបានកំណើនដូចការគ្រោងទុក ដែលបន្តគាំទ្រដោយនិន្នាការល្អនៃតម្រូវការពីទីផ្សារសហរដ្ឋអាម៉េរិក ក៏ដូចជាការបន្តកើនឡើងនៃតម្រូវការពីទីផ្សារផ្សេងៗទៀត ពិសេសទីផ្សារក្នុងតំបន់អាស៊ាន ជាដើម ។



**អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ** ត្រូវបានវាយតម្លៃថាមានកំណើនថមថយបន្តិចក្នុងឆ្នាំ ២០២៥ ក្នុងរង្វង់ ៩,៨% ដោយសារផលប៉ះពាល់នៃបញ្ហាព្រំដែនកម្ពុជា-ថៃ មកលើផលិតកម្មថៃបូកមួយ និងមូលដ្ឋានផលិតកម្មដែលស្ថិតនៅជិតព្រំដែនកម្ពុជា-ថៃ ។ ទោះជាយ៉ាងនេះក្តី, សកម្មភាពផលិតកម្ម និងការនាំចេញផលិតផលកម្មន្តសាលមិនមែនកាត់ដេរ ជារួម ពិសេសគ្រឿងបង្គុំអេឡិចត្រូនិក, សំបកកង់រថយន្ត និងគ្រឿងសង្ហារិម ជាដើម នៅបន្តរក្សាបានចលនការល្អប្រសើរ ។ ជាក់ស្តែង, ការនាំចេញផលិតផលកម្មន្តសាលមិនមែនកាត់ដេរ មាន

កំណើនប្រមាណ ១៥,៧% ។ ជាមួយគ្នានេះ គួរបញ្ជាក់ផងដែរថា ឧស្សាហកម្មបម្រើដល់ទីផ្សារក្នុងស្រុកមួយចំនួន ពិសេសឧស្សាហកម្មផ្គុំ និងដំឡើងរថយន្ត ត្បិតត្រូវប្រឈមនឹងការរអាក់រអួលនៃការផ្គត់ផ្គង់វត្ថុធាតុដើមនៅពេលមានការបិទព្រំដែនគោកភ្លាមៗក៏ពិតមែន, ប៉ុន្តែបញ្ហាប្រឈមនេះ ក៏ត្រូវបានដោះស្រាយភ្លាមៗផងដែរ តាមរយៈការបង្វែរទិសដៅដឹកជញ្ជូន និងការផ្លាស់ប្តូរមធ្យោបាយដឹកជញ្ជូន (Re-routing) គួបផ្សំនឹងការជួយសម្រួលនីតិវិធី ពាក់ព័ន្ធនឹងបែបបទបញ្ចេញទំនិញគយ និងការកកស្ទះនៅតាមកំពង់ផែ ពីរាជរដ្ឋាភិបាល ។ ក្នុងឆ្នាំ ២០២៦, អនុវិស័យនេះ រំពឹងថានឹងបន្តរក្សាបានអត្រាកំណើនក្នុងរង្វង់ ៨,៥% ដោយសារការរំពឹងទុកនិន្នាការល្អនៃផលិតកម្មបម្រើការនាំចេញ ជាពិសេសទំនិញសក្តានុពលសំខាន់ៗ ដូចជា សំបកកង់រថយន្ត, គ្រឿងបង្គុំអេឡិចត្រូនិក និងគ្រឿងសង្ហារិម, ខណៈដែលផលិតកម្មសក្តានុពលទាំងនេះ ក៏បាននិងកំពុងពង្រីកច្រវាក់ផលិតកម្មរបស់ខ្លួនជាបន្តបន្ទាប់ ។ ដូចគ្នាទៅនឹងអនុវិស័យកាត់ដេរដែរ, ក្នុងករណីរបបពាណិជ្ជកម្មសកល ពុំវិវត្តទៅក្នុងទិសដៅអវិជ្ជមានខ្លាំងជាងនេះបន្តទៀត ហើយកម្មវិបាកនៃសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា ក៏ពុំបង្កការប៉ះពាល់ធំដុំដល់តម្រូវការសកល, នោះ អនុវិស័យនេះនឹងបន្តរក្សាបានកំណើនដូចការគ្រោងទុក ។



**អនុវិស័យសំណង់** ត្រូវបានវាយតម្លៃថាមានកំណើនក្នុងល្បឿនយឺតសម្រាប់ឆ្នាំ ២០២៥ ជាមួយនឹងអត្រាកំណើន ក្នុងរង្វង់ ១,៣% ដែលបន្តគាំទ្រដោយសំណង់លំនៅឋានតម្លៃសមរម្យ ឆ្លើយតបទៅនឹងតម្រូវការពិតក្នុងស្រុក (Real demand), និងសំណង់បម្រើឱ្យវិស័យឧស្សាហកម្ម ដូចជា រោងចក្រ និងឃ្លាំងទំនិញ ជាដើម ។ ស្ថិតក្នុងដំណាក់កាលនៃការកែតម្រូវទីផ្សារ សំណង់លំនៅឋានតម្លៃសមរម្យ នៅបន្តមានសកម្មភាព ប៉ុន្តែក្នុងល្បឿនយឺត និងក្នុងទ្រង់ទ្រាយតូច បានសេចក្តីថា ក្រុមហ៊ុនអភិវឌ្ឍន៍ ធ្វើការសាងសង់សម្រាប់តែឆ្លើយតបទៅនឹងតម្រូវរបស់ប្រជាជនក្នុងស្រុក ជាពិសេសសម្រាប់ប្រជាជនវ័យជំទង់ដែលមានតម្រូវការជម្រក ។ គួរបញ្ជាក់ថា, ក្នុងពេលកន្លងមក ការបន្តអនុវត្ត វិធានការ ៨ ចំណុច ក៏នៅតែដើរតួនាទីយ៉ាងសំខាន់, *ម្ខាង,* រក្សាលំនឹងអាជីវកម្មរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ ផង, *និងម្ខាងទៀត,* ជំរុញសកម្មភាពតម្រូវការឱ្យងើបឡើងវិញជាបណ្តើរៗ ផង ។ ជាមួយគ្នានេះ, សំណង់បម្រើឱ្យវិស័យឧស្សាហកម្ម ក៏មាននិន្នាការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំផងដែរ ឆ្លុះបញ្ចាំងពីការបន្តនិន្នាការកើនឡើងនៃលំហូរវិនិយោគក្នុងវិស័យផលិតកម្ម ជាពិសេសវិស័យកម្មន្តសាលមិនមែនកាត់ដេរ ។ ក្នុងឆ្នាំ ២០២៦ អនុវិស័យនេះ រំពឹងថានឹងបន្តថមថយ ក្នុងអត្រា ០,៧% ដោយសារបច្ច័យជាអវិជ្ជមាននៃភាពមិនប្រាកដប្រជា នៃកត្តាសេដ្ឋកិច្ច និងផលវិបាកនៃការបង្ក្រាបនិងទប់ស្កាត់សកម្មភាពឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ក្នុងរយៈពេលខ្លី មកលើទំនុកចិត្តវិនិយោគិន ដែលអាចបន្តចំបង្អាក់ដល់សកម្មភាពសាងសង់ និងតម្រូវការ, ប៉ុន្តែ ជារួមអនុវិស័យនេះនៅបន្តទ្រទ្រង់ដោយសំណង់លំនៅឋានតម្លៃសមរម្យ និងសំណង់បម្រើឱ្យឧស្សាហកម្ម ។ ជាមួយគ្នានេះ ការបន្តអនុវត្តវិធានការ ៨ ចំណុច រហូតដល់ដំណាច់ឆ្នាំ ២០២៦ ក៏រំពឹងថានឹងជួយគាំពារដល់អនុវិស័យនេះ ផងដែរ ។

**អនុវិស័យផលិតកម្មម្ហូបអាហារ និង អនុវិស័យផលិតកម្មភេសជ្ជៈ និងថ្នាំជក់** ត្រូវបានវាយ-តម្លៃថាសម្រេចបានកំណើន ៤,៦% និង ៣,២% រៀងគ្នា ក្នុងឆ្នាំ ២០២៥ គាំទ្រដោយនិន្នាការល្អនៃសកម្មភាពចាយ និងប្រើប្រាស់ក្នុងស្រុក គួបផ្សំនឹងនិន្នាការនៃការងាកមកគាំទ្រផលិតផលក្នុងស្រុក ដែលបានចូលរួមលើកកម្ពស់សកម្មភាពផលិតក្នុងស្រុក ។ សម្រាប់ឆ្នាំ ២០២៦, អនុវិស័យផលិតកម្មម្ហូបអាហារ និង អនុវិស័យផលិតកម្មភេសជ្ជៈ និងថ្នាំជក់ ត្រូវបានប៉ាន់ស្មានថានឹងសម្រេចបានកំណើនវិជ្ជមាន ក្នុងអត្រា ៤,២% និង ២,៥% រៀងគ្នា ដោយសារការបន្តនិន្នាការកើនឡើងនៃសកម្មភាពផលិតកម្ម បម្រើតម្រូវការក្នុងស្រុក គួបផ្សំនឹងការពង្រីក និងពង្រឹងសមត្ថភាពផលិតកម្មបន្ថែមទៀត សំដៅឆ្លើយតបទៅនឹងនិន្នាការនៃការងាកមកគាំទ្រ និងប្រើប្រាស់ផលិតផលក្នុងស្រុក ។ លើសពីនេះ, ឆ្លើយតបទៅនឹងការងាកមកគាំទ្រផលិតផលខ្មែរ ដើម្បីលើកកម្ពស់ការផលិតក្នុងស្រុក និងក្នុងគោលដៅជំនួសការនាំចូលទំនិញពីបរទេស រាជរដ្ឋាភិបាលបានកំណត់មុខទំនិញកសិកម្ម និងកសិ-ឧស្សាហកម្ម អាទិភាព ចំនួន ៩ មុខ និងមុខទំនិញឧស្សាហកម្មអាទិភាព សម្រាប់ជំរុញផលិតកម្មក្នុងស្រុក និងជំនួសការនាំចូលចំនួន ២ ក្រុមមុខទំនិញ ដើម្បីត្រៀមរៀបចំក្របខ័ណ្ឌគោលនយោបាយ ជាកញ្ចប់ជំរុញផលិតកម្ម នៃមុខទំនិញទាំងនេះ ។ ជារួម, ការគិតគូររៀបចំក្របខ័ណ្ឌគោលនយោបាយនេះ នឹងក្លាយជាចលករ យ៉ាងសំខាន់ ក្នុងការចាប់ផ្តើមជំរុញ និងគាំពារកំណើនអនុវិស័យនេះ ។

## ■ វិស័យសេវាកម្ម

**វិស័យសេវាកម្ម** ត្រូវបានវាយតម្លៃថាមានកំណើនថមថយ ក្នុងឆ្នាំ ២០២៥ កន្លងទៅ ក្នុងអត្រាកំណើន ៣,៣% ដោយសារកំណើនថមថយនៃអនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ (ទេសចរណ៍) និងវិស័យអចលនទ្រព្យ ដោយសារកម្មវិបាកនៃបញ្ហាព្រំដែនកម្ពុជា-ថៃ, ប៉ុន្តែអនុវិស័យលក់ដុំ-រាយ នៅបន្តរក្សានិន្នាការរឹងមាំ ។ ក្នុងឆ្នាំ ២០២៦, វិស័យសេវាកម្ម នឹងបន្តថមថយបន្ថែមទៀត ក្នុងអត្រាកំណើន ២,៦% ដោយនិន្នាការធ្លាក់ចុះនៃអនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ និងកំណើនថមថយនៃអនុវិស័យលក់ដុំ-រាយ និងអចលនទ្រព្យ ដែលបង្កឡើងនូវឥទ្ធិពលផ្សេងៗគ្នា តួយ៉ាងកម្មវិបាកនៃសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា, ការបង្ក្រាប និងទប់ស្កាត់សកម្មភាពឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងឥទ្ធិពលសាយភាយនៃបញ្ហាព្រំដែនកម្ពុជា-ថៃ ។

**អនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ** ត្រូវបានវាយតម្លៃថាមានការថមថយ ក្នុងអត្រាកំណើន ២,១% សម្រាប់ឆ្នាំ ២០២៥ ដោយសារកម្មវិបាកនៃការបិទព្រំដែនគោកកម្ពុជា-ថៃ និងការបន្តអូសបន្លាយនៃភាពតានតឹងតាមបណ្តោយព្រំដែន មកលើលំហូរទេសចរអន្តរជាតិ, ប៉ុន្តែកំណើនជារួមនៅបន្តទ្រទ្រង់ដោយនិន្នាការល្អនៃទេសចរក្នុងស្រុក ។ ជាក់ស្តែង, ក្នុងឆ្នាំ ២០២៥ ចំនួនទេសចរអន្តរជាតិ បានធ្លាក់ចុះមកត្រឹម ៥,៥៧ លាននាក់ ដែលធ្លាក់ចុះប្រមាណ -១៦,៩% ខណៈដែលចំនួនទេសចរជាតិ បានកើនដល់ប្រមាណ ២៥ លាននាក់ ក្នុងឆ្នាំ ២០២៥, *ម្ខាង,* ដោយសារការងាកមកគាំទ្រការធ្វើដំណើរកម្សាន្តក្នុងស្រុក និង, *ម្ខាងទៀត,* ការជំរុញការធ្វើដំណើរក្នុងរដូវកាលបៃតង (Green season) របស់ក្រសួងទេសចរណ៍ ។ ក្នុងឆ្នាំ ២០២៦ អនុវិស័យនេះ ត្រូវបានរំពឹងថានឹងធ្លាក់ ក្នុង

អត្រា -០,១% ដោយសារការរំពឹងទុកពីការថមថយយ៉ាងគំហុកនៃលំហូរទេសចរអន្តរជាតិ ដែលសុទ្ធសឹងជាបច្ច័យអវិជ្ជមាននៃការបិទខ្ទប់ព្រំដែនគោកកម្ពុជា-ថៃ, ខណៈដែលសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា ក៏បានប៉ះពាល់ដល់ទំនុកចិត្តក្នុងការធ្វើដំណើររបស់ទេសចរ ទាំងអន្តរជាតិ និងក្នុងស្រុក ហើយការកើននៃថ្លៃប្រេងឥន្ធនៈសកល ធ្វើឱ្យថ្លៃធ្វើដំណើរ និងចំណាយផ្សេងៗ កើនជាគំហុក ។

**អនុវិស័យអចលនទ្រព្យ** ត្រូវបានវាយតម្លៃថាបន្តមានកំណើនយឺតក្នុងឆ្នាំ ២០២៥ ក្នុងអត្រា ១,១% ដោយសារការបន្តថមថយចរន្តទិញ-លក់ និងជួលអចលនវត្ថុថ្លៃខ្ពស់, ប៉ុន្តែកំណើនជារួមត្រូវបានគាំទ្រ ដោយសកម្មភាពទិញ-លក់ និងជួលអចលនវត្ថុថ្លៃសមរម្យ ពោលទាំងលំនៅឋាន និងខុនដូ ស្របពេលដែលការជួលឃ្លាំង និងដី បម្រើឱ្យវិស័យឧស្សាហកម្ម ក៏នៅបន្តមាននិន្នាការល្អ ។ ការបន្តអនុវត្តវិធានការ ៨ ចំណុច ក៏បានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការលើកកម្ពស់ចរន្តទិញ-លក់ ជារួមផងដែរ ។ ក្នុងឆ្នាំ ២០២៦ អនុវិស័យនេះមាននិន្នាការថមថយ ដោយរំពឹងថាមានកំណើន ក្នុងអត្រា ០,៦% ដោយសារកម្មវិបាកជាអវិជ្ជមាននៃភាពមិនប្រាកដប្រជានៃកត្តាសេដ្ឋកិច្ច និងផលវិបាកនៃការបង្ក្រាប និងទប់ស្កាត់សកម្មភាពឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ក្នុងរយៈពេលខ្លី មកលើសកម្មភាពទិញ-លក់ ជារួម ពិសេសអគារការិយាល័យ និងអគារប្រើប្រាស់ចម្រុះ (Mixed-use building) ។ ទោះជាយ៉ាងនេះក្តី, ការបន្តអនុវត្តវិធានការ ៨ ចំណុច ពិសេសការលើកលែងពន្ធប្រថាប់ត្រាចំពោះការទិញ-លក់ និងផ្ទេរកម្មសិទ្ធិលំនៅឋាន មានតម្លៃក្រោម ២១ ម៉ឺនដុល្លារអាមេរិក ក៏រំពឹងថាជួយគាំពារកំណើនអនុវិស័យនេះ ។

**អនុវិស័យលក់ដុំ-រាយ** ត្រូវបានវាយតម្លៃថាមានកំណើនល្អ ក្នុងអត្រា ៣,៩% ក្នុងឆ្នាំ ២០២៥ គាំទ្រដោយនិន្នាការរឹងមាំនៃសកម្មភាពចាយវាយ និងប្រើប្រាស់ក្នុងស្រុក ពោលទាំងផ្នែកម្ហូបអាហារ និងមិនមែនម្ហូបអាហារ និងទំនិញប្រណីត ជាដើម ពិសេសរថយន្ត ។ សម្រាប់ឆ្នាំ ២០២៦, អនុវិស័យនេះ នឹងមាននិន្នាការថមថយ ក្នុងអត្រា ២,០% ដោយសារការរំពឹងទុកការកាត់បន្ថយចំណាយ ឬការចាយវាយប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ (Precautionary) លើទំនិញមិនចាំបាច់ និងទំនិញប្រណីត ក្នុងកាលៈទេសៈនៃការកើនសម្ពាធអតិផរណា ដែលភាពមិនប្រាកដប្រជានៃកត្តាសេដ្ឋកិច្ច ពិសេសបង្កឡើងដោយសង្គ្រាមក្នុងតំបន់មជ្ឈិមបូព៌ា គួបផ្សំនឹងការរំពឹងទុកនៃបច្ច័យអវិជ្ជមាននៃការធ្លាក់ចុះប្រាក់បង្វែរឯកជន និងកម្មវិបាកការបង្ក្រាបសកម្មភាពឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ។ ទោះជាយ៉ាងនេះក្តី, សកម្មភាពចាយ និងប្រើប្រាស់ទំនិញចាំបាច់ នៅបន្តមាននិន្នាការល្អ ពិសេសជំរុញដោយការចូលរួមគាំទ្រ និងប្រើប្រាស់ផលិតផលក្នុងស្រុក ។

**អនុវិស័យដឹកជញ្ជូន និងស្តុក** ត្រូវបានវាយតម្លៃថាបន្តសម្រេចបានកំណើនល្អ ក្នុងអត្រា ៤,៧% ក្នុងឆ្នាំ ២០២៥ ដែលបន្តគាំទ្រដោយការដឹកជញ្ជូនបម្រើឱ្យវិស័យបម្រើការនាំចេញ គួបផ្សំនឹងការបន្តនិន្នាការល្អនៃការដឹកជញ្ជូនបញ្ញើរហ័សក្នុងស្រុក ។ គួរបញ្ជាក់ថា, បើទោះបីការដឹកជញ្ជូន ជាពិសេសវត្ថុធាតុដើមផលិតកម្ម មានការរអាក់រអួលដោយសារបញ្ហាព្រំដែន

កម្ពុជា-ថៃ យ៉ាងណាក្តី, ក៏សកម្មភាពដឹកជញ្ជូន ជារួមនៅតែបន្តមានចលនការល្អ ជំរុញដោយការបង្វែរទិសដៅដឹកជញ្ជូន (Re-routing) និងការផ្លាស់ប្តូរមធ្យោបាយដឹកជញ្ជូនពិសេសតាមផ្លូវទឹក និងផ្លូវអាកាស ។ ជាក់ស្តែង, បរិមាណកុងតឺន័រឆ្លងកាត់កំពង់ផែទាំងពីរ បន្តកើនឡើងដល់ប្រមាណ ១,៩៤ លានកុងតឺន័រ (TEU) ជាមួយអត្រាកំណើន ២៨,៨% ។ សម្រាប់ឆ្នាំ ២០២៦ អនុវិស័យនេះ រំពឹងថាមានកំណើនថមថយបន្តិច ប៉ុន្តែនៅរក្សាបាននិន្នាការវិជ្ជមាន ក្នុងអត្រា ៤,៥% ដែលគាំទ្រដោយនិន្នាការល្អនៃវិស័យបម្រើការនាំចេញ គួបផ្សំនឹងការបន្តពង្រីក និងពង្រឹងសមត្ថភាពផ្ទុក និងចរាចរណ៍ទំនិញនៅតាមកំពង់ផែទាំងពីរ, ស្របពេលដែលការដឹកជញ្ជូនបញ្ញើរហ័ស ក៏នៅបន្តរក្សាបាននិន្នាការល្អ ។ ការកើនថ្លៃប្រេងឥន្ធនៈ ក៏បង្កផលប៉ះពាល់ដល់សកម្មភាព និងប្រាក់ចំណេញរបស់ក្រុមហ៊ុនដឹកជញ្ជូនផងដែរ ដែលធ្វើឱ្យមានការកាត់បន្ថយនូវចំនួនជើងនៃការដឹកជញ្ជូន ពិសេសការដឹកជញ្ជូនបញ្ញើរហ័សក្នុងស្រុក, ប៉ុន្តែការដឹកជញ្ជូន ពិសេសទំនិញបម្រើការនាំចេញ នៅបន្តរក្សាបាននិន្នាការល្អ ដែលចូលរួមគាំទ្រដល់អនុវិស័យនេះ ជារួម ។

**អនុវិស័យបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍** ត្រូវបានវាយតម្លៃថាបន្តមានកំណើនល្អក្នុងឆ្នាំ ២០២៥ ក្នុងអត្រា ៥,៧% ដែលបន្តគាំទ្រដោយការបន្តកើនឡើងនៃការប្រើប្រាស់អ៊ីនធឺណិត ស្របពេលដែលការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រ គួយ៉ាង ការវិនិយោគលើបង្គោលសេវាទូរស័ព្ទ ជាដើម គួបផ្សំនឹងការបន្តធ្វើទំនើបកម្មលើប្រព័ន្ធប្រតិបត្តិការផ្តល់សេវាឌីជីថល ទាំងក្នុងវិស័យសាធារណៈ និងឯកជន ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងបរិការណ៍ឌីជីថលូបនីយកម្ម ។ ក្នុងឆ្នាំ ២០២៦, អនុវិស័យនេះ ត្រូវបានរំពឹងថានឹងនៅបន្តរក្សាបានចលនការល្អ ក្នុងអត្រា ៥,១% គាំទ្រដោយការបន្តកើនឡើងនៃការចាប់យក និងធ្វើបរិវត្តកម្មឌីជីថលនៅកម្ពុជា ពោលទាំងផ្នែកតម្រូវការ *(ការបន្តចាប់យក និងប្រើប្រាស់ឌីជីថលជាមធ្យោបាយក្នុងការទំនាក់ទំនង និងជាថ្នាលអាជីវកម្ម)* និងផ្នែកផ្គត់ផ្គង់ *(ការពង្រីកហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដើម្បីឆ្លើយតបទៅនឹងនិន្នាការកើនឡើងនៃតម្រូវការ)* ។ ជាមួយគ្នានេះ, ការដាក់ឱ្យដំណើរការប្រព័ន្ធ 5G ក៏នឹងជំរុញតម្រូវការ និងការវិនិយោគ ដែលជាចលករជំរុញកំណើននៃអនុវិស័យនេះ ។

**អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង** ត្រូវបានវាយតម្លៃថាមានកំណើនវិជ្ជមានក្នុងឆ្នាំ ២០២៥ ជាមួយអត្រាកំណើនទាបក្នុងរង្វង់ ១,១% ដោយសារការងើបឡើងវិញនៃប្រាក់ចំណូលរបស់គ្រឹះស្ថានធនាគារ ខណៈដែលសម្ពាធនៃកំណើនចំណាយការប្រាក់ និងប្រតិបត្តិការបានធ្លាក់ទាបបន្តិចម្តងៗ ដោយសារ ការបន្តបន្ធូរបន្ថយគោលនយោបាយរឹតបន្តឹងរូបិយវត្ថុសកល គួបផ្សំនឹងការងើបត្រលប់មកវិញក្នុងល្បឿនយឺតនៃការបញ្ចេញឥណទានថ្មី ។ ជាមួយគ្នានេះ អនុវិស័យធានារ៉ាប់រង ក៏នៅបន្តរក្សាស្ថិរភាពកំណើន ដែលបន្តគាំទ្រដោយការធានារ៉ាប់រងទូទៅ និងធានារ៉ាប់រងសុខភាព ។ ក្នុងឆ្នាំ ២០២៦, អនុវិស័យនេះ រំពឹងថានឹងមានកំណើនយឺត ក្នុងអត្រា ០,៥% ក្រោមការរំពឹងទុកបច្ច័យនៃភាពមិនប្រាកដប្រជានៃកត្តាសេដ្ឋកិច្ច មកលើតម្រូវការឥណទានថ្មីៗ គួបផ្សំនឹងសម្ពាធនៃការបន្តកើននៃឥណទានមិនដំណើរការ (NPL) ។

## ■ វិស័យកសិកម្ម

**វិស័យកសិកម្ម** ក្នុងឆ្នាំ ២០២៥ ត្រូវបានវាយតម្លៃថាសម្រេចបានកំណើនល្អ ក្នុងអត្រា ១,២% គាំទ្រដោយកំណើនល្អនៃអនុវិស័យដំណាំ និងអនុវិស័យនេសាទ ខណៈដែលអនុវិស័យចិញ្ចឹមសត្វ ក៏នៅតែបន្តរក្សាស្ថិរភាពកំណើន ។ ដោយឡែក ក្នុងឆ្នាំ ២០២៦, វិស័យកសិកម្ម រំពឹងថានឹងមានកំណើនថមថយ ក្នុងអត្រា ០,៧% ដោយសារនិន្នាការថមថយនៃគ្រប់អនុវិស័យគាំទ្រកំណើន ។



**អនុវិស័យដំណាំ** ត្រូវបានវាយតម្លៃថាបន្តសម្រេចបានកំណើនល្អ ក្នុងអត្រា ១,៤% ក្នុងឆ្នាំ ២០២៥ បើទោះបីទទួលរងនូវកម្មវិបាកនៃការធ្លាក់ថ្លៃកសិផល និងការប៉ះទង្គិចនៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃយ៉ាងណាក្ដី, ដោយសារកំណើនល្អនៃផលិតកម្មស្រូវ ក៏ដូចជាដំណាំសាកវប្បកម្ម និងឧស្សាហកម្មផ្សេងទៀត ពិសេសស្វាយចន្ទី និង ដំឡូងមី ជាដើម ។ ត្បិតថ្លៃកសិផលអន្តរជាតិ មាននិន្នាការធ្លាក់ចុះ ពិសេសចាប់ពីឆមាសទី២ ឆ្នាំ ២០២៥ ហើយភាពតានតឹងនៅតាមព្រំដែន ក៏បានបង្កផលប៉ះពាល់ដល់ការប្រមូលផល និងលទ្ធភាពបង្កបង្កើនផល, ប៉ុន្តែទំហំផលិតកម្មនៃទំនិញសំខាន់ៗទាំងនេះ ក៏ដូចជាការនាំចេញកសិផលរបស់កម្ពុជា នៅបន្តរក្សាបាននិន្នាការល្អ ដោយសារការបង្កើនការដាំដុះ និងបរិមាណផលិតកម្ម ក្នុងឆមាសទី១ ឆ្នាំ ២០២៥ ។ ទន្ទឹមនេះ ឆ្លើយតបទៅនឹងបញ្ហាបិទខ្ទប់ព្រំដែនគោកកម្ពុជា-ថៃ, រាជរដ្ឋាភិបាល ក៏បានដាក់ចេញវិធានការអន្តរាគមន៍បន្ទាន់ចំពោះមុខ តាមរយៈការជំរុញលើកទឹកចិត្តរោងចក្រ និងក្រុមហ៊ុនកែច្នៃ ដើម្បីស្រូបយកទំនិញកសិកម្មក្នុងស្រុក ពិសេសដំឡូងមី និងពោតក្រហម សំដៅបញ្ចៀសការជន់គរកសិផល និងខិតខំបង្ការការធ្លាក់ចុះគំហុកនៃថ្លៃកសិផល ។ យ៉ាងណាមិញ, ក្នុងឆ្នាំ ២០២៦ អនុវិស័យនេះ ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនយឺត ក្នុងអត្រា ០,៨% ដោយសារការរំពឹងទុកការថមថយបរិមាណផលិតកម្ម ដែលបណ្ដាលមកពីនិន្នាការធ្លាក់ចុះនៃថ្លៃកសិផលជារួម និង កម្មវិបាកនៃបញ្ហាព្រំដែនមកលើលទ្ធភាព និងសមត្ថភាពបង្កបង្កើនផល គួបផ្សំនឹងការកើនថ្លៃប្រេងឥន្ធនៈ និងថ្លៃដើមធាតុចូលកសិកម្ម (Input cost) ដែលអាចប៉ះពាល់ដល់សមត្ថភាពផលិតកម្ម ។ ទោះជាយ៉ាងនេះក្ដី, ការបន្តអនុវត្តនូវ **«កម្មវិធីធានាស្ថិរភាពថ្លៃកសិផល»**, **«សហគមន៍កសិកម្មទំនើប»** និងការជំរុញលើកកម្ពស់ផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្ម តាមរយៈការរៀបចំ និងអនុវត្ត **«កម្មវិធីលើកកម្ពស់ផលិតកម្ម ការកែច្នៃ សម្រាប់ជំនួសការនាំចូល និងជំរុញការនាំចេញ ក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ឆ្នាំ ២០២៦-២០២៨ លើមុខដំណាំពោត បន្លែ និងដំឡូងមី»** ក៏នឹងចូលរួមជំរុញសកម្មភាពផលិតកម្ម និងគាំទ្រដល់កំណើននៃអនុវិស័យ នេះ ជារួម ។



**អនុវិស័យចិញ្ចឹមសត្វ** ត្រូវបានវាយតម្លៃថានៅរក្សាបានកំណើនវិជ្ជមាន ក្នុងអត្រា ០,៩% ក្នុងឆ្នាំ ២០២៥ ដោយសារការរក្សាបាននូវស្ថិរភាពផលិតកម្ម ឆ្លើយតបទៅនឹងតម្រូវការក្នុងស្រុក គួបផ្សំនឹងការបន្តអនុវត្តវិធានការទប់ស្កាត់ការនាំចូលសាច់បង្កក សំដៅលើកកម្ពស់ផលិតកម្មក្នុងស្រុក ។ ក្នុងឆ្នាំ ២០២៦ អនុវិស័យនេះ ក៏រំពឹងថានឹងរក្សាបានកំណើនវិជ្ជមាន ក្នុងអត្រា ០,៤% ដោយសារការបន្តរក្សាបានចលនការផលិតកម្ម ឆ្លើយតបទៅនឹងនិន្នាការកើនឡើងនៃ

ការប្រើប្រាស់ក្នុងស្រុក គួបផ្សំនឹងការយកចិត្តទុកដាក់ខ្ពស់លើវិធានការអន្តរាគមន៍ និងបទប្បញ្ញត្តិ ពិសេសពាក់ព័ន្ធនឹងការនាំចូលសាច់បង្កក ដើម្បីលើកកម្ពស់ផលិតកម្មក្នុងស្រុក ។

**អនុវិស័យនេសាទ** ត្រូវបានវាយតម្លៃថានៅបន្តមានកំណើនល្អក្នុងឆ្នាំ ២០២៥ ក្នុងអត្រា ១,៦% ដែលជំរុញដោយសារកំណើនល្អនៃផលចាប់ទឹកសាប ដោយសារភាពអំណោយផលនៃអាកាសធាតុ និងកម្រិតល្អនៃកម្ពស់ទឹកទន្លេ និងការបន្តស្តារឡើងវិញនៃជម្រកធម្មជាតិ ក្រោមកិច្ចខិតខំប្រឹងប្រែងបង្ក្រាបបទល្មើសនេសាទ ។ ក្នុងឆ្នាំ ២០២៦, អនុវិស័យនេះ រំពឹងថានឹងបន្តមានកំណើនថមថយ ក្នុងអត្រា ០,៩% ដោយសារមូលដ្ឋានធំពីឆ្នាំចាស់ផង និងម្ខាងទៀត ដោយសារផលប៉ះពាល់នៃការកើនថ្លៃប្រេង មកលើសកម្មភាពនេសាទ ពិសេសលើផលចាប់ទឹកសាប, ប៉ុន្តែជារួមទំហំផលិតកម្ម នៅបន្តរក្សាបាននិន្នាការវិជ្ជមាន ។

## អតិផរណា និងអត្រាប្តូរប្រាក់

អត្រាអតិផរណា (មធ្យមប្រចាំឆ្នាំ) បន្តស្ថិតក្នុងអត្រាទាប និងគ្រប់គ្រងបានក្នុងអត្រា ២,៦% ក្នុងឆ្នាំ ២០២៥ ឆ្លុះបញ្ចាំងពីនិន្នាការល្អនៃតម្រូវការក្នុងស្រុក (ផ្នែកតម្រូវការ) និងការបន្តរក្សាបានស្ថិរភាពនៃថ្លៃទំនិញអន្តរជាតិ ជាពិសេសថ្លៃប្រេងឥន្ធនៈ (ផ្នែកផ្គត់ផ្គង់) ។ ក្នុងឆ្នាំ ២០២៥, អត្រាប្តូរប្រាក់ផ្លូវការ ក៏បន្តវិលត្រលប់ទៅប្រក្រតីភាព ក្នុងរង្វង់ប្រមាណ ៤ ០១១ រៀល/ដុល្លារអាម៉េរិក ដោយសារការបន្តបន្ធូរបន្ថយគោលនយោបាយរឹតបន្តឹងរូបិយវត្ថុសកល គួបផ្សំនឹងការបន្តអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជា ក្នុងការធានាស្ថិរភាពអត្រាប្តូរប្រាក់ ។ ក្នុងឆ្នាំ ២០២៦, អត្រាអតិផរណា ត្រូវបានប៉ាន់ស្មានថា កើនក្នុងអត្រា ៣,៨% ដោយសារនិន្នាការកើននៃថ្លៃប្រេងឥន្ធនៈ ជាបច្ច័យនៃសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា ។ ទោះជាយ៉ាងនេះក្តី អត្រាប្តូរប្រាក់ផ្លូវការ ក៏រំពឹងថានៅបន្តមានស្ថិរភាព ក្នុងរង្វង់ប្រមាណ ៤ ០២៩ រៀល/ដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០២៦ ដោយសារការបន្តអនុវត្តគោលនយោបាយរូបិយវត្ថុគាំពារកំណើន និងធានាស្ថិរភាពថ្លៃ ជារួម ។

## វិស័យខាងក្រៅ

សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរ) ត្រូវបានប៉ាន់ស្មានថាមានឱនភាព ក្នុងអត្រាប្រមាណ -៣,៦% នៃ ផ.ស.ស. ឆ្លុះបញ្ចាំងពីការវិលទៅរកប្រក្រតីភាពវិញនៃគណនីចរន្ត ពិសេសការបន្តនិន្នាការល្អនៃការនាំចេញ-នាំចូល ។ ក្នុងនោះ, ការនាំចេញនៅបន្តមានចលនការល្អប្រសើរ ដែលបន្តគាំទ្រដោយកំណើនល្អនៃការនាំចេញផលិតផលកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ខណៈដែលការនាំចូលក៏បន្តមាននិន្នាការល្អប្រសើរ គាំទ្រដោយការនាំចូលវត្ថុធាតុដើមសម្រាប់ផលិតកម្ម, សម្ភារសំណង់ យានយន្ត និងទំនិញប្រើប្រាស់ផ្សេងទៀត ។ ប៉ុន្តែ, ចំណូលពីវិស័យទេសចរណ៍ មាននិន្នាការថមថយ ដោយសារបច្ច័យអវិជ្ជមាននៃការបិទខ្ទប់ច្រកព្រំដែនគោក និងភាពតានតឹងនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ។ ជាមួយគ្នានេះ, ចំណូលបន្ទាប់បន្សំ (Secondary incomes) ក៏មាននិន្នាការថមថយផងដែរ ដោយសារការធ្លាក់ចុះនៃប្រាក់បង្វែរឯកជន បណ្តាលមកពីការវិលត្រលប់មកវិញនៃទេសន្តប្រវេសន៍កម្ពុជាពីប្រទេសថៃ ក្នុងអំឡុងឆមាសទី២ ឆ្នាំ ២០២៥, ដែលការណ៍នេះធ្វើឱ្យកម្រិតនៃឱនភាពគណនីចរន្ត ជារួម មានទំហំធំជាងការរំពឹងទុក ។ វំហូរវិនិយោគផ្ទាល់ពីបរទេស បន្តមាននិន្នាការរឹងមាំ ក្នុងអត្រាកំណើន ១៦,៩% ឬ ប្រមាណ ១០,០% នៃ ផ.ស.ស. ដែលទ្រទ្រង់ដោយវំហូរវិនិយោគ

ក្នុងវិស័យកម្មន្តសាលកាត់ដេរ និងមិនមែនកាត់ដេរ ។ ការណ៍នេះ ធ្វើឱ្យទុនបម្រុងអន្តរជាតិបន្តកើនឡើង ក្នុងទំហំប្រមាណ ២៧ ៥៣០ លានដុល្លារអាមេរិក ឬប្រមាណ ៩,៨ ខែ នៃការនាំចូល ។

ក្នុងឆ្នាំ ២០២៦, សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរ) រំពឹងថានឹងបន្តមានឱនភាពក្នុងទំហំធំប្រមាណ -៧,៤% នៃ ផ.ស.ស. ដោយសារការរំពឹងទុកការថមថយនៃសកម្មភាពពាណិជ្ជកម្មអន្តរជាតិ ដែលស្របគ្នាទៅនឹងនិន្នាការថមថយនៃសន្ទុះកំណើនសេដ្ឋកិច្ច ។ ក្នុងនោះ ការនាំចេញអាចនឹងមានកំណើនថមថយ, *ម្ខាង,* ដោយសារមូលដ្ឋានខ្ពស់ពីឆ្នាំ ២០២៥ និងដោយសារការរំពឹងទុកការថមថយនិន្នាការនៃការនាំចេញ ជារួមផង ពិសេសផ្នែកកសិផល ដោយសារកត្តាថ្លៃអន្តរជាតិ ។ ជាមួយគ្នានេះ, ការនាំចូលក៏រំពឹងថាមានការថមថយផងដែរ ពិសេសលើទំនិញប្រណីត តួយ៉ាង រថយន្ត និងគ្រឿងសម្អាងសំណង់ ជាដើម ។ ទន្ទឹមនេះ, ចំណូលបន្ទាប់បន្សំ ក៏បន្តមាននិន្នាការថមថយ ដោយសារការបន្តធ្លាក់ចុះនៃប្រាក់បង្វែរឯកជន ត្បិតទេសន្តរប្រវេសន៍ដែលវិលមកកម្ពុជាវិញ ក៏ពុំទាន់អាច ឬពុំវិលត្រលប់ទៅប្រទេសថៃវិញតែម្តង ។ ជាមួយគ្នានេះ, ចំណូលពីវិស័យទេសចរណ៍ ក៏រំពឹងថានឹងមានការធ្លាក់ចុះផងដែរ ដោយសារនិន្នាការថមថយនៃលំហូរទេសចរអន្តរជាតិ ។ ទោះជាយ៉ាងនេះក្តី, លំហូរវិនិយោគផ្ទាល់ពីបរទេស រំពឹងថានឹងនៅតែបន្តមាននិន្នាការរឹងមាំ ជាមួយនឹងអត្រាកំណើនក្នុងរង្វង់ប្រមាណ ៨,៤% ឬប្រមាណ ១០,២% នៃ ផ.ស.ស. ដែលនៅតែបន្តគាំទ្រដោយលំហូរវិនិយោគក្នុងវិស័យកម្មន្តសាលកាត់ដេរ និងមិនមែនកាត់ដេរ ។ ក្នុងន័យនេះ, ទុនបម្រុងអន្តរជាតិ បន្តពូនគរដល់ប្រមាណ ២៩ ១៦៩ លានដុល្លារអាមេរិក ឬ ប្រមាណ ៨,២ ខែនៃការនាំចូល ។

## ■ វិស័យហិរញ្ញវត្ថុ

វិស័យហិរញ្ញវត្ថុ មានការប្រែប្រួលគួរឱ្យកត់សម្គាល់ គិតចាប់តាំងពីការធ្លាក់ចុះនូវសន្ទុះកំណើនសេដ្ឋកិច្ចដោយវិបត្តិជំងឺកូវីដ-១៩, ការថមថយសកម្មភាពពាណិជ្ជកម្ម និង ការវិនិយោគ ក្នុងឆ្នាំ ២០២៣ ដោយសារការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុសកល ឆ្លើយតបទៅនឹងសម្ពាធអតិផរណា, និងក្នុងពេលថ្មីៗ នេះ ផលជះនៃការបិទខ្ទប់ និងភាពតានតឹងតាមព្រំដែនកម្ពុជា-ថៃ ជាដើម ។ **វិស័យហិរញ្ញវត្ថុធនាគារ បានផ្លាស់ប្តូរពីស្ថានភាពដែលឥណទានមានសន្ទុះកំណើនខ្ពស់ និង អត្រាឥណទានមិនដំណើរការទាប មកក្នុងស្ថានភាពថ្មី ដែលឥណទានមានកំណើនទាប និងឥណទានមិនដំណើរការបន្តកើនឡើងជាលំដាប់** ។ ជាក់ស្តែង, ក្នុងឆ្នាំ ២០២៥ ឥណទានដែលបានផ្តល់ដោយប្រព័ន្ធធនាគារបានបង្ហាញសញ្ញាណងើបឡើងក្នុងអត្រា ៥,៤% បើធៀបនឹង ២,៨% នាឆ្នាំ ២០២៤ ស្របពេលដែលប្រាក់បញ្ញើអតិថិជនបន្តមានកំណើនរឹងមាំក្នុងកម្រិត ១២,៤% ដែលឆ្លុះបញ្ចាំងពីការរក្សាបាននូវជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ ។ យ៉ាងណាមិញ អនុបាតឥណទានមិនដំណើរការស្ថិតក្នុងកម្រិតខ្ពស់ ៨,៣% (៧,១% នាឆ្នាំ២០២៤) សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង ១៣,៥% (១៤,៣% នាឆ្នាំ២០២៤) សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ។ **យ៉ាងណាក៏ដោយ, ស្ថានភាពដើមទុន និងសន្ទនីយភាពមានភាពរឹងមាំ ដោយអនុបាតភាពគ្រប់គ្រាន់នៃដើមទុនមានកម្រិត ២២% សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង ៣១,២% សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ដែលខ្ពស់ជាងកម្រិតបទប្បញ្ញត្តិ ១៥% ហើយអនុបាតសន្ទនីយភាពមានកម្រិត ១៧៩,៣% សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលខ្ពស់ជាងកម្រិតបទប្បញ្ញត្តិ ១០០%** ។

ដោយឡែក, វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក៏បាននិងកំពុងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាពិសេសលើការជំរុញបរិយាបន្នហិរញ្ញវត្ថុ និងការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុជាដើម ដែលមានការផ្សារភ្ជាប់ខ្ពស់ទៅនឹងហានិភ័យនៅប្រព័ន្ធហិរញ្ញវត្ថុ ដូចគ្រឹះស្ថានហិរញ្ញវត្ថុដែរ ។ គិតត្រឹមឆ្នាំ ២០២៣ ទ្រព្យសកម្មសរុបមានចំនួន ៧,៦ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ៨,៣% នៃទ្រព្យសកម្មនៃវិស័យហិរញ្ញវត្ថុសរុប និង ១៧,៧% នៃ ផ.ស.ស. ។ បើទោះយ៉ាងណា, វិស័យនេះមិនទាន់ត្រលប់ទៅរកស្ថានភាពប្រសើរនៅឡើយ ក្នុងឆ្នាំ ២០២៦ នេះ ប៉ុន្តែហានិភ័យក្នុងវិស័យនេះ ស្ថិតនៅក្រោមស្ថានភាពអាចគ្រប់គ្រងបាន ។

ជារួម, មកទល់បច្ចុប្បន្ននេះ, បើទោះបីវិស័យហិរញ្ញវត្ថុនៅបន្តមានស្ថិរភាព និងមានភាពធន់ក្នុងស្ថានភាពថ្មី ប៉ុន្តែការប្រែប្រួលនៃស្ថានការណ៍សេដ្ឋកិច្ច ពិសេសក្នុងឆ្នាំ ២០២៦ នេះ ហាក់បាន និងកំពុងដាក់សម្ពាធបន្ថែម និងរំលេចឡើងនូវរូបភាពកាន់តែច្បាស់ទៅៗ ដែលក្នុងករណីខ្វះការយកចិត្តទុកដាក់គ្រប់គ្រងដោយប្រុងប្រយ័ត្ន អាចបង្កហានិភ័យជាប្រព័ន្ធក្នុងវិស័យហិរញ្ញវត្ថុ និងប៉ះពាល់ដល់គុណភាពនៃទ្រព្យសកម្មរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ។

## ខ. ទស្សនវិស័យសេដ្ឋកិច្ចរយៈពេលមធ្យម ឆ្នាំ ២០២៧-២០២៩

ផ្អែកលើមូលដ្ឋានសម្មតិកម្ម និងការសន្មតគន្លឹះដូចបានបរិយាយក្នុងផ្នែកខាងលើ, សម្រាប់ឆ្នាំ ២០២៧, សេដ្ឋកិច្ចកម្ពុជា ត្រូវបានព្យាករថានឹងងើបឡើងវិញសន្សឹមៗ ជាមួយអត្រាកំណើន ៥,០% ខណៈដែលក្នុងរយៈពេលមធ្យមខាងមុខ (២០២៨-២០២៩) កំណើននឹងបន្តនិន្នាការកើនឡើង ក្នុងរង្វង់ ៥,៥% ក្រោមការរំពឹងទុក នៃការបន្តរក្សាបាននូវចលនការកំណើនរឹងមាំនៃអនុវិស័យផលិតកម្ម (កាត់ដេរ និងមិនមែនកាត់ដេរ) ដែលចូលរួមពីអនុវិស័យ ដែលជាចន្ទល់កំណើនស្រាប់ ពោលគឺ កាត់ដេរសម្លៀកបំពាក់, ស្បែកជើង និងកាបូប (GFT) និងការចាប់ផ្តើមរីកធំធាត់នៃអនុវិស័យដែលសុទ្ធសឹងជាប្រភពនៃកំណើនថ្មីផង ពិសេសក្នុងផលិតកម្មកម្មន្តសាលមិនមែនកាត់ដេរ តួយ៉ាង គ្រឿងបង្គុំអេឡិចត្រូនិក, គ្រឿងបន្លាស់យានយន្ត, សំបកកង់រថយន្ត, ផ្គុំ និងដំឡើងរថយន្ត, និង កែច្នៃកសិផល និងម្ហូបអាហារ ជាដើម ។ ជាមួយគ្នានេះ, វិស័យកសិកម្ម ក៏ចាប់ផ្តើមងើបឡើងវិញជាបណ្តើរៗ ពិសេសវិស័យដំណាំ ដែលជំរុញដោយវិធានការលើកកម្ពស់ផលិតកម្មក្នុងស្រុក ជំនួសឱ្យការនាំចូលរបស់រាជរដ្ឋាភិបាល, ខណៈដែលអនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ (ទេសចរណ៍) ក៏រំពឹងថាងើបឡើងជាសន្សឹមៗ ដោយសារការងើបឡើងមកវិញនៃទំនុកចិត្តធ្វើដំណើរកំសាន្ត គួបផ្សំនឹងបច្ច័យវិជ្ជមាននៃការបោសសម្អាតទាំងស្រុងនៃសកម្មភាពឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដែលនឹងចូលរួមលើកកម្ពស់ទំនុកចិត្តនៃការធ្វើដំណើរកំសាន្តមក កម្ពុជា ជារួមផងដែរ ។

ផ្អែកលើការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន និងដំខ្លីខាងមុខ (Near-term outlook), ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេលខ្លី និងមធ្យម កាន់តែមានភាពមិនប្រាកដប្រជា និងភាពចល័តខ្ពស់ ខណៈដែលការធានាឱ្យបាននូវចលនការ និងទាញកំណើនសេដ្ឋកិច្ចឱ្យត្រលប់ទៅរកគន្លងសក្តានុពលវិញ កាន់តែមានមិស្សភាពជាងមុន ។ ជាក់ស្តែង, សង្គ្រាមនៅតំបន់មជ្ឈិមបូព៌ាបានសបញ្ជាក់ពីភាពផុយស្រួយនៃមូលដ្ឋានផលិតកម្មប្រេងឥន្ធនៈ ដែលបណ្តាលមកពីការកើនថ្លៃជាគំហុក និង ប្រឈមនឹងការរឹតត្បិតការផ្គត់ផ្គង់ សម្រាប់ប្រទេសដែលពឹងផ្អែកលើការនាំចូលផលិតផលទាំងនេះ ។ ការដំឡើងពន្ធជាសកល និងការប្រើប្រាស់ឧបករណ៍គោល-នយោបាយពាណិជ្ជកម្ម និងសេដ្ឋកិច្ច ក៏សុទ្ធសឹងជាចំណោទបញ្ហាមួយបន្ថែមទៀត ដែលបាននិងកំពុងធ្វើឱ្យរបបពាណិជ្ជកម្មសកល ប្រែប្រួលក្នុងទិសដៅ លឿនដោយមិនអាចប៉ាន់ប្រមាណទុកមុនបាន ។ ជាមួយគ្នានេះ, បញ្ហាព្រំដែនកម្ពុជា-ថៃ ក៏បានក្លាយជាវិញ្ញាសារសាកល្បងពីភាពធន់ និងសមត្ថភាពឆ្លើយតប មិនត្រឹមដើម្បីគ្រាន់តែរស់រាន (Survival) មួយមុខប៉ុណ្ណោះទេ ប៉ុន្តែគឺត្រូវរស់ដោយភាពរឹងមាំ និងបត់បែនរហ័ស (Nimble) ។ ក្នុងន័យ

នេះ, សម្រាប់កម្ពុជា, ក្នុងបរិការណ៍មិនប្រាកដប្រជាខ្ពស់ដូចបច្ចុប្បន្ន, ការធានាឱ្យបាននូវចលនការ និងអូសទាញកំណើនឱ្យត្រលប់ទៅវិថីនៃកំណើនសក្តានុពលវិញ កាន់តែមានភាពតឹងតែងជាងមុន ដែលតម្រូវឱ្យមានការគិតគូររៀបចំវិធានការគោលនយោបាយ កាន់តែមុតស្រួច, ចំគោលដៅ, មានភាពបត់បែន, និងអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់ ។ ស្របពេលដែល **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១»** ជាក្របខ័ណ្ឌយុទ្ធសាស្ត្រគ្របដណ្តប់រួម, ការបន្តជំរុញការអនុវត្តយុទ្ធសាស្ត្រនេះ និងការអនុវត្ត **«កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និងពង្រឹងភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់ របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា»** និង **«កម្មវិធីជំរុញការកែលម្អបរិយាកាសធុរកិច្ច និង វិនិយោគនៅកម្ពុជា ឆ្នាំ ២០២៥-២០២៨»** កាន់តែមានភាពចាំបាច់ និងបន្ទាន់ឡើង ដើម្បីក្បាលទ្រទ្រង់ម៉ាស៊ីនកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេលមធ្យម និងវែងខាងមុខ និងការរំពឹងទុកដូចខាងក្រោម៖

**វិស័យឧស្សាហកម្ម** ត្រូវបានព្យាករថានឹងមានកំណើនជាមធ្យម ប្រមាណ ៧,៥% សម្រាប់រយៈពេលមធ្យម ២០២៧-២០២៩ ។ ក្នុងនោះ, សម្រាប់ឆ្នាំ ២០២៧, វិស័យនេះត្រូវបានព្យាករថាមានកំណើន ៧,៣% ។ អនុវិស័យកាត់ដេរ នៅបន្តមានចលនការកំណើន ដែលបន្តគាំទ្រដោយការបន្តនិន្នាការវិជ្ជមាន និងការធ្វើពិពិធកម្មនៃការនាំចេញផលិតផលកាត់ដេរពោលទាំងទៅលើផលិតផល និងទីផ្សារ ។ ជាមួយគ្នានេះ, ការរៀបចំ និងដាក់ចេញនូវ **«យុទ្ធសាស្ត្រអន្តរកាលដោយរលូន»** ដើម្បីត្រៀមចាកចេញពីក្រុមបណ្តាប្រទេសអភិវឌ្ឍន៍តិចតួច (LDC) ក៏ដូចជាឆ្លើយតបទៅនឹងលក្ខខ័ណ្ឌផ្លាស់ប្តូរពីរដំណាក់កាល នឹងកាន់តែដើរតួនាទីយ៉ាងសំខាន់ ក្នុងការពង្រឹងប្រវាក់តម្លៃនៃអនុវិស័យនេះ ពិសេសការពង្រីក និងពង្រឹងឧស្សាហកម្មប្រតិគមន៍ (Backward linkage) ផង និងបង្កើតតម្លៃបន្ថែមក្នុងអនុវិស័យនេះ ជារួមផង ។ អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ រំពឹងថានឹងបន្តនិន្នាការកើនឡើង ដែលបន្តចូលរួមគាំទ្រដោយឧស្សាហកម្មបម្រើទីផ្សារក្នុងស្រុក និងឧស្សាហកម្មបម្រើទីផ្សារនាំចេញ ។ ក្នុងនោះ, ឧស្សាហកម្មយុទ្ធសាស្ត្រសំខាន់ៗ តួយ៉ាង គ្រឿងបង្គុំអេឡិចត្រូនិក, សំបកកង់រថយន្ត, គ្រឿងបន្លាស់រថយន្ត, ផ្គុំ និងដំឡើងរថយន្ត, គ្រឿងសង្ហារិម, កែច្នៃ និងវេចខ្ចប់ ជាដើម នៅតែជាចលករអូសទាញកំណើនយ៉ាងសំខាន់ ខណៈនៅតែបន្តរីកធំធាត់ជាលំដាប់ តាមរយៈការបន្តជំរុញសេដ្ឋកិច្ចមាត្រដ្ឋាន (Economies of scale) ដែលកើតចេញពីកម្លាំងប្រមូលផ្តុំ (Clustering effects) តួយ៉ាងដូចជាតំបន់សេដ្ឋកិច្ចពិសេស និងសួនឧស្សាហកម្ម ជាដើម ។ អនុវិស័យផលិតកម្មម្ហូបអាហារ និងភេសជ្ជៈ ក៏នៅបន្តមានកំណើនឆ្លើយតបទៅនឹងនិន្នាការកើនឡើងជាលំដាប់នៃតម្រូវការក្នុងស្រុក ។ ជាទិសដៅក្នុងរយៈពេលមធ្យមខាងមុខ, ការជំរុញលើកកម្ពស់អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ជារួម នឹងត្រូវធ្វើឡើងតាមរយៈការពង្រីក និងពង្រឹងមូលដ្ឋានប្រមូលផ្តុំ ដោយផ្អែកលើទំនិញ និងឧស្សាហកម្មជាយុទ្ធសាស្ត្រ ។ ជាក់ស្តែង, ការដាក់ចេញ និងអនុវត្តនូវ **«ផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា»** និង **«កម្មវិធីលើកកម្ពស់ផលិតកម្មកែច្នៃ សម្រាប់ជំនួសការនាំចូល និងជំរុញការនាំចេញ ក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ឆ្នាំ ២០២៦-២០២៨»** ក៏នឹងក្លាយជាការបោះជំហានថ្មីមួយ ក្នុងគោលដៅពង្រឹងកម្លាំងផលិតកម្មសេដ្ឋកិច្ច

ក្នុងស្រុក និងពង្រីកមូលដ្ឋាននាំចេញ ។ ជាមួយគ្នានេះ, ការបន្តអនុវត្ត **«កម្មវិធីពិសេសជំរុញការវិនិយោគ ក្នុងខេត្តទាំងបួននៅភូមិភាគឦសាននៃព្រះរាជាណាចក្រកម្ពុជា ២០២៥-២០២៨»** ក៏សុទ្ធសឹងជាគោលនយោបាយជំរុញការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម ពិសេសឧស្សាហកម្មកែច្នៃ មិនត្រឹមតែក្នុងគោលដៅជំរុញការវិនិយោគ និងពង្រាយមូលដ្ឋានផលិតកម្មនៅតំបន់ឆ្ងាយមជ្ឈមណ្ឌលកំណើនតែប៉ុណ្ណោះទេ, ប៉ុន្តែក៏ក្នុងគោលដៅជំរុញការអភិវឌ្ឍអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ពិសេសការកែច្នៃ ជារួម ។ ទន្ទឹមនេះ, ការត្រៀមរៀបចំ និង អនុវត្ត **«អនុក្រឹត្យ ស្តីពីការលើកទឹកចិត្តសហគ្រាសធុនតូច និង មធ្យម»** ក៏នឹងក្លាយជាមូលដ្ឋានមួយដ៏ចាំបាច់បន្ថែមទៀត ក្នុងការលើកកម្ពស់តួអង្គពាក់ព័ន្ធ ដែលជាចលករសំខាន់ក្នុងការជំរុញកំណើនអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ។ អនុវិស័យសំណង់ ព្យាករថានឹងបន្តមានកំណើនយឺត ដោយសារការរំពឹងទុកការងើបឡើងវិញក្នុងល្បឿនយឺតនៃសំណង់ថ្លៃខ្ពស់, ប៉ុន្តែអនុវិស័យនេះ ជារួមនឹងទ្រទ្រង់ដោយសំណង់លំនៅឋានថ្លៃសមរម្យ ឆ្លើយតបទៅនឹងតម្រូវការពិត គួបផ្សំនឹងបច្ច័យជាវិជ្ជមាននៃការដាក់ឱ្យអនុវត្តនូវ **«គោលនយោបាយអភិវឌ្ឍន៍លំនៅឋាន សង្គម និងលំនៅឋានតម្លៃសមរម្យ»**, និងសំណង់បម្រើឱ្យឧស្សាហកម្មពិសេសរោងចក្រ និងឃ្លាំង ជាដើម, ដែលជានិន្នាការថ្មីជួយគាំពារកំណើននៃអនុវិស័យនេះក្នុងរយៈពេលមធ្យមខាងមុខ ។

**វិស័យសេវាកម្ម** ត្រូវបានព្យាករថានឹងមានកំណើនជាមធ្យម ប្រមាណ ៤,២% សម្រាប់រយៈពេលមធ្យម ២០២៧-២០២៩ ក្នុងនោះ, សម្រាប់ឆ្នាំ ២០២៧, វិស័យនេះត្រូវបានព្យាករថាមានកំណើន ៣,៨% ។ អនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ រំពឹងថានឹងបន្តនិន្នាការកើនឡើង ដោយសារការបន្តកើនឡើងជាលំដាប់នៃលំហូរទេសចរអន្តរជាតិ ស្របពេលដែលទេសចរជាតិ ក៏នៅមានសក្តានុពលខ្ពស់ ។ ការបន្តស្តារ និងលើកកម្ពស់កិត្តិនាមរបស់កម្ពុជាលើឆាកអន្តរជាតិ, ការបន្តធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ និង សេវាកម្មគាំទ្រ, ការជំរុញភាពប្រកួតប្រជែងក្នុងវិស័យទេសចរណ៍ និងពង្រឹងប្រវាក់តម្លៃទេសចរណ៍, ការបន្តបើកទីផ្សារទេសចរណ៍ និងជំរុញការភ្ជាប់ជើងហោះហើរត្រង់, ការរៀបចំប្រតិទិនទេសចរណ៍ និងព្រឹត្តិការណ៍ទេសចរណ៍ គួបផ្សំនឹងការបន្តអនុវត្តផែនការមេអភិវឌ្ឍន៍ទេសចរណ៍តាមបណ្តាខេត្តដែលជាប៉ូលទេសចរណ៍សំខាន់ៗ និងការបន្តលើកកម្ពស់ការធ្វើដំណើរកំសាន្តក្នុងរដូវកាលបែតង គឺជាចលករដ៏សំខាន់ ក្នុងការចូលរួមគាំទ្រដល់កំណើននៃ អនុវិស័យនេះ ក្នុងរយៈពេលមធ្យមខាងមុខ ។ ដោយឡែក, អនុវិស័យអចលនទ្រព្យ ដូចគ្នាទៅនឹងអនុវិស័យសំណង់ដែរ ក៏ងើបឡើងវិញក្នុងល្បឿនយឺត ដែលបន្តគាំទ្រដោយសកម្មភាពទិញ-លក់ និងជួលលំនៅឋានថ្លៃសមរម្យ, និងរោងចក្រ ។ អនុវិស័យលក់ដុំ-រាយ រំពឹងថានឹងបន្តនិន្នាការកើនឡើង ដែលជំរុញដោយសកម្មភាពចាយ និងប្រើប្រាស់ក្នុងស្រុក ស្របនឹងនិន្នាការនៃការកើនឡើងប្រភពចំណូលរបស់ប្រជាជន ។ នៅក្នុងរយៈពេលមធ្យមខាងមុខ ការបន្តរីកចម្រើននៃអាជីវកម្មអនឡាញ, និងការបន្តធ្វើទំនើបកម្ម និងសមាហរណកម្មនៃប្រព័ន្ធទូទាត់ឌីជីថល នឹងកាន់តែបង្កលក្ខណៈងាយស្រួលបន្ថែមទៀតដល់ប្រតិបត្តិការសេដ្ឋកិច្ចផងដែរ ។ អនុវិស័យដឹកជញ្ជូន និងស្តុក ក៏នៅបន្តនិន្នាការល្អ គាំទ្រដោយចលនការកំណើននៃវិស័យគាំទ្រ

ពិសេសវិស័យបម្រើការនាំចេញ និងវិស័យទេសចរណ៍ ស្របពេលដែលការដឹកជញ្ជូនបញ្ញើរហ័សក្នុងស្រុក ក៏កាន់តែមានការកើនឡើងជាលំដាប់ ឆ្លើយតបទៅនឹងនិន្នាការកើនឡើងនៃតម្រូវការ និងសកម្មភាពអាជីវកម្មក្នុងស្រុក ។ ជាមួយគ្នានេះ ការបន្តអនុវត្តនូវ **«ផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយ និងភស្តុភារកម្ម កម្ពុជា ២០២៣-២០៣៣»** គួបផ្សំនឹងការបន្តវិនិយោគហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ពិសេសលើការពង្រីកវិសាលភាព, សមត្ថភាពផ្ទុក និងលើកដាក់ទំនិញ នៅកំពង់ផែទាំងពីរ ក៏នឹងជួយគាំទ្រដល់កំណើននៃអនុ-វិស័យនេះផងដែរ ក្នុងរយៈពេលមធ្យមខាងមុខ ។ អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង ក៏រំពឹងថាងើបឡើងវិញសន្សឹមៗ ដោយសារការកើនឡើងនូវការបញ្ចេញឥណទានថ្មីៗ ដើម្បីគាំទ្រដល់សកម្មភាពវិនិយោគ និងអាជីវកម្ម ពិសេសសហគ្រាសធុនតូច និងមធ្យម និងវិស័យដែលមានផលិតភាពខ្ពស់ ។ ជាមួយគ្នានេះ, ការបន្តធ្វើឌីជីថលូបនីយកម្មប្រព័ន្ធ និងសេវាហិរញ្ញវត្ថុ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពប្រតិបត្តិការហិរញ្ញវត្ថុ ស្របតាម **«គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨»** និង **«យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ ២០២៥-២០៣០»** ក៏នឹងគាំពារដល់កំណើននៃអនុវិស័យនេះផងដែរ ។ អនុវិស័យបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ រំពឹងថានឹងបន្តមានកំណើនរឹងមាំ ដែលគាំទ្រដោយនិន្នាការវិជ្ជមាននៃការចាប់យក និងត្រៀមធ្វើបរិវត្តកម្មឌីជីថល ពោលទាំង ក្នុងកម្រិតប្រជាជនទូទៅ, អាជីវកម្ម និងរដ្ឋាភិបាល ស្របតាម **«ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥»** និងក្របខ័ណ្ឌគោលនយោបាយពាក់ព័ន្ធផ្សេងទៀត ។

**វិស័យកសិកម្ម** ត្រូវបានព្យាករថានឹងមានកំណើនជាមធ្យម ប្រមាណ ១,៣% សម្រាប់រយៈ-ពេលមធ្យម ២០២៧-២០២៩ ។ ក្នុងនោះ, សម្រាប់ឆ្នាំ ២០២៧, វិស័យនេះត្រូវបានព្យាករថាមានកំណើន ១,២% ។ ក្នុងនោះ, អនុវិស័យដំណាំ រំពឹងថានឹងនៅបន្តនិន្នាការកើនឡើងដោយសារការបន្តលើកកម្ពស់ការវិនិយោគក្នុងស្រុក និងពីបរទេសលើការកែច្នៃផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្ម ពិសេសលើទំនិញសក្តានុពលសំខាន់ៗ ជាអាទិ៍ ស្វាយចន្ទី, ដំឡូងមី,ពោត និងបន្លែ ជាដើម តាមរយៈការរៀបចំ និងដាក់ឱ្យអនុវត្តនូវ **«កម្មវិធីលើកកម្ពស់ផលិតកម្មកែច្នៃ សម្រាប់ជំនួសការនាំចូល និងជំរុញការនាំចេញ ក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ឆ្នាំ ២០២៦-២០២៨»** និងការបន្តអនុវត្ត **«កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាន នៃព្រះរាជាណាចក្រកម្ពុជា ២០២៥-២០២៨»** ដែលនឹងជំរុញកម្លាំងប្រមូលផ្តុំ និងសេដ្ឋកិច្ចមាត្រដ្ឋាន ក្នុងអនុវិស័យនេះ ។ ជាមួយគ្នានេះ, ការបន្តអនុវត្តវិធានការដែលមានស្រាប់ តួយ៉ាង **«កម្មវិធីធានាស្ថិរភាពថ្លៃកសិផល»**, **«សហគមន៍កសិកម្មទំនើប»**, និង **«កម្មវិធីហិរញ្ញប្បទានក្រោមធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម»** ក៏នឹងជួយពង្រឹងមូលដ្ឋាននៃការអភិវឌ្ឍក្នុងអនុវិស័យនេះបន្ថែមទៀត ។ អនុវិស័យចិញ្ចឹមសត្វ ក៏នៅបន្តរក្សាស្ថិរភាពកំណើន ដោយសារការបន្តកើនឡើងនៃតម្រូវការក្នុងស្រុក គួបផ្សំនឹងការបន្តអនុវត្តវិធានការអន្តរាគមន៍ លើការនាំចូលសាច់បង្កក និងបទប្បញ្ញត្តិពាក់ព័ន្ធ ដែលនឹងលើកទឹកចិត្តការចិញ្ចឹមក្នុងស្រុក ។ អនុវិស័យនេសាទ ក៏នឹងបន្តមានកំណើនល្អ គាំទ្រដោយកំណើនល្អនៃផលចាប់ទឹកសាប ដោយសារការបន្តបង្ក្រាបបទល្មើសនេសាទ ខណៈ

ដែលការវិនិយោគក្នុងវារីវប្បកម្ម រំពឹងថាងើបឡើងវិញសន្សឹមៗផងដែរ ក្រោមការជ្រោមជ្រែង របស់រាជរដ្ឋាភិបាល តាមរយៈការដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធ ការគាំទ្រផ្នែក ហិរញ្ញប្បទាន និងបច្ចេកទេសពាក់ព័ន្ធ ។

ក្នុងរយៈពេលខាងមុខ (២០២៧-២០២៩) **អត្រាអតិផរណា** ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ប្រមាណ ២,៥% ស្របគ្នាទៅនឹងនិន្នាការសេដ្ឋកិច្ច ខណៈដែលថ្លៃទំនិញអន្តរជាតិ ក៏រំពឹងថានឹង បន្តរក្សាបានប្រក្រតីភាព ។ ជាមួយគ្នានេះ, **អត្រាប្តូរប្រាក់ផ្លូវការ (រៀល/ដុល្លារអាមេរិក)** រំពឹងថានឹងរក្សាបានក្នុងរង្វង់ ៤ ០៥០ រៀល/ដុល្លារអាមេរិក ក្រោមការរំពឹងទុកនៃការរក្សាបានស្ថិរភាពនៃរូបិយប័ណ្ណដុល្លារ គួបផ្សំនឹងការបន្តអនុវត្តគោលនយោបាយរូបិយវត្ថុគាំទ្រកំណើន និងធានាស្ថិរភាពថ្លៃ ។

## តារាងទី ២៖ ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជាតាមវិស័យ ឆ្នាំ ២០២០-២០២៩

| កំណើន (%) | 2020 | 2021 | 2022 | 2023 | 2024 | 2025 | 2026ប. | 2027ព្យ. | 2028ព្យ. | 2029ព្យ. |
|---|---|---|---|---|---|---|---|---|---|---|
| **ផ.ស.ស.** | **-3.6** | **3.1** | **5.1** | **5.0** | **6.0** | **5.3** | **4.2** | **5.0** | **5.3** | **5.6** |
| **វិស័យកសិកម្ម** | **0.6** | **1.5** | **0.6** | **1.1** | **1.0** | **1.2** | **0.7** | **1.2** | **1.3** | **1.3** |
| ដំណាំ | 0.6 | 2.2 | 1.1 | 1.2 | 1.4 | 1.4 | 0.8 | 1.5 | 1.6 | 1.6 |
| នេសាទ | 0.7 | -1.0 | -1.3 | 1.3 | 1.8 | 1.6 | 0.9 | 1.0 | 1.0 | 1.0 |
| ចិញ្ចឹមសត្វ | 0.9 | 2.3 | 1.2 | 1.1 | -1.2 | 0.9 | 0.4 | 0.6 | 0.7 | 0.8 |
| **វិស័យឧស្សាហកម្ម** | **-2.2** | **8.4** | **8.2** | **5.4** | **9.9** | **8.7** | **6.7** | **7.3** | **7.4** | **7.8** |
| កាត់ដេរ | -7.7 | 15.9 | 11.3 | -4.5 | 15.8 | 12.5 | 8.6 | 7.6 | 6.7 | 6.7 |
| សំណង់ | -7.6 | -8.0 | 0.9 | 0.8 | 1.2 | 1.3 | 0.7 | 1.1 | 2.2 | 3.1 |
| ផលិតកម្មម្ហូបអាហារ | 3.4 | 4.2 | 7.6 | 9.3 | 5.0 | 4.6 | 4.2 | 5.5 | 6.3 | 6.5 |
| ផលិតកម្មភេសជ្ជៈ និងថ្នាំជក់ | 4.4 | 7.9 | 5.6 | 5.8 | 2.4 | 3.2 | 2.5 | 2.8 | 3.5 | 4.0 |
| កម្មន្តសាលមិនមែនកាត់ដេរ | 11.9 | 16.8 | 10.3 | 21.7 | 10.6 | 9.8 | 8.5 | 10.5 | 11.0 | 11.3 |
| **សេវាកម្ម** | **-6.7** | **-1.8** | **3.6** | **6.0** | **4.3** | **3.3** | **2.6** | **3.8** | **4.3** | **4.6** |
| បដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ | -34.2 | -39.5 | 22.0 | 49.1 | 13.2 | 2.1 | -0.1 | 4.6 | 5.0 | 5.5 |
| លក់ដុំ-រាយ | -6.3 | 2.5 | 4.5 | 2.1 | 3.9 | 3.9 | 2.0 | 4.1 | 5.1 | 5.5 |
| ដឹកជញ្ជូន និងស្តុក | -2.7 | 3.8 | 4.7 | 4.8 | 6.0 | 4.7 | 4.5 | 5.6 | 6.1 | 6.1 |
| បច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ | 11.5 | 12.0 | 9.0 | 8.6 | 5.1 | 5.7 | 5.1 | 5.6 | 6.0 | 6.0 |
| ហិរញ្ញវត្ថុ និងធានារ៉ាប់រង | 4.3 | 3.2 | -1.0 | -0.1 | -0.2 | 1.1 | 0.5 | 0.9 | 1.6 | 1.8 |
| អចលនទ្រព្យ | -8.3 | -8.5 | 0.5 | -1.6 | 0.9 | 1.1 | 0.6 | 0.9 | 1.7 | 2.9 |
| **អតិផរណា** | **2.9** | **2.9** | **5.3** | **2.1** | 0.8 | 2.6 | 3.8 | 2.6 | 2.5 | 2.5 |
| **អត្រាប្តូរប្រាក់** | **4,077** | **4,068** | **4,087** | **4,110** | **4,070** | **4,011** | **4,029** | **4,041** | **4,050** | **4,058** |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (២០២០-២០២៥) និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២៦-២០២៩)*

**ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ)** ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ ប្រមាណ -៦,៩% នៃ ផ.ស.ស. ដោយសារការរំពឹងទុកការរក្សាបាននូវសមតុល្យពាណិជ្ជកម្ម ស្របពេលដែលចំណូលពីវិស័យទេសចរណ៍ ក៏មានការកើនឡើងជាបន្តបន្ទាប់, ខណៈប្រាក់បង្វែរឯកជនរំពឹងថានឹងកើនឡើងវិញជាសន្សឹមៗ ប៉ុន្តែរំពឹងថានឹងមិនអាចវិលត្រលប់ទៅរកកម្រិតមុនបញ្ហាព្រំដែនកម្ពុជា-ថៃ វិញឡើយ ។ ក្នុងរយៈពេលមធ្យមខាងមុខ ទំហំពាណិជ្ជកម្មកម្ពុជា នឹងមាននិន្នាការកើនឡើងជាបន្តបន្ទាប់ ស្របពេលដែលការនាំចេញនឹងកាន់តែមានពិពិធភាព និងតម្លៃបន្ថែមខ្ពស់ជាងមុន តួយ៉ាងការបន្តរីកធំនៃផលិតកម្ម និងការនាំចេញផលិតផលកម្មន្តសាលមិនមែនកាត់ដេរ ពិសេសលើប្រភេទឧស្សាហកម្មសក្តានុពល ជាអាទិ៍ គ្រឿងបង្គុំអេឡិច-ត្រូនិក, ខ្សែចម្លងអគ្គិសនី, គ្រឿងបន្លាស់រថយន្ត, សំបកកង់រថយន្ត, និងគ្រឿងសង្ហារិម ជាដើម ។ ទន្ទឹមនេះ ការនាំចូលក៏បន្តនិន្នាការកើនឡើងផងដែរ ដែលគាំទ្រដោយការនាំចូលវត្ថុធាតុដើមសម្រាប់ផលិតកម្មក្នុង

ស្រុក និងទំនិញប្រើប្រាស់ផ្សេងទៀត សំដៅបំពេញបន្ថែមនូវតម្រូវការក្នុងស្រុក ។ វិហូរវិនិយោគផ្ទាល់ពីបរទេស ត្រូវបានព្យាករថានឹងបន្តកើនឡើងជាលំដាប់ ក្នុងរង្វង់ប្រមាណ ១១,០% នៃ ផ.ស.ស. ពិសេសក្នុងវិស័យកសិ-ឧស្សាហកម្ម និងឧស្សាហកម្ម ដែលជាបច្ច័យពីការពង្រឹងការអនុវត្តច្បាប់ និងកម្មវិធីជំរុញវិនិយោគ គួបផ្សំនឹងការខិតខំប្រឹងប្រែងការបន្តកែលម្អបរិយាកាសធុរកិច្ច និងកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការដាក់ឱ្យអនុវត្តនូវ **«កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និងពង្រឹងភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់ របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា»** និង **«កម្មវិធីជំរុញការកែលម្អបរិយាកាសធុរកិច្ច និង វិនិយោគនៅកម្ពុជា ឆ្នាំ ២០២៥-២០២៨»** ។ ផ្អែកលើមូលដ្ឋាននេះ, ទុនបម្រុងអន្តរជាតិ ត្រូវបានព្យាករថានឹងបន្តរក្សាបាននិន្នាការរឹងមាំ ដែលមានទំហំសមាមាត្រទៅនឹងការនាំចូល ប្រមាណ ៧,៩ ខែ ជាមធ្យមប្រចាំឆ្នាំ ។

### តារាងទី ៣៖ ទស្សនវិស័យនៃស្ថានភាពវិស័យខាងក្រៅកម្ពុជា ២០២០-២០២៩

| សូចនាករ | 2020 | 2021 | 2022 | 2023 | 2024 | 2025 | 2026ប. | 2027ព្យ. | 2028ព្យ. | 2029ព្យ. |
|---|---|---|---|---|---|---|---|---|---|---|
| ការនាំចេញ (លានដុល្លារអាម៉េរិក) | 18,522 | 19,521 | 23,179 | 23,564 | 26,752 | 31,359 | 33,122 | 36,050 | 39,621 | 43,741 |
| ការនាំចូល (លានដុល្លារអាម៉េរិក) | 21,066 | 30,726 | 32,005 | 26,551 | 31,247 | 36,932 | 39,372 | 42,924 | 47,116 | 52,009 |
| សមតុល្យពាណិជ្ជកម្ម (លានដុល្លារអាម៉េរិក) | -2,544 | -11,257 | -8,826 | -2,986 | -4,496 | -5,573 | -6,250 | -6,874 | -7,495 | -8,267 |
| សមតុល្យគណនីចរន្ត (លានដុល្លារអាម៉េរិក) | -881 | -10,893 | -7,582 | 552 | 228 | -1,867 | -4,045 | -4,275 | -4,297 | -4,349 |
| វិហូរវិនិយោគផ្ទាល់ពីបរទេស (លានដុល្លារអាម៉េរិក) | 3,625 | 3,486 | 3,579 | 3,959 | 4,395 | 5,136 | 5,569 | 6,157 | 6,867 | 7,693 |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាម៉េរិក) | 21,334 | 20,265 | 17,805 | 19,998 | 22,511 | 27,530 | 29,169 | 30,867 | 33,159 | 36,221 |
| ការនាំចេញ (ភាគរយនៃ ផ.ស.ស.) | 53.0% | 52.7% | 58.5% | 55.7% | 57.7% | 61.1% | 60.7% | 61.8% | 63.3% | 64.9% |
| ការនាំចូល (ភាគរយនៃ ផ.ស.ស.) | 60.3% | -82.9% | -80.8% | -62.7% | -67.4% | -72.0% | -72.1% | -73.5% | -75.3% | -77.2% |
| សមតុល្យពាណិជ្ជកម្ម (ភាគរយនៃ ផ.ស.ស.) | -7.3% | -30.4% | -22.3% | -7.1% | -9.7% | -10.9% | -11.4% | -11.8% | -12.0% | -12.3% |
| សមតុល្យគណនីចរន្ត (ភាគរយនៃ ផ.ស.ស.) | -2.5% | -29.4% | -19.1% | 1.3% | 0.5% | -3.6% | -7.4% | -7.3% | -6.9% | -6.5% |
| វិហូរវិនិយោគផ្ទាល់ពីបរទេស (ភាគរយនៃ ផ.ស.ស.) | 10.4% | 9.4% | 9.0% | 9.3% | 9.5% | 10.0% | 10.2% | 10.5% | 11.0% | 11.4% |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូល) | 13.4 | 7.4 | 6.1 | 10.1 | 9.6 | 9.8 | 8.2 | 8.0 | 7.9 | 7.8 |

*ប្រភព៖ ធនាគារជាតិនៃកម្ពុជា (២០២០-២០២៥) និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២៦-២០២៩)*

## គ. ហានិភ័យ និងទិសដៅគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

ហានិភ័យ និងភាពមិនប្រាកដប្រជាពីកត្តាខាងក្រៅ នៅតែជាចំណោទបញ្ហាដល់ទស្សនវិស័យសេដ្ឋកិច្ចក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ ។ សេដ្ឋកិច្ចកម្ពុជា ដែលមានម៉ូដែលនៃកំណើន និងគម្រូនៃការកសាងមូលដ្ឋានសេដ្ឋកិច្ច ដោយពឹងផ្អែកលើផលលាភនៃសកលភាវូបនីយកម្ម និងការពង្រឹងការផ្សារភ្ជាប់ទៅនឹងប្រវាក់ផលិតក្នុងតំបន់ និងសកល, ការប្រែប្រួលក្នុងទិសដៅណាមួយនៃកត្តាខាងក្រៅ ប្រាកដណាស់នឹងមានកម្មវិបាកដល់សេដ្ឋកិច្ចកម្ពុជាទាំងផ្ទាល់ និងប្រយោល ។ ហានិភ័យ និងភាពមិនប្រាកដប្រជាចម្បងៗ ដែលបង្កឡើងដោយកត្តាខាងក្រៅ និងកត្តាខាងក្នុង រួមមាន៖

➢ **កត្តាខាងក្រៅ**

១). ភាពមិនច្បាស់លាស់ និងភាពចល័តខ្ពស់ នៃស្ថានភាពនៅតំបន់មជ្ឈិមបូព៌ា ដែលនឹងជំរុញថ្លៃប្រេងឥន្ធនៈអន្តរជាតិ បន្តហក់ឡើងខ្ពស់ និងមានលទ្ធភាពអាចបន្ទចបង្អាក់ ដល់ប្រវាក់ផ្គត់ផ្គង់សកល ក្នុងទ្រង់ទ្រាយធំ;

២). ការផ្លាស់ប្តូរយ៉ាងរហ័សនៃរបបពាណិជ្ជកម្មសកល ពិសេសតាមរយៈការដាក់ចេញនូវពន្ធគយជាសកល (Global tariff) និងការបន្តស្ថិតក្នុងការស៊ើបអង្កេតឧបាស្រ័យពាណិជ្ជកម្មរបស់សហរដ្ឋអាម៉េរិក លើផលិតផលកម្មន្តសាលមិនមែនកាត់ដេរសំខាន់ៗមួយចំនួន;

៣). ការថមថយសន្ទុះនៃកំណើនសេដ្ឋកិច្ចសកល ពិសេសបណ្តាប្រទេសដែលជាដៃគូពាណិជ្ជកម្មជាមួយកម្ពុជា តួយ៉ាងសហភាពអឺរ៉ុប ជាដើម;

៤).បញ្ហាព្រំដែនកម្ពុជា-ថៃ ដែលមានលទ្ធភាពអាចផ្ទុះប្រដាប់អាវុធឡើងវិញជាថ្មី និង/ឬ ការដាក់ទិវង្សនាសេដ្ឋកិច្ចមកលើកម្ពុជា; និង

៥). ការប្រែប្រួលអាកាសធាតុ នៅតែជាហានិភ័យ ជាពិសេសលើការបង្កបង្កើនផល និងវិស័យកសិកម្មផ្សេងទៀត ។

➢ **កត្តាខាងក្នុង**

១). សន្ទុះកំណើនយឺតក្នុងវិស័យមួយចំនួន តួយ៉ាង វិស័យសំណង់-អចលនទ្រព្យ និងទេសចរណ៍ និងលទ្ធភាពដែលអាចបំផុសឱ្យមានបញ្ហាថ្មីៗកើតឡើងបន្ថែមទៀត;

២). ការនាំចេញនៅមានលក្ខណៈប្រមូលផ្តុំខ្លាំងតែទៅលើទីផ្សារមួយចំនួន ដែលធ្វើឱ្យទស្សនវិស័យនៃវិស័យបម្រើការនាំចេញ (កាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ) ប្រឈមនឹងហានិភ័យខ្ពស់ ស្របពេលដែលសភាពការណ៍សកល បន្តមានភាពមិនប្រាកដប្រជា និងភាពចល័តខ្ពស់;

៣). បំណុលឯកជនស្ថិតក្នុងកម្រិតខ្ពស់ និងការបន្តកើនឡើងនៃឥណទានមិនដំណើរការ (NPL) ដែលអាចប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុ;

៤). ការកៀរគរចំណូលបន្តមានកំណើនទាប និងការថមថយនៃហិរញ្ញប្បទានក្រៅប្រទេស ដែលកម្រិតដល់លទ្ធភាពក្នុងការធ្វើអន្តរាគមន៍ក្នុងពេលមានវិបត្តិ ពិសេសការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ និងជីវភាពប្រជាជន; និង

៥). កំណើនសេដ្ឋកិច្ចបន្តរងផលប៉ះពាល់ដោយសារវិបត្តិ និង ធ្វើឱ្យកំណើនថមថយជាលំដាប់ ដោយកម្ពុជានៅបន្តពឹងផ្អែកលើចន្ទល់កំណើនដែលមានស្រាប់ មិនទាន់អាចកសាងបាននូវចន្ទល់កំណើនសេដ្ឋកិច្ចថ្មីនៅឡើយ ។

ទន្ទឹមនឹងការកើនឡើងនៃហានិភ័យខាងក្រៅ និងខាងក្នុង, កម្ពុជា ក៏នៅតែប្រឈមបញ្ហាជារចនាសម្ព័ន្ធផ្ទៃក្នុងមួយចំនួន ដែលទាមទារឱ្យខាងតែបាននូវការបន្តពង្រឹងការដ្ឋានកែទម្រង់ស៊ីជម្រៅ និងប្រកបដោយឆន្ទៈនយោបាយបាយខ្ពស់ ដូចជា៖ **១).** ល្បឿនយឺតនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច, **២).** ថ្លៃដើមធុរកិច្ចនៅមិនទាន់មានភាពប្រកួតប្រជែង, **៣).** ភាពមានកម្រិតនៃគុណភាពនៃកម្លាំងពលកម្ម ដែលមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ពិសេសការចាប់យកឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ និងបច្ចេកវិទ្យាឌីជីថល, និង **៤).** កង្វះខាតនូវឧស្សាហកម្មដើមខ្សែ (Upstream industries) និងឧស្សាហកម្មប្រតិគមន៍ គួបផ្សំនឹង

ភាពមានកម្រិតនៃការថ្លក់ភ្ជាប់ឧស្សាហកម្មទាំងនោះ ទៅនឹងខ្សែច្រវាក់ផលិតកម្មក្នុងស្រុក ដែលផ្តល់ការលំបាកក្នុងការជំរុញសេដ្ឋកិច្ចមាត្រដ្ឋាន ។

ទោះជាយ៉ាងនេះក្តី, កម្ពុជាក៏បានពូនជ្រំនូវមូលដ្ឋានគ្រឹះសំខាន់ៗ ដែលសុទ្ធសឹងជាកម្លាំងក្នុងការផ្តល់នូវថាមពលកំណើន ក៏ដូចជាចលករជំរុញការប្រែក្លាយបញ្ហាប្រឈម ទៅជាកាលានុវត្តន៍ភាព សំដៅបន្តពង្រឹងកម្លាំងសេដ្ឋកិច្ច ក្នុងស្រុក និងគាំពារចលនការកំណើនក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ ។ មូលដ្ឋានគ្រឹះដ៏រឹងមាំទាំងនោះ រួមមាន៖ **១).** ការរក្សាបាននិន្នាការរឹងមាំ និងការបន្តរីកធំនៃសកម្មភាពនៃវិស័យកម្មន្ត-សាល ពិសេសឧស្សាហកម្មសក្តានុពលយុទ្ធសាស្ត្រ ដូចជា វិស័យកសិ-ឧស្សាហកម្មកែច្នៃ និងឧស្សាហកម្មធុនធ្ងន់ផ្សេងទៀត ឧទា. គ្រឿងបង្គុំអេឡិចត្រូនិក, ផ្គុំ និងដំឡើងរថយន្ត, និងសំបកកង់រថយន្ត ជាដើម, **២).** ការបន្តកើនឡើងជាលំដាប់នៃផលិតកម្មកសិកម្ម ដែលផ្តល់លក្ខខ័ណ្ឌល្អប្រសើរដល់ការជំរុញឧស្សាហកម្មកែច្នៃ, **៣).** ការវិលត្រលប់មកវិញនៃពលករទេសន្តរប្រវេសន៍ ដែលនឹងជំរុញកម្លាំងប្រមូលផ្តុំនៃសន្និធិមូលធនដែលជាមូលដ្ឋានចាំបាច់ក្នុងការលើកកម្ពស់ឧស្សាហកម្ម និងទាក់ទាញវិនិយោគ, **៤).** ភាពល្អប្រសើរនៃលម្ហថវិកា និងការបន្តរក្សាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ និងនិរន្តរភាពនៃបំណុលសាធារណៈ បើទោះត្រូវឆ្លើយតបទៅនឹងការបន្តកើនឡើងជាលំដាប់នៃតម្រូវការចំណាយ ដើម្បីទ្រទ្រង់កិច្ចអភិវឌ្ឍន៍, និង **៥).** ភាពរឹងមាំ និងស្ថិរភាពនៃវិស័យហិរញ្ញវត្ថុ ថ្វីបើមានកម្មវិបាកពីការបង្ក្រាបសកម្មភាពឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុសកលនាពេលកន្លងមក ។

ជាទិសដៅយុទ្ធសាស្ត្រ និងគោលនយោបាយអាទិភាព, រាជរដ្ឋាភិបាលនៅតែបន្តប្រកាន់ខ្ជាប់នូវអភិក្រមចំនួន ២ នោះគឺ៖ (១). វិធានការឆ្លើយតបទៅនឹងបញ្ហាបន្ទាន់ចំពោះមុខ និងក្នុងរយៈពេលខ្លី ដោយផ្តោតលើការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ការរក្សាលំនឹងសកម្មភាពសង្គម-សេដ្ឋកិច្ច ពិសេសដោយសារបច្ច័យអវិជ្ជមាននៃសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា, ព្រមទាំងស្តារឡើងវិញនូវជីវភាពប្រជាជន ពោលគឺប្រជា-ពលរដ្ឋភៀសសឹក ដោយសារបញ្ហាជម្លោះព្រំដែនកម្ពុជា-ថៃ, និងការប្រែក្លាយបញ្ហាចំពោះមុខឱ្យទៅជាកាលានុ-វត្តភាពនៃការអភិវឌ្ឍ និង (២). ទិសដៅវិធានការគោលនយោបាយរយៈពេលមធ្យម និងវែងខាងមុខ ដោយផ្តោត លើបន្តដោះស្រាយជារចនាសម្ព័ន្ធ ក្នុងការជំរុញពិពិធកម្មសេដ្ឋកិច្ច, ការលើកកម្ពស់ភាពប្រកួតប្រជែង និងការកសាងភាពធន់សម្រាប់សង្គម-សេដ្ឋកិច្ច ។ ក្នុងនោះ, កម្ពុជាត្រូវយកចិត្តទុកដាក់លើឧបករណ៍វិធានការគោលនយោបាយ ដូចខាងក្រោម៖

**១). វិធានការគោលនយោបាយដោះស្រាយបញ្ហាចំពោះមុខ** ដោយផ្តោតលើការបន្តតាមដាន ដោយខ្ជាប់ខ្ជួនអំពីការវិវត្តនៃស្ថានភាពភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ច ពិសេសសង្គ្រាម នៅតំបន់មជ្ឈិមបូព៌ា, របបពាណិជ្ជកម្មសកល, និងបញ្ហាព្រំដែនកម្ពុជា-ថៃ និងកម្មវិបាកមកលើស្ថានភាពសេដ្ឋកិច្ចក្នុងស្រុក, ទន្ទឹមនឹងរក្សាលំនឹងសង្គម-សេដ្ឋកិច្ច ឱ្យបានក្នុងកម្រិតអប្បបរមាមួយ តាមរយៈការអនុវត្តវិធានការពាក់ព័ន្ធនឹងការផ្គត់ផ្គង់ប្រេង និងការកាត់បន្ថយនៃការឡើងថ្លៃប្រេងឥន្ធនៈនៅកម្ពុជា, ការបន្តអនុវត្តយន្តការកម្មវិធីអន្តរាគមន៍ និង គាំពារសង្គម សម្រាប់គ្រួសារប្រជាពលរដ្ឋភៀសសឹក តាមរយៈការផ្តល់សាច់ប្រាក់ឧបត្ថម្ភជូនគ្រួសារភៀសសឹក, ការស្តារឡើងវិញនូវលំនៅឋានពលរដ្ឋដែលខូចខាត និង ការរៀបចំការតាំងលំនៅឋានបណ្តោះអាសន្នរយៈពេលវែង, និងការបន្តអនុវត្តគោលនយោបាយគាំពារដល់ ពលករទេសន្តរប្រវេសន៍ពីថៃ ។ ទន្ទឹមនេះ កម្ពុជា ក៏បាននិងកំពុងខិតខំប្រែក្លាយបញ្ហាចំពោះមុខឱ្យទៅជាកាលានុវត្តភាពនៃការអភិវឌ្ឍ តាមរយៈការជំរុញ

ការកែច្នៃសម្រាប់ជំនួសការនាំចូល និង ជំរុញការនាំចេញ ក្នុងវិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម, ការលើកកម្ពស់ផលិតកម្មក្នុងស្រុក សំដៅកាត់បន្ថយ ជាអតិបរមានូវការពឹងផ្អែកលើទំនិញនាំចូលពីក្រៅប្រទេស, និងការបន្តឆ្ពោះទៅបោសសម្អាតទាំងស្រុងនូវបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា ។

២). **វិធានការគោលនយោបាយហិរញ្ញវត្ថុសាធារណៈ** ដោយផ្តោតលើការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលមានភាពប្រយ័ត្នប្រយែង និងមានភាពបត់បែនខ្ពស់ ឆ្លើយតបទៅនឹងតម្រូវការអន្តរាគមន៍ ។ ក្របខ័ណ្ឌចំណូល នឹងផ្តោតលើកិច្ចប្រឹងប្រែងពង្រឹងការកៀរគរចំណូល ដោយមិនបង្កវិការភាពដល់សកម្មភាពសេដ្ឋកិច្ច និងអាជីវកម្ម គួបផ្សំនឹងការបន្តធ្វើទំនើបកាវូបនីយកម្មនៃប្រព័ន្ធរដ្ឋបាលពន្ធ និងការបន្តពង្រឹងអនុលោមភាព និងសេវាអ្នកជាប់ពន្ធ ។ ក្នុងក្របខ័ណ្ឌចំណាយ នឹងផ្តោតលើវិធានការចំណាយថវិកា និងចំណាយសារពើពន្ធ ក្នុងវិស័យអាទិភាព និងចាំបាច់បំផុត ពិសេសលើការស្តារ និងរក្សាលំនឹងជីវភាពប្រជាជន, រក្សាលំនឹងអាជីវកម្ម, និងការស្តារហេដ្ឋារចនាសម្ព័ន្ធចាំបាច់, និងក្នុងបុព្វហេតុការពារអធិបតេយ្យភាពជាតិ និង បូរណភាពទឹកដី ។ ជាមួយគ្នានេះ, ការពង្រឹងការផ្សារភ្ជាប់រវាងគោលនយោបាយ និងថវិកា និងកាន់តែបន្តយកចិត្តទុកដាក់ខ្ពស់ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពចំណាយ ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍផង និងចូលរួមរក្សាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ ផង ។

៣). **វិធានការគោលនយោបាយរូបិយវត្ថុ និងហិរញ្ញវត្ថុ** ដោយបន្តផ្តោតលើគោលនយោបាយរូបិយវត្ថុ ដើម្បីទ្រទ្រង់កំណើន តាមរយៈការជំរុញការផ្តល់ឥណទានក្នុងវិស័យសេដ្ឋកិច្ច ដែលមានផលិតភាពក្នុងគោលដៅបំផុសសកម្មភាពសេដ្ឋកិច្ច, ទន្ទឹមនឹងការដាក់ចេញនូវវិធានការបន្ធូរបន្ថយសម្ពាធបំណុល ពិសេសបំណុលរបស់គ្រួសារកៀសសឹក, និងបន្តតាមដាន និងវាយតម្លៃស្ថានភាពឥណទាន ដែលជាប់ពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍ សំដៅដាក់ចេញនូវវិធានការឆ្លើយតបជាក់លាក់ក្នុងករណីចាំបាច់ ។ ជាមួយគ្នានេះ, ការបន្តគ្រប់គ្រងស្ថិរភាពថ្លៃ និងវាយតម្លៃជាប្រចាំអំពីសុខុមាលភាពនៃប្រព័ន្ធហិរញ្ញវត្ថុ ជារួម ពោលទាំងផ្នែកធនាគារ និងមិនមែនធនាគារ គឺកាន់តែមានភាពចាំបាច់ ដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ និងបញ្ចៀសហានិភ័យជាប្រព័ន្ធ ។

៤). **វិធានការគោលនយោបាយដោះស្រាយបញ្ហារចនាសម្ព័ន្ធ** តាមរយៈការពង្រឹងគ្រប់ការដ្ឋានកែទម្រង់គន្លឹះ ការបន្តពង្រឹងយន្តការអនុវត្ត និងតាមដាន និងវាយតម្លៃ **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១»** រួមជាមួយការដាក់ចេញ និងអនុវត្តនូវ **«កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និងពង្រឹងភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់ របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា»** និង **«កម្មវិធីជំរុញការកែលម្អបរិយាកាសធុរកិច្ច និង វិនិយោគនៅកម្ពុជា ឆ្នាំ ២០២៥-២០២៨»** និងគោលនយោបាយពាក់ព័ន្ធផ្សេងទៀត នឹងកាន់តែមានសារសំខាន់ជាចលករក្នុងការជំរុញល្បឿន និងគាំពារកំណើនសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យម និងវែងខាងមុខ ។

# ៣

# យុទ្ធសាស្ត្រហិរញ្ញវត្ថុសាធារណៈ

«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៧-២០២៩» ឬហៅខ្លីថា «ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩» នេះ ដាក់ចេញនូវយុទ្ធសាស្ត្រហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល សម្រាប់រយៈពេលមធ្យម ដោយកំណត់នូវ **ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ** (Fiscal Policy Stance), **វិធានហិរញ្ញវត្ថុសាធារណៈ** (Fiscal Rules), និង **អាទិភាពគោលនយោបាយ** (Policy Priorities) ។

## ៣.១. ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ក្នុងបរិការណ៍ដែលស្ថានភាពសេដ្ឋកិច្ចកម្ពុជាកំពុងប្រឈមនឹងភាពមិនប្រាកដប្រជា និងហានិភ័យខ្ពស់ រួមមានការរំលោភលើអធិបតេយ្យជាតិ និងបូរណភាពទឹកដីរបស់ប្រទេសកម្ពុជា, ការបន្តបិទខ្ទប់ព្រំដែនគោកកម្ពុជា-ថៃ និងផលជះអវិជ្ជមានពីសង្គ្រាមនៅមជ្ឈិមបូព៌ា, **ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ** សម្រាប់រយៈពេលមធ្យមខាងមុខ នឹងត្រូវរៀបចំឡើងវិញដោយប្រកាន់យកនូវជំហរថ្មីគឺ **«ជំហរអព្យាក្រឹត** (Neutral Stance)» ។ ជំហរនេះ មានគោលបំណងធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម ដោយបន្តរក្សាស្ថិរភាពសេដ្ឋកិច្ច និងតុល្យភាពថវិកា ដោយពុំប្រើប្រាស់ប្រាក់សន្សំរបស់រាជរដ្ឋាភិបាល ។ ការកំណត់យក **ជំហរអព្យាក្រឹត** នេះ មានភាពសមស្របទៅនឹងស្ថានភាពមិនប្រាកដប្រជាខ្ពស់ ខណៈប្រភពហិរញ្ញប្បទានត្រូវបានរំពឹងទុកថានឹងថមថយ ដែលតម្រូវឱ្យចំណាយសាធារណៈ កើនស្របតាមលទ្ធភាពធនធានថវិកា ដើម្បីរក្សាភាពឆ្លើយតបបានទៅនឹងបរិការណ៍ដែលមិនទាន់អាចប្រមើលឃើញ ដោយចៀសវាងនូវការគ្រោងចំណាយខ្ពស់ជាងតម្រូវការជាក់ស្តែង (Over-commitment) និងការបង្កើនហិរញ្ញប្បទានបន្ថែមដោយគំហុក ។ ដោយឡែក, ជំហរនេះអាចនឹងផ្លាស់ប្តូរស្របតាមការវិវត្តរបស់ស្ថានការណ៍ជាក់ស្តែង នៅពេលរៀបចំច្បាប់ថវិកាប្រចាំឆ្នាំ ២០២៧ ។

ឈរលើជំហរគោលនយោបាយនេះ, រាជរដ្ឋាភិបាលក៏នឹងបន្តខិតខំបង្កើនប្រសិទ្ធភាព និងពង្រឹងការកៀរគរចំណូលគ្រប់ប្រភេទ តាមរយៈការជំរុញការអនុវត្ត **«យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា»** ដែលជាមូលដ្ឋានសំខាន់ក្នុងការគ្រប់គ្រងការប្រមូលចំណូល, ការកែទម្រង់ស៊ីជម្រៅទៅលើផ្នែករដ្ឋបាល, និងទំនើបភាវូបនីយកម្មប្រព័ន្ធរដ្ឋបាលប្រមូលចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ។ បន្ថែមលើនេះ, រាជរដ្ឋាភិបាល នឹងបន្តពង្រីកមូលដ្ឋានចំណូល ប្រកបដោយភាពហ្មត់ចត់ ព្រមទាំងបន្តអនុវត្តវិធានការលើកទឹកចិត្តនានាដែលមានស្រាប់របស់រាជរដ្ឋាភិបាល និងចាប់អនុវត្តឡើងវិញនូវអត្រាពន្ធជាធរមានលើផលិតផលគេលសិលាក្រោយពីមានការបញ្ចុះអត្រាក្នុងឆ្នាំ ២០២៦ ។ សម្រាប់រយៈពេលមធ្យម រាជរដ្ឋាភិបាលនឹងប្រកាន់ខ្ជាប់នូវភាពប្រយ័ត្នប្រយែងខ្ពស់ ចំពោះករណីនៃការអនុគ្រោះពន្ធថ្មីណាមួយ ដោយខិតខំបញ្ចៀសនូវការបង្កើនចំណាយសារពើពន្ធជាគំហុកបន្ថែមទៀត ។ ទន្ទឹមនឹងការតឹងតៀតផ្នែកចំណាយសារពើពន្ធនេះ,

ការផ្តល់នូវការលើកទឹកចិត្តពន្ធមានស្រាប់ដែលខានពុំបាន គឺត្រូវតែប្រើឱ្យចំគោលដៅ និងមានប្រសិទ្ធភាពខ្ពស់ ជាពិសេស ផ្តោតលើវិស័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ និងក្រុមងាយរងគ្រោះ ដើម្បីធានានូវការរក្សាលំនឹងសង្គម-សេដ្ឋកិច្ច ដែលមិនបង្កផលប៉ះពាល់ដល់ចីរភាពហិរញ្ញវត្ថុសាធារណៈ ខណៈរាជរដ្ឋាភិបាលក៏នឹងបន្តរៀបចំការសិក្សា និងការវាយតម្លៃលើប្រសិទ្ធភាពនៃវិធានការលើកទឹកចិត្តទាំងឡាយ ហើយលើមូលដ្ឋាននៃការសិក្សា និងវាយតម្លៃនេះ, រៀបចំដាក់ចេញនូវវិធានការធ្វើវិចារណកម្មតាមការចាំបាច់ ។

ទន្ទឹមនេះ, រាជរដ្ឋាភិបាលនឹងបន្តផ្តោតជាសំខាន់លើការបន្តពង្រឹងស័ក្តិសិទ្ធិភាពថវិកា ជាមួយនឹងការបន្តលើកកម្ពស់ប្រសិទ្ធភាពចំណាយ, ទាំងកម្រិតវិភាជន៍ និងកម្រិតប្រតិបត្តិការ, តាមរយៈការបន្តធ្វើអាទិភាវូបនីយកម្មចំណាយ ដោយក្នុងនោះ, ក្របខ័ណ្ឌចំណាយសាធារណៈ នឹងត្រូវរៀបចំឡើងដើម្បីតម្រង់ទិសធនធាន ទៅកាន់មុខសញ្ញាដែលជាអាទិភាពសំខាន់ៗចំពោះមុខ, ជាពិសេសគឺ ការពង្រឹងសមត្ថភាពការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី, ការរក្សានូវលម្ហថវិកាសម្រាប់ធ្វើអន្តរាគមន៍សង្គម-សេដ្ឋកិច្ចនៅពេលកាលៈទេសៈតម្រូវ, និងធានាលទ្ធភាពក្នុងការទ្រទ្រង់ដំណើរការនៃកិច្ចអភិវឌ្ឍន៍ ព្រមទាំងនិរន្តរភាពប្រតិបត្តិការការងារ និងការអនុវត្តកម្មវិធីគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ស្របតាមទិសដៅជាយុទ្ធសាស្ត្រដែលបានដាក់ចេញនៅក្នុង «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**» របស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ។

ផ្អែកលើមូលដ្ឋាននៃការអនុវត្ត **«ជំហរអព្យាក្រឹត»** នេះ, ឱនភាពថវិកា ក្នុងរយៈពេលមធ្យម នឹងមានការរួមតូច ឆៀបនឹងឆ្នាំ ២០២៦ **ដោយរាជរដ្ឋាភិបាល នឹងខិតខំប្រឹងប្រែង មិនដកប្រាក់សន្សំមកប្រើប្រាស់ ដើម្បីកុំឱ្យស្រកស្រុតបន្ថែមទៀត, លើកលែងតែក្នុងករណីចាំបាច់បំផុត ដែលសភាពការណ៍តម្រូវឱ្យប្រើប្រាស់ប្រាក់សន្សំរបស់រាជរដ្ឋាភិបាល ។**

## ៣.២. វិធានហិរញ្ញវត្ថុសាធារណៈ

**វិធានហិរញ្ញវត្ថុសាធារណៈ** គឺជាផ្នែកមួយដ៏សំខាន់ ក្នុងការពង្រឹងប្រសិទ្ធភាពនៃការរៀបចំក្របខ័ណ្ឌថវិកា, ពង្រឹងតម្លាភាព និងគណនេយ្យភាព, លើកកម្ពស់វិន័យ និងស្មារតីប្រុងប្រយ័ត្នក្នុងការអនុវត្តថវិកា និងជាពិសេស ធានានូវចីរភាពហិរញ្ញវត្ថុសាធារណៈសម្រាប់រយៈពេលមធ្យម ។ ក្នុងន័យនេះ, **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩** ត្រូវគោរពឱ្យបាននូវលក្ខខណ្ឌនៃ **វិធានហិរញ្ញវត្ថុសាធារណៈ** ដែលបានកំណត់លើសូចនាករហិរញ្ញវត្ថុសាធារណៈសំខាន់ៗ ដើម្បីពង្រឹងស័ក្តិសិទ្ធិភាពថវិកា ស្របតាមជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ។ ទោះជាយ៉ាងនេះក្តី, ការអនុវត្ត **វិធានហិរញ្ញវត្ថុសាធារណៈ** អាចមានភាពទន់ភ្លន់ជាងការកំណត់ ក្នុងករណីប្រធានសក្តិ ដូចជា គ្រោះធម្មជាតិ, ការរីករាលដាលនៃជំងឺឆ្លងជាសកល, ការផ្ទុះឡើងនូវសង្គ្រាម, គ្រោះអាសន្នដែលមានកម្រិតធ្ងន់ធ្ងរ និងពុំអាចប៉ាន់ស្មានទុកជាមុន ឬ ជាភាពចាំបាច់ជាបន្ទាន់សម្រាប់បម្រើដល់ប្រយោជន៍ជាតិ ជាដើម ដើម្បីផ្តល់លទ្ធភាពគ្រប់គ្រាន់ដល់រាជរដ្ឋាភិបាលក្នុងការធ្វើអន្តរាគមន៍ និងដោះស្រាយបញ្ហាប្រឈមបានទាន់ពេល ។

ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ, **វិធានហិរញ្ញវត្ថុសាធារណៈ** ដែលត្រូវបានដាក់ចេញក្នុង **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩** នេះ ត្រូវបានបែងចែកជា ២ រួមមាន៖ **១). យុថ្កាហិរញ្ញវត្ថុសាធារណៈ** (Fiscal Anchor); និង **២). វិធានប្រតិបត្តិ** (Operational Rules) ។

### ក. យុទ្ធាហិរញ្ញវត្ថុសាធារណៈ

**យុទ្ធាហិរញ្ញវត្ថុសាធារណៈ** គឺជាវិធានហិរញ្ញវត្ថុសាធារណៈ ដែលកំណត់ពិតានលើសូចនាករបំណុលសាធារណៈ ក្នុងកម្រិតណាមួយ ដែលធានាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម ។ ដូចជាឆ្នាំកន្លងទៅដែរ, សម្រាប់រយៈពេលមធ្យម ឆ្នាំ ២០២៧-២០២៩, **យុទ្ធាហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា** ត្រូវបានកំណត់លើ **សូចនាករគន្លឹះ** ចំនួន ៦ ដោយក្នុងនោះ, សូចនាករចំនួន ៥ ជាសូចនាករក្នុងការវិភាគចីរភាពបំណុលសាធារណៈ (Debt Sustainability Analysis – DSA) របស់កម្ពុជា, រួមមាន៖

(១). **អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស.** ត្រឹមកម្រិត **៥៥%;**

(២). **អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផ.ស.ស.** ត្រឹមកម្រិត **៤០%;**

(៣). **អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងការនាំចេញ** ត្រឹមកម្រិត **១៨០%;**

(៤). **អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងការនាំចេញ** ត្រឹមកម្រិត **១៥%;**

(៥). **អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងចំណូលថវិកាជាតិ** ត្រឹមកម្រិត **១៨%;** និង

(៦). **អនុបាតតម្លៃចារឹកនៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស.** ត្រឹមកម្រិត **៦៥%** ។

### ខ. វិធានប្រតិបត្តិ

បន្ថែមលើនេះ, **វិធានប្រតិបត្តិ** ក៏ត្រូវបានដាក់ចេញ ដោយប្រើប្រាស់វិធានតុល្យភាពថវិកា (**Budget Balance Rule**) ដែលបន្តជាវិធានសមស្របសម្រាប់បរិការណ៍កម្ពុជា ក្នុងការរៀបចំក្របខ័ណ្ឌថវិកាប្រចាំឆ្នាំ ហើយមានភាពផ្សារភ្ជាប់ខ្ពស់ទៅនឹងយុទ្ធាហិរញ្ញវត្ថុសាធារណៈដែលបានដាក់ចេញខាងលើ ។ សម្រាប់រយៈពេលមធ្យម ឆ្នាំ ២០២៧-២០២៩, រាជរដ្ឋាភិបាលបានបន្តកំណត់យកពិតាន **ឱនភាពថវិកាសរុប មិនត្រូវលើសពីកម្រិត -៥,០% នៃ ផ.ស.ស.** ដែលត្រូវជាប្រមាណ **-៣,៥% នៃ ផ.ស.ស. បើគិតក្នុងទម្រង់ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS)** ។ ការកំណត់កម្រិតឱនភាពថវិកានេះ ធ្វើឡើងក្នុងន័យបន្តរក្សាចីរភាពបំណុលសាធារណៈ និងធានានូវចីរភាពហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ស្របតាមជំហរគោលនយោបាយអព្យាក្រឹត ដើម្បីត្រៀមឆ្លើយតបប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាខ្ពស់ ដោយផ្តល់លទ្ធភាពគ្រប់គ្រាន់សម្រាប់ការអនុវត្តគោលនយោបាយអាទិភាព សំដៅការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី, ការរក្សាលំនឹងជីវភាពរបស់ប្រជាជន និង ការជំរុញកំណើនសេដ្ឋកិច្ច ព្រមទាំងការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការអភិវឌ្ឍសង្គម ជារួម ។

**តារាងទី ៤៖ វិធានហិរញ្ញវត្ថុសាធារណៈ**

| វិធានហិរញ្ញវត្ថុសាធារណៈ | |
|---|---|
| យុទ្ធាហិរញ្ញវត្ថុសាធារណៈ | (១). អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស. **ត្រឹមកម្រិត ៥៥%;**<br>(២). អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផ.ស.ស. **ត្រឹមកម្រិត ៤០%;**<br>(៣). អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងការនាំចេញ **ត្រឹមកម្រិត ១៨០%;**<br>(៤). អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងការនាំចេញ **ត្រឹមកម្រិត ១៥%;**<br>(៥). អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងចំណូលថវិកាជាតិ **ត្រឹមកម្រិត ១៨%;** និង<br>(៦). អនុបាតតម្លៃចារឹកនៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស. **ត្រឹមកម្រិត ៦៥%** ។ |
| វិធានប្រតិបត្តិ | ឱនភាពថវិកាសរុប មិនត្រូវលើសពី**កម្រិត -៥,០% នៃ ផ.ស.ស.** ឬ ត្រូវជា **-៣,៥% នៃ ផ.ស.ស. ក្នុងទម្រង់ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល** (GFS) ។ |

## ៣.៣. អាទិភាពគោលនយោបាយ

ជាទិសដៅយុទ្ធសាស្ត្រ និងគោលនយោបាយ, ការជំរុញអនុវត្តឱ្យសម្រេចបានជោគជ័យនូវ **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១»** នៅតែជាអាទិភាព ខណៈរាជរដ្ឋាភិបាល បានដាក់ចេញ និងកំពុងអនុវត្តនូវ **«កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និង ពង្រឹងភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់ របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា»** និង **«កម្មវិធីជំរុញការកែលម្អបរិយាកាសសម្រាប់ធុរកិច្ច និងការវិនិយោគនៅកម្ពុជា ឆ្នាំ ២០២៥-២០២៨»** សំដៅរួមចំណែកដោះស្រាយបញ្ហាជារចនាសម្ព័ន្ធសំខាន់ៗ ឱ្យកាន់តែចំទិសដៅ និងប្រសិទ្ធភាពស្របតាមបរិការណ៍សង្គម-សេដ្ឋកិច្ចកម្ពុជា, តំបន់ និងសកល កំពុងវិវត្តយ៉ាងឆាប់រហ័ស និងពិបាកប៉ាន់ស្មាន ។ ក្នុងន័យនេះ, **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩** នឹងចូលរួមគាំទ្រអាទិភាពគោលនយោបាយចម្បងៗ ចំនួន៧ ដូចខាងក្រោម៖

១). **ការការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី ព្រមទាំងធានាស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច៖** រាជរដ្ឋាភិបាល នឹងបន្តផ្តល់អាទិភាពដល់កិច្ចការការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី, ការការពារសន្តិភាព និងស្ថិរភាពនយោបាយ ដែលជាមូលដ្ឋានគ្រឹះ សម្រាប់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, សមិទ្ធផលសង្គម និងជំរុញការដោះស្រាយបញ្ហាគ្រោះអាសន្ននានា ក្នុងសង្គម ។

២). **ការដោះស្រាយលំនឹងជីវភាពប្រជាជន៖** រាជរដ្ឋាភិបាល នឹងបន្តយកចិត្តទុកដាក់លើការធានាសន្តិសុខស្បៀង, ការគាំពារ និងការបង្កើតការងារជូនប្រជាជន ជាពិសេសពលករទេសន្តរប្រវេសន៍ត្រលប់ពី

ថៃ ព្រមទាំងវិធានការគាំពារសង្គម សម្រាប់គ្រួសារភៀសសឹក ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាល នឹងបន្តគាំទ្រពលរដ្ឋ អាជីវករខ្នាតតូច និងកសិករ ដើម្បីកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលសេដ្ឋកិច្ច និងវិបត្តិនានា សំដៅបង្កើនប្រសិទ្ធភាព និងពង្រីកវិសាលភាពនៃប្រព័ន្ធគាំពារសង្គម និងការផ្តល់សេវាសង្គមចាំបាច់នានា ។

៣). **ការជំរុញពិពិធកម្មសេដ្ឋកិច្ច និងអភិវឌ្ឍប្រភពថ្មីនៃកំណើន៖** រាជរដ្ឋាភិបាល នឹងបន្តជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និងអភិវឌ្ឍប្រភពថ្មីនៃកំណើន ដោយផ្តោតលើការពង្រឹងមូលដ្ឋានគាំទ្រកំណើនប្រកបដោយចីរភាព តាមរយៈការជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តគ្រប់ប្រភេទ, ការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មក្នុងស្រុក, និង ការលើកកម្ពស់ការកែច្នៃ សម្រាប់ជំនួសការនាំចូល និងជំរុញការនាំចេញ ដើម្បីបង្កើនតម្លៃបន្ថែម និងពង្រឹងភាពធន់នៃសេដ្ឋកិច្ច ស្របតាមអាទិភាពគោល-នយោបាយ ដែលបានដាក់ចេញ ។

៤). **ការពង្រឹងបរិយាកាសធុរកិច្ច និងការលើកកម្ពស់វិស័យឯកជន៖** រាជរដ្ឋាភិបាល នឹងបន្តកែលម្អបរិយាកាសធុរកិច្ច និងជំរុញការអភិវឌ្ឍវិស័យឯកជន តាមរយៈការអនុវត្តយន្តការហិរញ្ញប្បទានដែលមានលក្ខខណ្ឌអំណោយផល សំដៅគាំទ្រការពង្រីកអាជីវកម្ម និងបង្កើនផលិតភាព សម្រាប់ទាក់ទាញវិនិយោគដែលមានគុណភាពខ្ពស់ ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាល, ម្ខាង នឹងបន្តពង្រឹងការអនុវត្តក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដើម្បីធានាបរិយាកាសប្រកួតប្រជែង ប្រកបដោយតម្លាភាព ស្មើភាព និងយុត្តិធម៌, និងម្ខាងទៀត លើកកម្ពស់កិត្យានុភាព និងភាពជឿជាក់របស់កម្ពុជាតាមរយៈការពង្រឹងយន្តការទប់ស្កាត់ និងបង្ក្រាបសកម្មភាពឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដែលអាចប៉ះពាល់ដល់ទំនុកចិត្តវិនិយោគិន និងសុវត្ថិភាពនៃប្រតិបត្តិការធុរកិច្ច ។

៥). **ការអភិវឌ្ឍមូលធនមនុស្ស និងសង្គម៖** រាជរដ្ឋាភិបាល នឹងបន្តផ្តោតលើការអភិវឌ្ឍមូលធនមនុស្ស និងសង្គម តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសគ្រប់កម្រិត ដើម្បីគាំទ្រផលិតកម្មដែលមានតម្លៃបន្ថែមខ្ពស់ និងទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព បរិយាប័ន្ន និងភាពធន់ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាល នឹងបន្តលើកកម្ពស់ភាពជាពលរដ្ឋក្នុងសង្គម វប្បធម៌ និងសុខុមាលភាពប្រជាជន ព្រមទាំងបន្តជំរុញការលើកកម្ពស់សុខុមាលភាពសង្គម តាមរយៈការពង្រឹងប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសង្គមចាំបាច់ ។

៦). **ការជំរុញបរិវត្តកម្មឌីជីថល និងការអភិវឌ្ឍបៃតង៖** រាជរដ្ឋាភិបាល នឹងបន្តជំរុញបរិវត្តកម្មឌីជីថល និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដើម្បីជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល បង្កើនប្រសិទ្ធភាពនៃសេវាសាធារណៈ លើកកម្ពស់ផលិតភាព សំដៅកសាងរដ្ឋាភិបាល និងពលរដ្ឋឌីជីថលប្រកបដោយចីរភាព និងភាពធន់ ព្រមទាំងការលើកកម្ពស់ការអភិវឌ្ឍបៃតង ដើម្បីចូលរួមចំណែកដល់ការសម្រេចបាននូវអព្យាក្រឹតកាបូន ។

៧). **ការពង្រឹងអភិបាលកិច្ច និងស្ថាប័ន៖** រាជរដ្ឋាភិបាល នឹងបន្តពង្រឹងអភិបាលកិច្ច និងប្រសិទ្ធភាពស្ថាប័ន តាមរយៈការអនុវត្តកម្មវិធីកែទម្រង់មុតស្រួច រួមមាន កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, និងកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីពង្រឹងតម្លាភាព គណនេយ្យ-ភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ សំដៅគាំទ្រកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព ។

៤

# ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

## ៤.១. ការអនុវត្តថវិកា ឆ្នាំ ២០២៥ និង ២០២៦

### ក. ការអនុវត្តថវិកា ឆ្នាំ ២០២៥

សម្រាប់ឆ្នាំ ២០២៥, **លទ្ធផលនៃការប្រមូលចំណូលសរុបថវិការដ្ឋ** (តួលេខបណ្ដោះអាសន្ន) សម្រេចបានប្រមាណ ១៦,២៩% នៃ ផ.ស.ស. ដែលមានកំណើនប្រមាណ ១១,៩% ធៀបនឹងលទ្ធផលឆ្នាំ ២០២៤ ។ ការអនុវត្តចំណូលសរុបនៅឆ្នាំ ២០២៥ បានបង្ហាញនូវភាពប្រសើរឡើង ស្របគ្នាទៅនឹងបរិការណ៍នៃការស្ដារឡើងវិញជាបន្តបន្ទាប់នៃសកម្មភាពសេដ្ឋកិច្ច និងពាណិជ្ជកម្មក្រៅប្រទេស ដែលបានគាំទ្រដល់មូលដ្ឋានចំណូលសារពើពន្ធឱ្យកាន់តែទូលំទូលាយ និងមានស្ថិរភាព ។

ក្នុងនោះ, **ចំណូលចរន្ត** សម្រេចបានកំណើនប្រសើរ, ពោលគឺក្នុងអត្រា ១០,៥% ធៀបនឹងលទ្ធផលឆ្នាំ ២០២៤, សមមូលនឹង ១៥,០៣% នៃ ផ.ស.ស. និង ១០១,៨% នៃច្បាប់ថវិកាឆ្នាំ ២០២៥ ដោយសារ ប្រសិទ្ធភាពនៃការប្រមូលចំណូលក្នុងឆ្នាំ ២០២៥ ក្នុងបរិការណ៍សេដ្ឋកិច្ចមានជវភាពប្រសើរជារួម ទោះបីមានភាពមិនស្មើគ្នាតាមវិស័យមួយចំនួនក៏ដោយ ។ កំណើននេះ ត្រូវបានទ្រទ្រង់ដោយកត្តាចម្បងចំនួន ២ រួមមានៈ **១).** ការប្រមូលពន្ធនាំចូលដែលសម្រេចបានលទ្ធផលប្រសើរលើគ្រប់មុខទំនិញសំខាន់ៗ ស្របតាមការកើនឡើងនៃតម្រូវការនាំចូល និងសកម្មភាពពាណិជ្ជកម្មក្រៅប្រទេស, និង **២).** ការរក្សាបាននិន្នាការល្អប្រសើរនៃចំណូលមិនមែនសារពើពន្ធ, ជាពិសេសពីប្រភពចំណូលសំខាន់ៗ ដូចជាៈ ភាគលាភសហគ្រាសសាធារណៈ និងចំណូលពីធនធានធម្មជាតិ ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញចំណូលសរុបឱ្យលើសផែនការ ។ ជាក់ស្ដែង, ទោះបីវិស័យជាចន្ទល់កំណើនសេដ្ឋកិច្ចមួយចំនួន ដូចជា កសិកម្ម, ទេសចរណ៍, កាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ទទួលបានការអនុគ្រោះ និងលើកលែងពន្ធ ដើម្បីគាំទ្រការស្ដារឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច, ក៏សមិទ្ធផលចំណូលចរន្តនៅតែរក្សាបាននូវនិន្នាការល្អប្រសើរ និងសម្រេចបានកំណើនក្នុងរង្វង់ពីរខ្ទង់ ដែលទ្រទ្រង់ដោយវិស័យជាប្រភពចំណូលសំខាន់ក្នុងស្រុកមួយចំនួន ដូចជា ហិរញ្ញវត្ថុ, បដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ, លក់ដុំ-រាយ និងសំណង់ ដែលសម្រេចបានកំណើនមួយក្នុងកម្រិតមធ្យម ។

បន្ថែមលើនេះ, ការអនុវត្តវិធានការបន្ធូរបន្ថយបន្ទុកពន្ធ និងការពង្រីកវិសាលភាពនៃ ចំណាយសារពើពន្ធ (Tax expenditures) បានរួមចំណែកគាំទ្រជីវភាពប្រជាជន និងលើកកម្ពស់បរិយាកាសធុរកិច្ចក្នុងបរិការណ៍សេដ្ឋកិច្ចសកល ដែលនៅតែមានភាពមិនប្រាកដប្រជា ។ ជាមួយគ្នានេះ, ការបន្តពង្រឹងប្រសិទ្ធភាពរដ្ឋបាលប្រមូលចំណូល និងការកែលម្អអនុលោមភាពពន្ធដារ ជាពិសេសតាមរយៈការប្រើប្រាស់ប្រព័ន្ធឌីជីថល និងការត្រួតពិនិត្យមានប្រសិទ្ធភាព បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកៀរគរចំណូលឱ្យអស់សក្ដានុពល ។ ជារួម, លទ្ធផលចំណូលចរន្តឆ្នាំ ២០២៥ បង្ហាញថា រាជរដ្ឋាភិបាលអាចរក្សាបាននូវកំណើនចំណូលយ៉ាងរឹងមាំ

និងមានគុណភាព បើទោះបីជាស្ថិតក្រោមសម្ពាធពីការអនុវត្តគោលនយោបាយលើកទឹកចិត្តពន្ធ និងបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចមួយចំនួន ជាពិសេសពីកត្តាខាងក្រៅ និងការបិទខ្ទប់ព្រំដែនគោកកម្ពុជា-ថៃ ក្តី ។

ទន្ទឹមនេះ, រាជរដ្ឋាភិបាលបានអនុវត្តវិធានការគ្រប់គ្រងចំណាយថវិកា ដោយផ្អែកលើគោលការណ៍វិន័យថវិកា និងការកំណត់អាទិភាពចំណាយសាធារណៈ ។ ជាមួយគ្នានេះ, ការអនុវត្តថវិកាត្រូវបានផ្តោតលើការពង្រឹងស័ក្តិសិទ្ធិភាពចំណាយ ទាំងក្នុងដំណាក់កាលរៀបចំ និងអនុវត្តថវិកា សំដៅធានាធនធានសាធារណៈត្រូវបានវិភាជ និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ ឈរលើមូលដ្ឋាននេះ, ចំណាយត្រូវបានអនុវត្តដោយផ្តល់អាទិភាពលើ ការការពារអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដី, ការពង្រឹងសន្តិសុខ, ការរក្សាលំនឹងជីវភាពប្រជាជន តាមរយៈប្រព័ន្ធគាំពារសង្គម, ការអភិវឌ្ឍមូលធនមនុស្ស និងការលើកកម្ពស់ផលិតភាព, ព្រមទាំងការគាំទ្រការស្តារ និងជំរុញកំណើនសេដ្ឋកិច្ច ។ ជាលទ្ធផល, **ចំណាយក្នុងឆ្នាំ ២០២៥** ត្រូវបានប៉ាន់ស្មានថាអនុវត្ត ក្នុងទំហំប្រមាណ ១៧,៥៨% នៃ ផ.ស.ស. (តួលេខបណ្តោះអាសន្ន) ទាបជាងការគ្រោងក្នុងច្បាប់បន្ថែម ពោលគឺស្មើនឹងប្រមាណ ៩៥,៣% នៃច្បាប់ថវិកា ហើយ **ឱនភាពថវិកាឆ្នាំ ២០២៥** ត្រូវបានប៉ាន់ស្មានថាស្ថិតក្នុងរង្វង់ -១,២៩% នៃ ផ.ស.ស. ទាបជាងការគ្រោងក្នុងច្បាប់ថវិកាប្រមាណ -១,៨០ ពិន្ទុភាគរយនៃ ផ.ស.ស. ដែលមានកំណត់ក្នុងច្បាប់ថវិកា, ឱនភាពថវិកាត្រូវបានគ្រោងក្នុងកម្រិត -៣,០៩% នៃ ផ.ស.ស. ដែលការណ៍នេះបានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលមានអតិរេកសាច់ប្រាក់មួយចំនួន ។ ការវាយតម្លៃការអនុវត្តថវិកាឆ្នាំ ២០២៥ និងតួលេខចុងក្រោយ នឹងឆ្លុះបញ្ចាំងក្នុង **សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥** ក្នុងពេលខាងមុខ ។

## ខ. ការប៉ាន់ស្មានការអនុវត្តថវិកាឆ្នាំ ២០២៦

ក្នុងឆ្នាំ ២០២៦ នេះ, **ចំណូលសរុប** ត្រូវបានប៉ាន់ស្មានថានឹងពុំមានកំណើននោះទេ ធៀបនឹងលទ្ធផលអនុវត្ត (បណ្តោះអាសន្ន) ឆ្នាំ ២០២៥ ដោយសារការថមថយនូវផ្នែកចំណូលផ្សេងៗ ខណៈចំណូលចរន្តត្រូវបានរំពឹងទុកថានឹងមានកំណើន ។ ជាក់ស្តែង, **ចំណូលចរន្ត** ត្រូវបានប៉ាន់ស្មានថានឹងបន្តកើនឡើងក្នុងអត្រា ៤,៧% សមមូលនឹងប្រមាណ ១៤,៧៣% នៃ ផ.ស.ស. និង ១០២,៥% នៃច្បាប់ថវិកា ដោយផ្អែកលើការវាយតម្លៃប្រកបដោយភាពប្រុងប្រយ័ត្ន លើនិន្នាការសេដ្ឋកិច្ច និងសមត្ថភាពប្រមូលចំណូលជាក់ស្តែង ស្របពេលដែលរាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការផ្នែកសារពើពន្ធមួយចំនួន សំដៅកាត់បន្ថយបញ្ហាប្រឈមនៃការកើនថ្លៃថាមពលសកល ។ ក្នុងនោះ, ចំណូលពន្ធដារ ត្រូវបានរំពឹងថានឹងមានកំណើនល្អ គាំទ្រចម្បងដោយការសម្រេចបាននូវលទ្ធផលយ៉ាងប្រសើរនៃពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ខណៈ ចំណូលគយ និងរដ្ឋាករកម្ពុជា ត្រូវបានរំពឹងថានឹងថមថយ ចំពោះមុខនៃសម្ពាធពីវិបត្តិថាមពល និងការកើននៃចំណាយសារពើពន្ធ ។ ទន្ទឹមនេះ, ចំណូលមិនមែនសារពើពន្ធ ត្រូវបានរំពឹងថានឹងបន្តមាននិន្នាការល្អ ដោយមានការគាំទ្រពីប្រភពចំណូលសំខាន់ៗ ដូចជា ប្រៃសណីយ៍ និង ទូរគមនាគមន៍, សម្បទានពីប្រេងកាត និងរ៉ែ និងចំណូលពីអាជ្ញាបណ្ណ ។

**ចំណាយសរុបឆ្នាំ ២០២៦** ត្រូវបានគ្រោងក្នុងច្បាប់ថវិកាថានឹងកើនក្នុងអត្រា ១៣,១% ធៀបនឹងលទ្ធផលអនុវត្តឆ្នាំ ២០២៥ សមមូលប្រមាណ ១៨,៦០% នៃ ផ.ស.ស. ដែលក្នុងនោះ ចំណាយចរន្ត មានទំហំប្រមាណ ១២,៤២% នៃ ផ.ស.ស. និង ចំណាយមូលធន មានទំហំប្រមាណ ៦,១៨% នៃ ផ.ស.ស. ។ ក្របខ័ណ្ឌចំណាយនេះ ត្រូវបានរៀបចំឡើង ដោយផ្តោតលើការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានសាធារណៈ និងការគាំទ្រគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល តាមរយៈការបន្តគ្រប់គ្រងចំណាយបុគ្គលិកយ៉ាងប្រុងប្រយ័ត្នស្របតាមគោលដៅបង្កើនប្រសិទ្ធភាពរដ្ឋបាលសាធារណៈ និងបែងចែកធនធានទៅគាំទ្រកម្មវិធីអន្តរាគមន៍ដែលមានអាទិភាពខ្ពស់ ។ ទន្ទឹមនេះ, ចំណាយមូលធនត្រូវបានបង្កើនផ្តោតលើគោលដៅ

យុទ្ធសាស្ត្រមួយចំនួន ជាពិសេស ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក ដើម្បីគាំទ្រការស្តារឡើងវិញនៃហេដ្ឋារចនាសម្ព័ន្ធ និងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ។ ជាលទ្ធផល, **ឱនភាពថវិកា ឆ្នាំ ២០២៦** ត្រូវបានប៉ាន់ស្មានថានឹងស្ថិតនៅក្នុងកម្រិតប្រមាណ -៣,៣៦% នៃ ផ.ស.ស. ដែលបង្ហាញអំពីការគាំទ្រស្ថិរភាពនៃកំណើនសេដ្ឋកិច្ច និងការរក្សាលំនឹងជីវភាពប្រជាជន ខណៈបន្តរក្សាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម ។ ឈរលើស្មារតីប្រុងប្រយ័ត្នខ្ពស់ចំពោះភាពមិនប្រាកដប្រជានៃបរិការណ៍សេដ្ឋកិច្ចសកល និងក្នុងស្រុក, ការអនុវត្តថវិកាឆ្នាំ ២០២៦ នឹងត្រូវបានគ្រប់គ្រងដោយ ហ្មត់ចត់ និងបុរេសកម្ម ស្របតាម **ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦** សំដៅធានាឱ្យការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលសម្រេចបានតាមផែនការគ្រោងទុក ។ ជាក់ស្តែង, ចំពោះមុខនៃការកើនថ្លៃប្រេងឥន្ធនៈ និងថ្លៃដើមលើការផលិតអគ្គិសនី, រាជរដ្ឋាភិបាល បានដាក់ចេញនូវសារាចរស្តីពីវិធានការសន្សំសំចៃលើការប្រើប្រាស់ប្រេងឥន្ធនៈ និងអគ្គិសនី ដែលក្នុងនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់ចេញនូវវិធានការរិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិកាថ្នាក់ជាតិផ្នែកចំណាយមិនមែនបន្ទុកបុគ្គលិករបស់ក្រសួង ស្ថាប័ន ថ្នាក់កណ្តាល ។

**តារាងទី ៥៖ លទ្ធផលការអនុវត្តថវិកាឆ្នាំ ២០២៤-២០២៦**

| | កំណើនប្រចាំឆ្នាំ | | | ភាគរយនៃ ផ.ស.ស. | | |
|---|---|---|---|---|---|---|
| | 2024 | 2025ប. | 2026គ. | 2024 | 2025ប. | 2026គ. |
| **ចំណូលសរុប** | -14.8% | 11.9% | 0.0% | 15.87% | 16.29% | 15.25% |
| **ចំណូលចរន្ត** | 3.5% | 10.5% | 4.7% | 14.82% | 15.03% | 14.73% |
| **ចំណូលសារពើពន្ធ** | 2.7% | 10.2% | 4.1% | 12.96% | 13.10% | 12.77% |
| អគ្គនាយកដ្ឋានពន្ធដារ | -3.9% | 2.2% | 9.7% | 7.43% | 6.97% | 7.15% |
| *ក្នុងនោះ៖ ថ្នាក់ក្រោមជាតិ* | *0.4%* | *1.7%* | *8.5%* | *1.03%* | *0.96%* | *0.98%* |
| អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | 13.3% | 20.9% | -2.2% | 5.53% | 6.14% | 5.62% |
| **ចំណូលមិនមែនសារពើពន្ធ** | 9.2% | 13.1% | 8.7% | 1.86% | 1.93% | 1.96% |
| *ក្នុងនោះ៖ ថ្នាក់ក្រោមជាតិ* | *-30.0%* | *4.7%* | *3.0%* | *0.17%* | *0.16%* | *0.16%* |
| **ចំណូលផ្សេងៗ** | -75.6% | 30.4% | -56.1% | 1.05% | 1.26% | 0.52% |
| **ចំណាយសរុប** | -10.9% | 8.5% | 13.1% | 17.66% | 17.58% | 18.60% |
| **ចំណាយចរន្ត** | 1.7% | 10.5% | 5.4% | 12.43% | 12.60% | 12.42% |
| **ចំណាយមូលធន** | -31.1% | 3.6% | 32.8% | 5.24% | 4.98% | 6.18% |
| **សមតុល្យថវិកា** | | | | -1.93% | -1.29% | -3.36% |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## គ. លទ្ធផលអនុវត្តថវិកាធៀបទៅនឹងវិធានហិរញ្ញវត្ថុសាធារណៈ

ជារួម, ការអនុវត្តថវិកាក្នុងឆ្នាំ ២០២៥ និង ២០២៦ ត្រូវបានប្រកាន់ខ្ជាប់នូវវិធានហិរញ្ញវត្ថុសាធារណៈដែលត្រូវបានដាក់ចេញ ក្នុងនោះ រាល់សូចនាករទាំងអស់ ត្រូវបានស្ថិតនៅក្រោមពិតានដែលបានកំណត់ ។ ជាក់ស្តែង, **បំណុលសាធារណៈសរុបរបស់កម្ពុជា សម្រាប់ឆ្នាំ ២០២៦ ជាតម្លៃបច្ចុប្បន្ន** ត្រូវបានប៉ាន់ស្មានថានឹងស្ថិតក្នុងកម្រិតប្រមាណ ១៩,២៥% នៃ ផ.ស.ស. និង**ជាតម្លៃចារឹក** ក្នុងកម្រិតប្រមាណ ២៦,៩២% នៃ ផ.ស.ស. ខណៈសូចនាករចំនួន ៤ ផ្សេងទៀតរបស់យុថ្កាហិរញ្ញវត្ថុសាធារណៈ ក៏ស្ថិតក្នុងកម្រិតទាបជាងពិតានដែលបានកំណត់ ។ បន្ថែមលើនេះ, ឱនភាពថវិកា សម្រាប់ឆ្នាំ ២០២៦ ក៏ត្រូវបានប៉ាន់ស្មានថានឹងស្ថិតក្រោមកម្រិតនៃការកំណត់ដោយវិធានប្រតិបត្តិ ផងដែរ ។

**តារាងទី ៦៖ សូចនាករវិធានហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៤-២០២៦**

| សូចនាករ | ពិតាន | 2024 | 2025ប. | 2026ប៉ាន់. |
|---|---|---|---|---|
| **I. យុថ្កាហិរញ្ញវត្ថុសាធារណៈ** | | | | |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស. | **55%** | 18.29% | 18.28% | 19.25% |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផ.ស.ស. | **40%** | 18.05% | 17.80% | 17.89% |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ | **180%** | 26.90% | 25.22% | 25.66% |
| អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ | **15%** | 1.72% | 1.75% | 1.96% |
| អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ចំណូលថវិកាជាតិ | **18%** | 7.60% | 7.57% | 8.98% |
| អនុបាតតម្លៃចារឹកនៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស. | **65%** | 25.60% | 25.45% | 26.92% |
| **II. វិធានប្រតិបត្តិ** | | | | |
| ឱនភាពថវិកាសរុប | **-5%** | -1.93% | -1.29% | -3.36% |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## ៤.២. ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៧-២០២៩

**ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩** ត្រូវបានរៀបចំឡើង ដោយគោរពតាមជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើ ក្នុងគោលបំណងធានាលទ្ធភាពឆ្លើយតបបាន និងចីរភាពហិរញ្ញវត្ថុសាធារណៈ ដើម្បីការពារអធិបតេយ្យភាព និងបូរណភាពទឹកដី ព្រមទាំងរក្សាស្ថិរភាពសេដ្ឋកិច្ច និង ការគាំទ្រកំណើនប្រកបដោយចីរភាព នៅក្នុងបរិការណ៍ ដែលហ៊ុមព័ទ្ធដោយបញ្ហាភូមិសាស្ត្រនយោបាយ, ការឡើងកម្តៅនៃសង្គ្រាមនៅជុំវិញពិភពលោក និងការកើនឡើងនូវគោលនយោបាយគាំពារនិយម ។ ជារួម, ការរៀបចំក្របខ័ណ្ឌរយៈពេលមធ្យមនេះ បានផ្តោតជាសំខាន់លើទិដ្ឋភាព ចំនួន ៣ ធំៗ រួមមាន៖ ១). **ទិដ្ឋភាពចំណូល** បន្តមានភាពប្រឈមក្នុងរយៈពេលមធ្យម ដែលទទួលរងឥទ្ធិពលពីភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល, បញ្ហាព្រំដែនកម្ពុជា-ថៃ, ការវិវត្តយ៉ាងលឿននៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ និងផលជះពីវិបត្តិការផ្គត់ផ្គង់ប្រេងឥន្ធនៈសកល ដែលអាចផ្តល់ផលអវិជ្ជមានលើវិស័យមួយចំនួនដែលប៉ះពាល់ដោយផ្ទាល់ និងប្រយោល; ២). **ទិដ្ឋភាពចំណាយ** មានការកើននូវតម្រូវការប្រើប្រាស់ថវិកាទាំងចំណាយចរន្ត និងចំណាយវិនិយោគ សម្រាប់អភិវឌ្ឍឡើងវិញនៅបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ រួមទាំងការបន្តគាំពារដល់ជនភៀសសឹក និងពលករទេសន្តរប្រវេសន៍, ការរក្សាលំនឹងជីវភាពប្រជាជន ក៏ដូចជា តម្រូវការសម្រាប់បន្តការងារកែទម្រង់ និងពង្រឹងសមត្ថភាពស្ថាប័ន, ការបន្តអនុវត្តគោលនយោបាយគាំពារសង្គម និង ការអភិវឌ្ឍមូលធនមនុស្ស ព្រមទាំងការអនុវត្តគោលនយោបាយអាទិភាព និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដែលមានគុណភាពខ្ពស់ និងមានភាពធន់; និង ៣).

**ទិដ្ឋភាពលម្អិតវិកា** ត្រូវគិតគូរកសាងឡើងវិញ ខណៈលទ្ធភាពក្នុងការទទួលបានឥណទានក្នុងកម្រិតសម្បទានខ្ពស់កាន់តែថមថយ និងការកៀរគរហិរញ្ញប្បទានក្នុងស្រុក នៅមានកម្រិតនៅឡើយ ។

## ក. ក្របខ័ណ្ឌចំណូល

**ចំណូលសរុប ក្នុងឆ្នាំ ២០២៧ ត្រូវបានព្យាករថានឹងសម្រេចបានក្នុងទំហំប្រមាណ ១៥,២៤% នៃ ផ.ស.ស. ដែលសមមូលនឹងកំណើនប្រមាណ ៧,២% ធៀបនឹងលទ្ធផលប៉ាន់ស្មានក្នុងឆ្នាំ ២០២៦ ។ សម្រាប់រយៈពេលមធ្យមឆ្នាំ ២០២៨-២០២៩ ត្រូវបានរំពឹងថាសម្រេចបានកំណើនជាមធ្យម ក្នុងអត្រា ៧,៤% និងស្ថិតក្នុងទំហំ ១៥,១៦% នៃ ផ.ស.ស. នៅឆ្នាំ ២០២៩ ។** ភាពល្អប្រសើរនៃចំណូលសរុបក្នុងរយៈពេលមធ្យមនេះ បង្ហាញពីលទ្ធផលវិជ្ជមាននៃការដាក់ចេញគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការគាំទ្រកំណើនសេដ្ឋកិច្ច ។ ទោះជាយ៉ាងណា, ចំណូលពីហិរញ្ញប្បទានឥតសំណង ត្រូវបានរំពឹងទុកថានឹងមានការថមថយ ស្របពេលដែលប្រទេសកម្ពុជានឹងក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ដែលលទ្ធភាពក្នុងការទទួលបានឥណទាន ក្នុងកម្រិតសម្បទានខ្ពស់ និងជំនួយពីបរទេសកាន់តែរួមតូច ។

**ចំណូលចរន្ត ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ១៤,៧៦% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៧ សមមូលនឹងអត្រាកំណើនក្នុងរង្វង់ ៧,៥% ធៀបនឹងលទ្ធផលប៉ាន់ស្មានក្នុងឆ្នាំ ២០២៦ ។ សម្រាប់ឆ្នាំ ២០២៨-២០២៩, ចំណូលចរន្ត ត្រូវបានរំពឹងថាសម្រេចបានកំណើនជាមធ្យម ក្នុងអត្រា ៧,៣% និងស្ថិតក្នុងរង្វង់ ១៤,៦៨% នៃ ផ.ស.ស. នៅឆ្នាំ ២០២៩ ។** ជារួម, ចំណូលចរន្តសម្រាប់រយៈពេលមធ្យម ត្រូវបានព្យាករដោយផ្អែកលើទិដ្ឋភាព ៣ សំខាន់ៗ រួមមាន៖ ១). **ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច** ដែលនឹងសម្រេចបានកំណើនលើស ៥%, ២). **កត្តាគោលនយោបាយសារពើពន្ធ** ដែលគិតគូរលើការកែសម្រួលអត្រាពន្ធឱ្យត្រលប់មកប្រក្រតីភាពវិញ បន្ទាប់មានការអនុវត្តនូវវិធានការអនុគ្រោះពន្ធមួយចំនួន ក្នុងឆ្នាំ ២០២៦ និងការពង្រឹងការគ្រប់គ្រងចំណាយសារពើពន្ធ ឱ្យកាន់តែចំគោលដៅ និងមានប្រសិទ្ធភាពខ្ពស់ និង ៣). **ការកែទម្រង់មុតស្រួច** លើការប្រមូលចំណូលពីទំនិញនាំចូលជាក់លាក់មួយចំនួន ដែលនឹងជួយរក្សាស្ថិរភាពនៃកំណើនចំណូលចរន្ត ។

**ចំណូលសារពើពន្ធប្រមូលដោយ អគ្គនាយកដ្ឋានពន្ធដារ** ត្រូវបានព្យាករថានឹងមាន កំណើនប្រមាណ ៤,៧% ក្នុងឆ្នាំ ២០២៧ ធៀបនឹងលទ្ធផលប៉ាន់ស្មានក្នុងឆ្នាំ ២០២៦ និង សម្រេចបានកំណើនជាមធ្យមក្នុងអត្រា ៦,៧% សម្រាប់ឆ្នាំ ២០២៨-២០២៩ ។ ជារួម, លទ្ធផលខាងលើ ត្រូវបានព្យាករក្រោមមូលដ្ឋានសម្មតិកម្ម ដែលចំណូលពីវិស័យសំខាន់ៗ ដូចជា វិស័យហិរញ្ញវត្ថុ, សកម្មភាពស្នាក់នៅ និងអាហារ, កម្មន្តសាល, អាហារ័ណ-នីហារ័ណ, និងសេវាកម្មស្នាក់នៅ និងអាហារ ត្រូវបានរំពឹងថានឹងមានកំណើនថមថយ ដោយសារការបន្តទទួលរងឥទ្ធិពលបន្សល់ពីវិបត្តិនានា ពីក្នុងឆ្នាំ ២០២៥ ឆ្លងមកដល់ឆ្នាំ ២០២៦ ។ យ៉ាងណាមិញ,

ចំណូលពន្ធប្រយោលក្នុងស្រុក ត្រូវបានរំពឹងថានឹងសម្រេចបានកំណើនប្រសើរ និងត្រលប់មករកសម្ទុះកំណើនប្រក្រតីភាពវិញ ស្របតាមទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច ។

**ចំណូលសារពើពន្ធប្រមូលដោយ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា** ត្រូវបានព្យាករថានឹងមាន កំណើនប្រមាណ ១២,០% ក្នុងឆ្នាំ ២០២៧ ធៀបនឹងលទ្ធផលប៉ាន់ស្មានក្នុងឆ្នាំ ២០២៦ និងសម្រេចបានកំណើនក្នុងរង្វង់ ៧,៨% សម្រាប់ឆ្នាំ ២០២៨-២០២៩ ។ ការហក់ឡើងខ្ពស់នៃចំណូលក្នុងឆ្នាំ ២០២៧ និងការរក្សាបានកំណើនល្អប្រសើរក្នុងរយៈពេលមធ្យមនេះ ត្រូវបានគាំទ្រដោយ៖ ១). ការកែទម្រង់មុតស្រួច សំដៅពង្រឹងអភិបាលកិច្ច នៃការប្រមូលចំណូលគយ និងរដ្ឋាករ ដែលនឹងជួយរក្សាស្ថិរភាពនៃកំណើនចំណូលចរន្ត, ២). ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការរក្សាលំនឹងជីវភាពប្រជាជន ជាពិសេសការកែសម្រួលអត្រាពន្ធគយលើគ្រឿងអគ្គិសនី និងការដាក់ជាបន្ទុករដ្ឋនូវពន្ធមួយចំនួនលើផលិតផលតេលសិលា ក្នុងឆ្នាំ ២០២៦ ដែលនឹងមានផលជះវិជ្ជមានមកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងឆ្នាំបន្ទាប់ និងទៅមុខរយៈពេលមធ្យម និង ៣). ការត្រលប់មកអនុវត្តអត្រាពន្ធជាធរមានឡើងវិញ លើផលិតផលតេលសិលា បន្ទាប់ពីមានការអនុវត្តនូវវិធានការអនុគ្រោះពន្ធមួយចំនួនក្នុងឆ្នាំ ២០២៦ ។

**ចំណូលមិនមែនសារពើពន្ធ** ត្រូវបានព្យាករថានឹងមានកំណើនយឺតប្រមាណ ៤,៦% ក្នុងឆ្នាំ ២០២៧ និងរំពឹងថាសម្រេចបានកំណើនជាមធ្យម ក្នុងរង្វង់ ៨,៣% សម្រាប់ឆ្នាំ ២០២៨-២០២៩ ។ ក្នុងនោះ ចំណូលនេះ ក្នុងរយៈពេលមធ្យម ត្រូវបានគាំទ្រ ដោយ៖ ១). ចំណូលពីប្រៃសណីយ៍ និងទូរគមនាគមន៍ រំពឹងថានិន្នាការប្រើប្រាស់ទូរស័ព្ទ នឹងបន្តកើន; ២). ចំណូលពីសម្បទានពីប្រេងកាត និងរ៉ែ រំពឹងថានឹងបន្តមានកំណើនពីការវិនិយោគរបស់ក្រុមហ៊ុនទៅលើអាជីវកម្មរ៉ែ និងប្រេងកាត; និង ៣). ចំណូលពីវិស័យទេសចរណ៍រួមមាន ផលទុនពីអាកាសចរស៊ីវិល, អាករនៃស្ថានទូត, ផលទុនពីសកម្មភាពទេសចរណ៍ និងចំណូលពីកាតព្វកិច្ចកាស៊ីណូ រំពឹងថានឹងមានការរើបឡើងវិញ ។

### តារាងទី ៧៖ ការព្យាករចំណូលរយៈពេលមធ្យម ឆ្នាំ ២០២៧-២០២៩

| | កំណើនប្រចាំឆ្នាំ | | | ភាគរយនៃ ផ.ស.ស. | | |
|---|---|---|---|---|---|---|
| | 2027ព្យ. | 2028ព្យ. | 2029ព្យ. | 2027ព្យ. | 2028ព្យ. | 2029ព្យ. |
| **ចំណូលសរុប** | **7.2%** | **6.9%** | **7.8%** | **15.24%** | **15.16%** | **15.16%** |
| **ចំណូលចរន្ត** | **7.5%** | **7.0%** | **7.7%** | **14.76%** | **14.70%** | **14.68%** |
| **ចំណូលសារពើពន្ធ** | **7.9%** | **6.9%** | **7.5%** | **12.85%** | **12.78%** | **12.74%** |
| អគ្គនាយកដ្ឋានពន្ធដារ | 4.7% | 6.4% | 6.9% | 6.99% | 6.92% | 6.86% |
| *ក្នុងនោះ ថ្នាក់ក្រោមជាតិ* | *8.8%* | *8.9%* | *9.1%* | *0.99%* | *1.00%* | *1.02%* |
| អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | 12.0% | 7.5% | 8.1% | 5.86% | 5.87% | 5.88% |
| **ចំណូលមិនមែនសារពើពន្ធ** | **4.6%** | **7.5%** | **9.0%** | **1.91%** | **1.91%** | **1.94%** |
| *ក្នុងនោះ ថ្នាក់ក្រោមជាតិ* | *3.5%* | *3.4%* | *3.3%* | *0.15%* | *0.15%* | *0.14%* |
| **ចំណូលផ្សេងៗ** | **-1.0%** | **4.2%** | **13.2%** | **0.48%** | **0.46%** | **0.49%** |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ដើម្បីសម្រេចឱ្យបាននូវលទ្ធផលព្យាករខាងលើ និងឆ្លើយតបទៅនឹងបញ្ហាប្រឈមលើការប្រមូលចំណូល ព្រមទាំងទ្រទ្រង់ចលនការនៃចីរភាពកំណើនសេដ្ឋកិច្ច, រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្តវិធានការគោលនយោបាយ ស្របតាម **«យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា»** ដែលជារបៀបវារៈកែទម្រង់របស់រាជរដ្ឋាភិបាល ក្នុងការធ្វើទំនើបកម្មប្រព័ន្ធសារពើពន្ធ និងប្រព័ន្ធចំណូលមិនមែនសារពើពន្ធ សំដៅធានាបាននូវការកៀរគរចំណូល ដោយមិនបង្កវិការភាពណាមួយដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ ។ ក្នុងន័យនេះ **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩** បានកំណត់បន្ថែមនូវវិធានការមួយចំនួន សម្រាប់ជាអាទិភាពក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ ដូចខាងក្រោម៖

#### ■ វិធានការផ្នែកពន្ធដារ

- បន្តផ្សព្វផ្សាយ និងពង្រឹងការអនុវត្ត «កម្មវិធីរដ្ឋបាលអេឡិចត្រូនិក ឬ GDT e-Administration» ដែលនឹងក្លាយជាថ្នាលឌីជីថលទំនើប ដើម្បីគាំទ្រវាល់ការផ្តល់សេវាអ្នកជាប់ពន្ធ ឱ្យមានភាពកាន់តែងាយស្រួលតាមប្រព័ន្ធអេឡិចត្រូនិក;
- បន្តសិក្សាពីបច្ច័យនៃការអនុវត្ត Inclusive Framework on Base Erosion Profit Shifting Project ឱ្យបានគ្រប់ជ្រុងជ្រោយ ទាំងក្នុងទិដ្ឋភាពចំណូល ទិដ្ឋភាពបន្ទុករដ្ឋបាលសារពើពន្ធ និងទិដ្ឋភាពបន្ទុកអនុលោមភាពអ្នកជាប់ពន្ធ;
- បន្តពិនិត្យ និងពង្រឹងយន្តការអនុវត្តវិធានការបង្វែរថ្លៃ (Transfer Pricing Rules) ជាពិសេសចំពោះសហគ្រាសបុត្រសម្ព័ន្ធ និងអ្នកជាប់ពន្ធនិវាសនជន ដែលកំពុងទទួលបានការលើកទឹកចិត្តពន្ធ;
- បន្តសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បី (១)- រៀបចំនិយាមនីតិវិធីប្រតិបត្តិការងារ (SOP) ស្តីពីការជូនវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ ដែលទទួលបានការលើកលែងពន្ធ, (២)- ស្នើសុំទិន្នន័យអចលនទ្រព្យដែលអាចប្រើប្រាស់បានសម្រាប់ប្រមូលពន្ធប្រថាប់ត្រាពន្ធលើអចលនទ្រព្យ និងពន្ធលើចំណេញមូលធន ស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាលកន្លងមក;

- បន្តធ្វើបច្ចុប្បន្នភាពថ្លៃអចលនទ្រព្យ សម្រាប់ជាមូលដ្ឋានគិតពន្ធប្រថាប់ត្រារៀងរាល់ ៥ ឆ្នាំម្តង ដោយសិក្សាលទ្ធភាពក្នុងការកែសម្រួលប្រកាស ស្តីពីការកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ;
- បន្តពង្រឹងយន្តការអនុវត្តពន្ធលើប្រាក់ចំណូល និងពន្ធអាករផ្សេងទៀត លើអាជីវកម្មល្បែងពាណិជ្ជកម្ម ទាំងសកម្មភាពល្បែងពាណិជ្ជកម្ម និងសកម្មភាពដទៃទៀត ដែលជ្រកក្រោមអាជីវកម្មល្បែងពាណិជ្ជកម្ម;
- ពង្រឹងយន្តការគ្រប់គ្រងចំណូលពន្ធលើវិស័យផលិតស្រាបៀរ និងភេសជ្ជៈ ស្របតាមសេចក្តីណែនាំលេខ ១៥០២៤ ស្តីពីកាតព្វកិច្ចដំឡើងឧបករណ៍វាស់ចំណុះស្រាបៀរ ដែលតម្រូវឱ្យសហគ្រាសផលិតក្នុងស្រុកដំឡើងនូវកុងទ័រ ក្នុងខ្សែចង្វាក់ផលិតកម្ម ដើម្បីវាស់បរិមាណផលិតនៅតាមបំពង់បង្ហូរស្រាបៀរ និងអាចទទួលបានទិន្នន័យភ្លាមៗ ពីទីតាំងផលិត;
- អនុវត្តតឹងរឹងលើវិធានការហាមឃាត់ការផ្តល់រង្វាន់តាមក្រវិលកំប៉ុង ឬ គម្របនៃផលិតផលគ្រឿងស្រវឹង និងភេសជ្ជៈ ដើម្បីធានាឱ្យមាននូវតម្លាភាព និងលើកកម្ពស់បរិយាកាសប្រកួតប្រជែងស្មើភាព;
- បន្តពង្រឹងការគ្រប់គ្រងបំណុលពន្ធ និងកំណត់បំណុលពន្ធជាអាទិភាពដែលអាចប្រមូលបាន តាមរយៈការធ្វើចំណាត់ថ្នាក់បំណុល ការតឹងទារបំណុល និងបំណុលពន្ធដែលប្រមូលបាន សំដៅកាត់បន្ថយជាអតិបរមានូវបំណុលពន្ធបច្ចុប្បន្ន និងចៀសវាងការកើនឡើងបំណុលពន្ធអនាគត;
- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងទិន្នន័យចំណាយសារពើពន្ធ ដោយពង្រឹងមុខងារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពន្ធដារ ក្នុងការកត់ត្រាតួលេខការអនុគ្រោះ ការលើកលែង និងការលើកទឹកចិត្តពន្ធនានា របស់រាជរដ្ឋាភិបាល;
- ចូលរួមអនុវត្តវិធានការពាក់ព័ន្ធនឹងពន្ធដារ ចំពោះការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីជំរុញវិស័យទាំងនោះឱ្យចូលក្នុងប្រព័ន្ធ ព្រមទាំងលើកទឹកចិត្ត និងថែរក្សាឱ្យវិស័យទាំងនោះក្លាយជាមូលដ្ឋានចំណូលពន្ធបន្ថែម;
- សិក្សាអំពីលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តប្រព័ន្ធ Self-service ជាមគ្គុទេសក៍សម្រាប់អ្នកជាប់ពន្ធ ដើម្បីអាចផ្តល់លទ្ធភាពដល់អ្នកជាប់ពន្ធ ដែលបានចុះបញ្ជីក្នុងប្រព័ន្ធពន្ធដារ អាចដឹងពីប្រភេទពន្ធអាករដែលខ្លួនត្រូវបង់, តាមដានទិន្នន័យបំណុលពន្ធ, ដឹងពីស្ថានភាពនៃការចុះធ្វើសវនកម្ម, និងទិន្នន័យផ្សេងទៀត; និង
- បន្តការងារកែទម្រង់ធនធានមនុស្ស ដោយជំរុញ និងខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងត្រូវមានភាពទន់ភ្លន់តែម៉ឺងម៉ាត់ ដោយផ្អែកលើទិដ្ឋភាពច្បាប់ក្នុងការផ្តល់សេវាជូនអ្នកជាប់ពន្ធ និងការគ្រប់គ្រងប្រមូលចំណូលពន្ធ ។

### ■ វិធានការផ្នែកគយ និងរដ្ឋាករកម្ពុជា

- បន្តជំរុញការអនុវត្តវិធានការកែទម្រង់គន្លឹះ និងមុតស្រួចផ្នែកកិច្ចសម្រួលពាណិជ្ជកម្ម ក្រោមដែនសមត្ថកិច្ចគយ ដែលបានដាក់ចេញ ក្នុងវេទិការាជរដ្ឋាភិបាលផ្នែកឯកជន;
- ជំរុញការអនុវត្តវិធានការមុតស្រួច ក្នុងការបង្ការ និងបង្ក្រាបអំពើរត់គេចពន្ធ និងការពង្រឹងអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដែលបានដាក់ចេញ ក្នុងកិច្ចប្រជុំយន្តការភាពជាដៃគូគយផ្នែកឯកជន;

- ធ្វើវិសិដ្ឋកម្មប្រព័ន្ធបច្ចេកវិទ្យាត្រួតពិនិត្យគយ តាមរយៈការបំពាក់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) និងបច្ចេកវិទ្យាទំនើបផ្សេងទៀត ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការត្រួតពិនិត្យអនុលោមភាពគយ និងពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូល;
- បន្តធ្វើបច្ចុប្បន្នភាពច្បាប់ និងបទប្បញ្ញត្តិថ្មី ស្របតាមការវិវឌ្ឍនៃបរិបទសេដ្ឋកិច្ច សង្គម និងបច្ចេកវិទ្យា ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការប្រមូលចំណូល ការអនុវត្តច្បាប់ ការទប់ស្កាត់អំពើគេចពន្ធ និងការសម្រួលពាណិជ្ជកម្ម;
- តាមដានប្រសិទ្ធភាពនៃការអនុវត្តមុខងារគយ និងវិភាគកម្រិតហានិភ័យ ដោយប្រើប្រាស់ថ្នាលរួម ដែលវិភាគពីរូបភាពស្កែន, រូបភាពកាមេរ៉ាសុវត្ថិភាព, ប្រព័ន្ធ ECTS, លទ្ធផលជញ្ជីងថ្លឹង, ឯកសារបញ្ចេញទំនិញ, ឯកសារដឹកជញ្ជូន និងទិន្នន័យ ឬ ព័ត៌មាននានា នៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគយ;
- បង្កើនប្រសិទ្ធភាពការគ្រប់គ្រងការអនុវត្តការអនុគ្រោះអត្រាពន្ធ និងការគ្រប់គ្រងទិន្នន័យ ក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការអនុវត្តគោលការណ៍លើកទឹកចិត្តពន្ធ និងអាករក្រោមក្របខ័ណ្ឌផ្សេងៗ ពិសេស គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ);
- បន្តធ្វើវិចារណកម្មតារាងពន្ធគយ ដើម្បីឱ្យមានភាពសមស្របតាមការវិវត្តសេដ្ឋកិច្ច និងលើកស្ទួយកម្រិតជីវភាពប្រជាជន និងពង្រឹងការអនុវត្តគោលការណ៍លើកទឹកចិត្តពន្ធ និងអាករស្របតាមច្បាប់ និងបទប្បញ្ញត្តិថ្មីៗ;
- បន្តតាមដាន និងវាយតម្លៃការងារបង្ការ និងបង្ក្រាបបទល្មើសគយ ការដាក់ចេញវិធានការមុតស្រួចលើមុខទំនិញជាក់លាក់;
- ពង្រឹងបន្ថែមសមត្ថភាពជំនាញរបស់មន្ត្រី ដើម្បីឆ្លើយតបឱ្យបានជាអតិបរមាទៅនឹងបទល្មើសគយដែលកើតឡើងក្នុងរូបភាពថ្មីៗ និងកាន់តែស្មុគស្មាញ;
- លើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ម៉ាស៊ីនស្កេន ដោយត្រូវសិក្សា និងពិនិត្យលទ្ធភាពបំពាក់ម៉ាស៊ីនស្កេន នៅមាត់ច្រកសំខាន់ៗបន្ថែមទៀត ដោយលើកលែងការបង់កម្រៃ ដើម្បីគាំទ្រការពង្រឹងអនុលោមភាពដោយរក្សាបាននូវកិច្ចសម្រួលពាណិជ្ជកម្ម; និង
- ជំរុញការបង្កើនចំនួន និងសម្រួលនីតិវិធីដល់ការស្នើសុំវិញ្ញាបនបត្រសមាជិកក្រុមឈ្មួញល្អបំផុត (Best Traders) និងប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត (Authorized Economic Operator Programme - AEO) ក៏ដូចជាកាត់បន្ថយតម្រូវការឯកសាររឹងក្នុងការស្នើសុំ ។

### ■ វិធានការផ្នែកចំណូលមិនមែនសារពើពន្ធ

- បង្កើត និងធ្វើបច្ចុប្បន្នភាពគោលនយោបាយ ដើម្បីពង្រឹងគណនេយ្យភាព តាមរយៈការរៀបចំឱ្យបានគ្រប់ជ្រុងជ្រោយនូវលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីពង្រឹងគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅក្នុងវិស័យសក្តានុពលសំខាន់ៗ;
- បែងចែកសមត្ថកិច្ចគ្រប់គ្រង និងប្រមូលចំណូលពីសេវាសាធារណៈរបស់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ (ការផ្ទេរមុខងារពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ) និងសិក្សា និងពិនិត្យលទ្ធភាពរៀបចំប្រព័ន្ធបច្ចេកវិទ្យា សម្រាប់ការផ្តល់សេវាតាមប្រព័ន្ធអនឡាញ;
- ពង្រឹងការគ្រប់គ្រង និងការអនុវត្តលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ តាមរយៈយន្តការពិន័យ ដាក់ទោសទណ្ឌ និងលើកទឹកចិត្ត;

- ពិនិត្យលទ្ធភាពបង្កើតយន្តការត្រួតពិនិត្យ និងវាយតម្លៃ សហគ្រាសសាធារណៈ និងភាគហ៊ុនរបស់រដ្ឋ និង សាកល្បងសិក្សាវាយតម្លៃអំពីប្រសិទ្ធភាព ភាពចាំបាច់នៃគោលនយោបាយ និងកម្មវិបាក នៃសហគ្រាសសាធារណៈ;
- ពន្លឿនការសិក្សាស្រាវជ្រាវអំពីប្រភេទល្បែងពាណិជ្ជកម្មថ្មីៗពីបណ្តាប្រទេសនានា ដើម្បីប្រមូលព័ត៌មាន, ដកស្រង់បទពិសោធ, និងឧត្តមានុវត្តន៍ ដោយផ្តោតលើយន្តការគ្រប់គ្រង និងប្រមូលចំណូលសម្រាប់ជាធាតុចូលក្នុងការតាក់តែងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការដាក់ឱ្យដំណើរការប្រភេទល្បែងពាណិជ្ជកម្មថ្មីៗ សំដៅរួមចំណែកពង្រីកសក្តានុពលនៃការប្រមូលចំណូល;
- បន្តការជំរុញឱ្យប្រើប្រាស់មុខងារទូទាត់តាមរយៈប្រព័ន្ធអេឡិចត្រូនិក ឬ e-Payment;
- បន្តជំរុញការធ្វើសន្ទានកម្មប្រព័ន្ធ NRMIS និងប្រព័ន្ធ SARMIS ជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រព័ន្ធនៃក្រសួង-ស្ថាប័នផ្សេងទៀត ឱ្យមានភាពប្រទាក់-ក្រឡា និងដំណើរការបានរលូន; និង
- បន្តសិក្សាស្រាវជ្រាវ និងស្វែងរកប្រភពចំណូលថ្មីៗឱ្យអស់លទ្ធភាព សមស្របតាមស្ថានភាពសេដ្ឋកិច្ច ។

## ខ. ក្របខ័ណ្ឌចំណាយសាធារណៈ

**ចំណាយសាធារណៈ សម្រាប់ឆ្នាំ ២០២៧-២០២៩** ត្រូវបានគ្រោងឡើង ស្របតាមជំហរគោលនយោ-បាយដែលបានដាក់ចេញខាងលើ ដោយរៀបចំលើមូលដ្ឋានតុល្យភាពនៃចំណូលនិងចំណាយ និងពុំមានការប្រើ-ប្រាស់ប្រាក់សន្សំរបស់រាជរដ្ឋាភិបាល ។ ក្នុងន័យនេះ, ការគ្រោងចំណាយសាធារណៈសម្រាប់រយៈពេលមធ្យម ត្រូវបានរៀបចំប្រកបដោយភាពប្រុងប្រយ័ត្ន និងបុរេសកម្មខ្ពស់ ដោយឈរលើគោលការណ៍គោរពម៉ឺងម៉ាត់វិន័យថវិកា និងពង្រឹងស័ក្តិសិទ្ធិភាពថវិកា តាមរយៈការបន្តខិតខំកែលម្អការវិភាជថវិកាឱ្យកាន់តែចំទិសដៅ និងចំតម្រូវការចាំបាច់ជាក់ស្តែង ។ ក្របខ័ណ្ឌចំណាយសាធារណៈរយៈពេលមធ្យមនេះ បានបន្តគិតគូរធ្វើអាទិភាពូបនីយកម្មចំណាយ ព្រមជាមួយការរក្សានូវលម្ហថវិកាសម្រាប់ធ្វើអន្តរាគមន៍សង្គម-សេដ្ឋកិច្ចនៅពេលកាលៈទេសៈតម្រូវ, ការបន្តអនុវត្តគោលនយោបាយគាំពារសង្គម, ការអភិវឌ្ឍមូលធនមនុស្ស, ការពង្រឹងសមត្ថភាពស្ថាប័ន, ការកែ-ទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់ដារចនាសម្ព័ន្ធ ព្រមទាំងការអនុវត្តគោលនយោបាយអាទិភាពគន្លឹះ ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង, បង្កើនផលិតភាព និងជំរុញការធ្វើពិពិធកម្មឱ្យខ្លាំងក្លា សំដៅកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់កំណើន, ការបង្កើតការងារ និងការវិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់ និងមានភាពធន់ គាំទ្រដល់ការស្តារ និងជំរុញកំណើនសេដ្ឋកិច្ច និងកិច្ចអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជារួម ។ ផ្អែកតាមស្ថានភាពចំណូលមិនទាន់មានភាពប្រសើរវិញដូចការរំពឹងទុក ដោយសារផលជះជាអវិជ្ជមានពីបញ្ហាជម្លោះព្រំដែនកម្ពុជា-ថៃ និងសង្គ្រាមនៅមជ្ឈិមបូព៌ា ដែលជះឥទ្ធិពលលើសេដ្ឋកិច្ចជារួម ស្របពេលដែលតម្រូវការក្នុងការអន្តរាគមន៍សង្គម-សេដ្ឋកិច្ចបានកើនឡើង, រាជរដ្ឋាភិបាលបានសម្រេចពន្យារការគ្រោង **«មូលនិធិបម្រុងហិរញ្ញវត្ថុរបស់រដ្ឋ»** ដោយប្រើប្រាស់ចំណាយថវិកាជាតិ ក្នុងឆ្នាំ ២០២៧; ប៉ុន្តែ, នឹងពិនិត្យលទ្ធភាពប្រើប្រាស់អតិរេកថវិកាឆ្នាំ ២០២៦ (ក្នុងករណីមានអតិរេក) ដើម្បីចាប់ផ្តើមអនុវត្តមូលនិធិនេះ, ដែលលទ្ធភាពនេះនឹងត្រូវកំណត់ដោយ **ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦** នៅពេលខាងមុខ ។ យ៉ាងណាក៏ដោយ, **មូលនិធិបម្រុងហិរញ្ញវត្ថុរបស់រដ្ឋ** នឹងត្រូវបានពិនិត្យលទ្ធភាពចាប់ផ្តើមអនុវត្តក្នុងឆ្នាំ ២០២៨ តទៅ ក្នុងអត្រា ១% ទៅ ២% នៃចំណូលចរន្តថ្នាក់ជាតិដែលប្រមូលបាននៅឆ្នាំ N-2 ។

**សម្រាប់ឆ្នាំ ២០២៧, ចំណាយសរុបត្រូវបានគ្រោងក្នុងទំហំ ១៧,០៣% នៃ ផ.ស.ស. ពោលគឺថមថយប្រមាណ -១,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៦ ។ សម្រាប់ឆ្នាំ ២០២៨-២០២៩ កញ្ចប់ចំណាយសរុបនឹងគ្រោងឱ្យមានកំណើនក្នុងអត្រាជាមធ្យមប្រមាណ ៥,៧% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១៦,៤៣% នៃ ផ.ស.ស. នៅឆ្នាំ ២០២៩ ។**

**ចំណាយចរន្ត ត្រូវបានគ្រោងក្នុងទំហំ ១២,៤១% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៧ ដែលមានកំណើនប្រមាណ ៧,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៦ ។ សម្រាប់ឆ្នាំ ២០២៨-២០២៩ ចំណាយចរន្ត ត្រូវបានគ្រោងឱ្យមានកំណើន ក្នុងអត្រាជាមធ្យមប្រមាណ ៥,២% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១១,៨៥% នៃ ផ.ស.ស. នៅឆ្នាំ ២០២៩ ។**

**ចំណាយបន្ទុកបុគ្គលិក ត្រូវបានគ្រោងឱ្យមានកំណើនក្នុងអត្រា ៨,២% ក្នុងឆ្នាំ ២០២៧ ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៦** ដោយបានគិតគូរការដំឡើងបៀវត្ស ព្រមទាំងការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ជូនមន្ត្រីរាជការស៊ីវិល ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងកងកម្លាំងប្រដាប់អាវុធ ដើម្បីបន្តលើកកម្ពស់ និងគាំទ្រដល់សុខុមាលភាពមន្ត្រីរាជការ ក្នុងកាលៈទេសៈចំពោះមុខនេះ ។ **សម្រាប់ឆ្នាំ ២០២៨-២០២៩, ចំណាយបន្ទុកបុគ្គលិក ត្រូវបានគ្រោងឱ្យកើនជាមធ្យមក្នុងអត្រា ២,៤%** ។ ដោយឡែក, **ចំណាយមិនមែនបន្ទុកបុគ្គលិក ត្រូវបានគ្រោងឱ្យមានកំណើនក្នុងអត្រា ៦,៤% ក្នុងឆ្នាំ ២០២៧ ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៦ និងកើនជាមធ្យមក្នុងអត្រា ៧,២% សម្រាប់ឆ្នាំ ២០២៨-២០២៩** ស្របតាមគោលការណ៍ពង្រឹងប្រសិទ្ធភាពវិភាជថវិកា តាមរយៈការខិតខំតម្រង់ការវិភាជថវិកាឱ្យបានត្រឹមត្រូវ និងចំគោលដៅ, បន្តត្បិតត្បៀតលើមុខសញ្ញាចំណាយមិនចាំបាច់ និងមិនសូវចាំបាច់ ព្រមទាំងរក្សាឱ្យបាននូវនិរន្តរភាពប្រតិបត្តិការរបស់ក្រសួង-ស្ថាប័ន និងជាពិសេសគាំទ្រដល់ដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់, ការផ្តល់អាទិភាពលើវិស័យសង្គមកិច្ច, ការលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តគោលនយោបាយគាំពារសង្គម សំដៅលើកកម្ពស់សមធម៌ និងភាពសុខដុមក្នុងសង្គម ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាល បានគិតគូរបង្កើនធនធានបន្ថែមទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយត្រូវចែករំលែកចំណូលពីសេវាសាធារណៈក្នុងអត្រា ១៥% ជូនជាគុណប្រយោជន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈយន្តការ **«មូលនិធិភាតរភាព»** ចាប់ពីឆ្នាំ ២០២៧ តទៅ និងបានត្រៀមកញ្ចប់ថវិកា ក្នុងឥណទានថវិកាមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល សម្រាប់អនុវត្តនូវមុខសញ្ញាថ្មីៗ និងកម្មវិធីអន្តរាគមន៍ ដើម្បីរក្សាលំនឹងជីវភាពប្រជាជន និងលើកកម្ពស់សមធម៌សង្គម ក្នុងករណីចាំបាច់ ផងដែរ ។

**ចំណាយមូលធន ត្រូវបានគ្រោងក្នុងទំហំ ៤,៦២% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៧ ដែលធ្លាក់ក្នុងអត្រា -១៩,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៦ ។** ការធ្លាក់ចុះនេះ បណ្តាលជាចម្បងមកពីការរំពឹងទុកនៃការថមថយប្រភពហិរញ្ញប្បទានក្រៅប្រទេស និងការកើនធំ ក្នុងឆ្នាំ ២០២៦ ដើម្បីបំពេញតម្រូវការស្តារ និងអភិវឌ្ឍព្រំដែនកម្ពុជា-ថៃ ។ យ៉ាងណាមិញ, ចំណាយមូលធនក្នុងឆ្នាំ ២០២៧ បន្តផ្តល់ការគិតគូរដល់គម្រោងវិនិយោគសាធារណៈអាទិភាព ស្របតាមគោលដៅអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល និងតាមលទ្ធភាពដែលអាចទ្រទ្រង់បាន ។ **សម្រាប់ឆ្នាំ ២០២៨-២០២៩ ចំណាយមូលធន ត្រូវបានគ្រោងឱ្យមានកំណើនឡើងវិញ ក្នុងអត្រាជា**

**មធ្យមប្រមាណ ៧,២% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ៤,៥៨% នៃផ.ស.ស. នៅឆ្នាំ ២០២៩** ។ កំណើននេះ បានគិតគូរពីតម្រូវការចំណាយចាំបាច់សម្រាប់ការអភិវឌ្ឍ និងឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់ប្រជាជន, ការរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ច, ការលើកកម្ពស់ភាពប្រកួតប្រជែង និងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ច ពោលគឺ រាជរដ្ឋាភិបាលនឹងផ្ដល់អាទិភាពខ្ពស់ទៅលើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ជាពិសេស តាមរយៈការបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានគុណភាពខ្ពស់ និងការបង្កើនបរិមាណ និងគុណភាពនៃការវិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបៃតង ដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់ការធ្វើបរិវត្តកម្មឌីជីថល និងការបន្តជួសជុល, ស្ដារ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា ។ បន្ថែមពីនេះ, ទំហំចំណាយវិនិយោគនេះ បានគិតគូរការវិភាជថវិកាសម្រាប់ទ្រទ្រង់ដល់ **កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល** ក្នុងគោលបំណងពង្រឹងការផ្សារភ្ជាប់រវាងផែនការវិនិយោគសាធារណៈ ទៅនឹងអាទិភាពគោលនយោបាយនានា ព្រមទាំងធានាភាពស្របគ្នារវាងផែនការវិនិយោគ និងផែនការថវិកា សំដៅសម្រេចបានគោលដៅដែលបានដាក់ចេញក្នុង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨** ។

**ជារួម, ចំណាយសរុបថ្នាក់ជាតិ ក្នុងឆ្នាំ ២០២៧ ត្រូវបានគ្រោងក្នុងទំហំ ១៥,៨៩% នៃ ផ.ស.ស. ថមថយប្រមាណ -២,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៦ ។ សម្រាប់ឆ្នាំ ២០២៨-២០២៩, ចំណាយសរុបថ្នាក់ជាតិនឹងគ្រោងឱ្យមានកំណើនក្នុងអត្រាជាមធ្យមប្រមាណ ៥,៥% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១៥,២៧% នៃ ផ.ស.ស. នៅឆ្នាំ ២០២៩** ។ ចំណាយថ្នាក់ជាតិ ដែលរួមបញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធនសម្រាប់ឆ្នាំ ២០២៧-២០២៩ ត្រូវបានគ្រោងវិភាជន៍ទៅតាមវិស័យ ដូចខាងក្រោម៖

**ចំណាយវិស័យរដ្ឋបាលទូទៅ ត្រូវបានគ្រោងជាមធ្យមឱ្យស្ថិតក្នុងរង្វង់ប្រមាណ ១,៥៩% នៃ ផ.ស.ស. សម្រាប់រយៈពេលមធ្យមខាងមុខ (ឆ្នាំ ២០២៧-២០២៩), សមមូលនឹងកំណើនប្រចាំឆ្នាំជាមធ្យមក្នុងអត្រា ៨,០%** សំដៅធានានូវប្រសិទ្ធភាពនៃការរៀបចំដំណើរការបោះឆ្នោត, បន្តពង្រឹង និងពង្រីកទំនាក់ទំនងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការងារការទូតសេដ្ឋកិច្ច ព្រមទាំងបន្តផ្ដល់ការគាំទ្រដល់កិច្ចការពារនិងជួយសង្គ្រោះពលករខ្មែរដែលធ្វើការនៅក្រៅប្រទេស, បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, ការងារទាក់ទាញ និងការគ្រប់គ្រងវិនិយោគឯកជន និងការពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍ, ការធ្វើទំនើបកម្ម និងប្រព័ន្ធស្វ័យប្រវត្តិកម្មរដ្ឋបាលសារពើពន្ធ, ការធ្វើទំនើបកម្មការគ្រប់គ្រងចំណាយសាធារណៈ និងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល, ការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ចធុរកិច្ច និងសង្គមឌីជីថល, ការបន្តគាំទ្រការអនុវត្តយុទ្ធសាស្ត្រស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ, ព្រមទាំងការបន្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»** ។

**ចំណាយវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវបានគ្រោងជាមធ្យមឱ្យស្ថិតក្នុងរង្វង់ប្រមាណ ២,៦២% នៃ ផ.ស.ស. សម្រាប់រយៈពេលមធ្យមខាងមុខ (ឆ្នាំ ២០២៧-២០២៩), សមមូលនឹងកំណើនប្រចាំឆ្នាំជាមធ្យមក្នុងអត្រា ៦,៤%** សំដៅបន្តពង្រឹងសមត្ថភាពការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី សន្តិសុខ និងសុវត្ថិភាព, ការយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ ព្រមទាំងការ-គ្រប់គ្រងនិងថែទាំយុទ្ធោបករណ៍ និងសម្ភារបច្ចេកទេស, ការអនុវត្តកិច្ចការសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ, ការអនុវត្តកិច្ចការសន្តិសុខមិនប្រពៃណី, ការពង្រឹងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ សង្កាត់មានសុវត្ថិភាព», ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យព្រំដែន, ការអភិវឌ្ឍចំណេះដឹង និងជំនាញវិជ្ជាជីវៈជូនកងកម្លាំងនគរបាលជាតិ និងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ ។

**ចំណាយវិស័យសង្គមកិច្ច ត្រូវបានគ្រោងជាមធ្យមឱ្យស្ថិតក្នុងរង្វង់ប្រមាណ ៤,៨០% នៃ ផ.ស.ស. សម្រាប់រយៈពេលមធ្យមខាងមុខ (ឆ្នាំ ២០២៧-២០២៩), សមមូលនឹងកំណើនប្រចាំឆ្នាំជាមធ្យមក្នុងអត្រា ៥,៦%** ពោលគឺនៅតែត្រូវបានចាត់ទុកជាវិស័យអាទិភាពទី ១ ដោយសំដៅបន្តរក្សាលំនឹងជីវភាពប្រជាជន ព្រមទាំងលើកកម្ពស់សមធម៌សង្គម, បន្តលើក-កម្ពស់គុណភាពអប់រំ និងគាំទ្រដល់ការពង្រឹង និងពង្រីកការទទួលបានសេវាអប់រំ, ការអភិវឌ្ឍជំនាញ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ពិសេសនៅក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម, លើកកម្ពស់គុណភាពសេវាសុខាភិបាល និងការពង្រីកការទទួលបានសេវាថែទាំសុខភាពឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា, ជំរុញការអនុវត្តគោលនយោបាយជាតិគាំពារសង្គម, ការបន្តផ្តល់របបសន្តិសុខសង្គម, ការលើកកម្ពស់សមភាពយេនឌ័រ, និងការបន្តគាំទ្រដល់គោលនយោបាយអាទិភាពផ្សេងទៀត ក្នុងផ្នែកសង្គមកិច្ច, សាសនា, វប្បធម៌ និងបរិស្ថាន ។

**ចំណាយវិស័យសេដ្ឋកិច្ច ត្រូវបានគ្រោងជាមធ្យមឱ្យស្ថិតក្នុងរង្វង់ប្រមាណ ៣,២៤% នៃ ផ.ស.ស. សម្រាប់រយៈពេលមធ្យមខាងមុខ (ឆ្នាំ ២០២៧-២០២៩), សមមូលនឹងកំណើនប្រចាំឆ្នាំជាមធ្យមក្នុងអត្រា ២,៧%** ដោយផ្តោតសំខាន់លើការលើកកម្ពស់ផលិតភាពស្របតាមស្តង់ដា និងតម្រូវការទីផ្សារ, ការលើកកម្ពស់ផលិតភាពកសិកម្ម និងការជួយគ្រួសារកសិករក្នុងការលើកស្ទួយផលិតផលកសិកម្ម តាមរយៈការបន្តដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ-សង្កាត់ទូទាំងប្រទេស និងការរៀបចំឱ្យមានសមាគមកសិកម្មទំនើប, ការគាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម, ការជួសជុល និងការថែទាំប្រព័ន្ធធារាសាស្ត្រ ផ្លូវស្ពាន និងផ្លូវលំជនបទ, ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរ៉ែគ្រប់ប្រភេទ និងការអភិវឌ្ឍវិស័យថាមពល និងការអនុវត្ត **យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ ២០២៣-២០២៨, គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ ២០២០-២០៣០, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ**

២០២១-២០៣៥, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាឆ្នាំ ២០២២-២០៣៥ និង គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០២១-២០៣០ ។ល។

៥ **ចំណាយផ្សេងៗ ត្រូវបានគ្រោងជាមធ្យមឱ្យស្ថិតក្នុងរង្វង់ប្រមាណ ៣,៣២% នៃ ផ.ស.ស. សម្រាប់រយៈពេលមធ្យមខាងមុខ (ឆ្នាំ ២០២៧-២០២៩) ដែលមានការរួមតូចធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៦ ។** ទោះជាយ៉ាងនេះក្ដី, ចំណាយនេះ ស្ថិតក្នុងទំហំមួយសមស្រប ក្នុងការផ្តល់លទ្ធភាព និងភាពបត់បែនខ្ពស់ដល់រាជរដ្ឋាភិបាល ដើម្បីបំពេញតម្រូវការចំណាយមានមុខសញ្ញា និងចំណាយត្រៀមបម្រុង និងមិនបានគ្រោងទុកតាមមុខសញ្ញា សំដៅឆ្លើយតបទៅនឹងតម្រូវការចាំបាច់ជាយថាហេតុ របស់រាជរដ្ឋាភិបាល និងក្រសួង-ស្ថាប័ន បានទាន់ពេល ក្នុងការដោះស្រាយបញ្ហាសង្គម-សេដ្ឋកិច្ច និងការអនុវត្តគោលនយោបាយអាទិភាព និងវិធានការគន្លឹះនានា, ការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ, ការវិភាជកញ្ចប់ថវិកាការរៀបចំព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ និងកិច្ចការបន្ទាន់ចំពោះមុខផ្សេងទៀត ដូចជាការត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយធម្មជាតិ និងស្បៀងបម្រុង ជាដើម ។ ដោយឡែក, សម្រាប់ការអនុវត្តជាក់ស្តែង, ចំណាយថវិកាដែលបានគ្រោងក្នុងផ្នែកចំណាយផ្សេងៗនេះ នឹងត្រូវវិភាជទៅតាមវិស័យទាំង ៤ ខាងលើ ស្របតាមគោលដៅនៃមុខចំណាយនីមួយៗ ។

**ចំណាយសរុបរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងឆ្នាំ ២០២៧ ត្រូវបានគ្រោងក្នុងទំហំ ១,៩០% នៃ ផ.ស.ស. ដែលរួមបញ្ចូលការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងទំហំ ០,៧៦% នៃ ផ.ស.ស. ។ សម្រាប់ឆ្នាំ ២០២៨-២០២៩ ចំណាយសរុបរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានគ្រោងឱ្យមានកំណើនក្នុងអត្រាជាមធ្យម ប្រមាណ ៩,០% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១,៩៥% នៃ ផ.ស.ស. នៅឆ្នាំ ២០២៩** ។ ជារួម, កញ្ចប់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ ២០២៧-២០២៩ នេះនឹងមានការរីកធំ នៅពេលដាក់ឱ្យអនុវត្តអនុក្រឹត្យលេខ ២៤៩ អនក្រ.បក ស្តីពីការកំណត់អត្រាបែងចែកចំណូលពីសេវាសាធារណៈ និងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋពីរដ្ឋបាលថ្នាក់ជាតិ ជូនជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈយន្តការ **«មូលនិធិភាតរភាព»** ចាប់ពីឆ្នាំ ២០២៧ តទៅ និងការគិតគូរដំឡើងអត្រាវិភាជន៍ប្រចាំឆ្នាំ នៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដល់មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ បន្ថែមក្នុងអត្រា ០,១% សម្រាប់ឆ្នាំ ២០២៩ ។ ជាមួយគ្នានេះ, កញ្ចប់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០២៧-២០២៩ ក៏បានគិតគូរអំពីការដំឡើងប្រាក់ឧបត្ថម្ភសម្រាប់ក្រុមប្រឹក្សា នៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំង ៣ ថ្នាក់ និងមន្ត្រីភូមិ ព្រមទាំងសំដៅគាំទ្រដល់ការអភិវឌ្ឍ និងការលើកកម្ពស់គុណភាពនៃសេវាសាធារណៈនៅមូលដ្ឋាន, ការផ្តល់ប្រាក់ឧបត្ថម្ភលំហែមាតុភាពដល់សមាជិកក្រុមប្រឹក្សាជាស្ត្រី សម្រាប់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិទាំង ៣ ថ្នាក់ និងការបន្តពង្រឹងសមត្ថភាពផ្នែករដ្ឋបាល, បច្ចេកទេស និងការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីធានាការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវការផ្ទេរសិទ្ធិអំណាច ការទទួលខុសត្រូវមុខងារ និងធនធានពីថ្នាក់ជាតិ តាមរយៈការអនុវត្ត **យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ ២០២៦-២០៣០** និង **កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី ២ ឆ្នាំ ២០២១-២០៣០** ។

ដើម្បីសម្រេចបាននូវគោលដៅរក្សាស្ថិរភាពសង្គម និងការងើបវិញនូវកំណើនសេដ្ឋកិច្ច, រាជរដ្ឋាភិបាល ចាំបាច់ត្រូវពង្រឹងស័ក្តិសិទ្ធិភាពថវិកា, ទាំងផ្នែកវិភាជន៍ និងផ្នែកប្រតិបត្តិការ, ដោយឈរលើគោលការណ៍គោរព វិន័យថវិកា ប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ដោយផ្តោតសំខាន់លើ **"តម្លៃនៃលុយ"** ដើម្បីធានាឱ្យបាននូវចីរភាព ហិរញ្ញវត្ថុសាធារណៈ និងឆ្លើយតបទៅនឹងទិសដៅគោលនយោបាយ និងកម្មវិធីកែទម្រង់នានា តាមរយៈវិធានការ សំខាន់ៗក្នុងការអនុវត្តចំណាយ ២០២៧-២០២៩ ដូចខាងក្រោម ៖

- បន្តពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធលើកទឹកចិត្ត ចំពោះមន្ត្រីដែលមានគុណវុឌ្ឍិ ដើម្បីពង្រឹង សមត្ថភាពរដ្ឋបាលសាធារណៈ, សមិទ្ធកម្មការងារ, បង្កើនផលិតភាព និងប្រសិទ្ធភាពនៃការផ្តល់សេវា សាធារណៈ ក៏ដូចជាពិនិត្យលទ្ធភាពដំឡើងបៀវត្ស និងការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ក្នុងគោលដៅ រក្សាលំនឹងជីវភាពរស់នៅរបស់មន្ត្រីគ្រប់ថ្នាក់,
- កំណត់គោលការណ៍ក្នុងការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី, ទាំងមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់ អាវុធ, ដែលត្រូវសមាមាត្រនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ លើកលែងតែក្រសួងអាទិភាព,
- បន្តតម្រង់ធនធានថវិកាលើវិស័យគន្លឹះ ដែលនឹងធានាឱ្យបានភាពធន់ បរិយាប័ន្ន និងចីរភាព តាមរយៈ ការផ្តល់អាទិភាពទៅលើការកែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់រចនាសម្ព័ន្ធ, ការអភិវឌ្ឍមូលធន មនុស្ស, និងការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការជំរុញការធ្វើបរិវត្តកម្មឌីជីថល និងការអភិវឌ្ឍបៃតង,
- ផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងលទ្ធភាពចំណូល ដែលមានប្រភពពីការប្រមូលចំណូលក្នុងប្រទេស ដោយខិតខំមិនប្រើប្រាក់សន្សំរបស់រាជរដ្ឋាភិបាល លើកលែងតែករណីចាំបាច់បំផុត ដើម្បីរក្សា តុល្យភាព និងចីរភាពថវិកា តាមរយៈការធ្វើអាទិភាវូបនីយកម្មចំណាយ និងពង្រឹងប្រសិទ្ធភាពថវិកា, ទាំងកម្រិតវិភាជន៍ និងប្រតិបត្តិការ,
- ពង្រឹងនីតិវិធីនៃការគ្រប់គ្រង, រៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈ និងការជួសជុលថែទាំ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ,
- បន្តរក្សាចីរភាពបំណុលរយៈពេលមធ្យម និងវែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប តាមរយៈ ការកំណត់ពិតាននៃការខ្ចីប្រចាំឆ្នាំ និងការធានារបស់រដ្ឋ, ការកំណត់សូចនាករបំណុលគន្លឹះសំខាន់ៗ, ការកំណត់គោលដៅនៃការប្រើប្រាស់ហិរញ្ញប្បទាន និងការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យបានទូលំ- ទូលាយ, និង
- បន្តពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព និងគណនេយ្យភាពនូវ **យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ឆ្នាំ២០២៤-២០២៨** សំដៅធានាចីរភាពហិរញ្ញវត្ថុសាធារណៈ ដោយផ្តោតសំខាន់លើការវិនិយោគចំពោះវិស័យ អាទិភាព ជាពិសេស វិស័យបង្កើនផលិតភាព និងតម្លៃបន្ថែម, ជំរុញការតភ្ជាប់, និងពង្រឹងភាពប្រកួត- ប្រជែង និងពិពិធកម្មសេដ្ឋកិច្ច ។

## គ. ឱនភាពថវិកា និងហិរញ្ញប្បទាន

**ឱនភាពថវិកាសរុបសម្រាប់រយៈពេលមធ្យម** ត្រូវបានរំពឹងទុកថានឹងរួមតូចពីច្បាប់ថវិកាឆ្នាំ ២០២៦ ដែលឆ្លុះបញ្ចាំងអំពី ការដាក់ចេញនូវ **ជំហរអព្យាក្រឹត** ដោយអនុលោមតាមវិធានហិរញ្ញវត្ថុសាធារណៈ ដែលបានដាក់

ចេញ សំដៅរក្សាឱ្យបាននូវស្ថិរភាពហិរញ្ញវត្ថុសាធារណៈ និងចីរភាពបំណុលសាធារណៈរបស់កម្ពុជានាពេលខាងមុខ ។ **ក្នុងន័យនេះ, ឱនភាពថវិកាក្នុងឆ្នាំ ២០២៧ នឹង ស្ថិតក្នុងកម្រិត -១,៧៩% នៃ ផ.ស.ស. និងសម្រាប់ឆ្នាំ ២០២៨-២០២៩ នឹងស្ថិតក្នុងរង្វង់ជាមធ្យមប្រមាណ -១,៤០% នៃ ផ.ស.ស. ។** ជារួម, ហិរញ្ញប្បទានដើម្បីទ្រទ្រង់ឱនភាពថវិកាក្នុងរយៈពេលមធ្យមខាងមុខ នឹងបន្តទទួលបានមកពីប្រភព ៣ សំខាន់ៗ រួមមាន៖ **១)**. ហិរញ្ញប្បទានផ្ទាល់ពីក្រៅប្រទេស សម្រាប់គម្រោងវិនិយោគសាធារណៈ, **២)**. មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍, និង **៣)**. ការបោះផ្សាយមូលបត្ររដ្ឋ ។

## ឃ. លទ្ធផលក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមធៀបទៅនឹងវិធានហិរញ្ញវត្ថុសាធារណៈ

ជារួម, **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩** ត្រូវបានរៀបចំដោយប្រកាន់ខ្ជាប់នូវវិធានហិរញ្ញវត្ថុសាធារណៈ ដែលបានដាក់ចេញ ។ ជាក់ស្តែង, **បំណុលសាធារណៈសរុបរបស់កម្ពុជាសម្រាប់ឆ្នាំ ២០២៧-២០២៩ ជាតម្លៃបច្ចុប្បន្ន** ត្រូវបានប៉ាន់ស្មានថានឹងស្ថិតក្នុងកម្រិតជាមធ្យម ១៩,១៦% នៃ ផ.ស.ស. និង**ជាតម្លៃចារឹក** ក្នុងកម្រិតជាមធ្យម ២៧,៤៥% នៃ ផ.ស.ស. ខណៈសូចនាករចំនួន ៤ ផ្សេងទៀតរបស់យុថ្កាហិរញ្ញវត្ថុសាធារណៈ ក៏ស្ថិតក្នុងកម្រិតទាបជាងពិតានដែលបានកំណត់ ។ បន្ថែមលើនេះ, ឱនភាពថវិកាសម្រាប់ឆ្នាំ ២០២៦ ក៏ត្រូវបានប៉ាន់ស្មានថានឹងស្ថិតក្រោមកម្រិតកំណត់ដោយវិធានប្រតិបត្តិ ផងដែរ ។

### តារាងទី ៨៖ តារាងសង្ខេបក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៧-២០២៩

| ភាគរយនៃ ផ.ស.ស. | 2026 ច្បា. | 2026 កែ. | 2027 ព្យ. | 2028 ព្យ. | 2029 ព្យ. |
|---|---|---|---|---|---|
| **ចំណូលសរុប** | **14.89%** | **15.25%** | **15.24%** | **15.16%** | **15.16%** |
| ចំណូលចរន្ត | 14.37% | 14.73% | 14.76% | 14.70% | 14.68% |
| **ចំណាយសរុប** | **18.60%** | **18.60%** | **17.03%** | **16.69%** | **16.43%** |
| ចំណាយចរន្ត | 12.42% | 12.42% | 12.41% | 12.14% | 11.85% |
| ចំណាយមូលធន | 6.18% | 6.18% | 4.62% | 4.54% | 4.58% |
| **អតិរេកចរន្ត** | **1.95%** | **2.31%** | **2.36%** | **2.55%** | **2.83%** |
| **សមតុល្យថវិកា** | **-3.71%** | **-3.36%** | **-1.79%** | **-1.53%** | **-1.26%** |
| ***តម្រូវការហិរញ្ញប្បទាន*** | ***5.13%*** | ***4.78%*** | ***3.83%*** | ***3.36%*** | ***3.26%*** |
| *ឱនភាពថវិកា* | 3.71% | 3.36% | 1.79% | 1.53% | 1.26% |
| *ការទូទាត់ការខ្ចី* | 1.21% | 1.21% | 1.57% | 1.36% | 1.53% |
| *ការបង្វិលសងអាករលើតម្លៃបន្ថែម* | 0.20% | 0.21% | 0.47% | 0.47% | 0.47% |
| ***ប្រភពហិរញ្ញប្បទាន*** | ***5.13%*** | ***4.78%*** | ***3.83%*** | ***3.36%*** | ***3.26%*** |
| *ហិរញ្ញប្បទានក្រៅប្រទេស* | 2.97% | 2.97% | 2.55% | 2.41% | 2.35% |
| *មូលនិធិទ្រទ្រង់ថវិកា* | 0.99% | 0.99% | 0.46% | 0.16% | 0.15% |
| *ការបោះផ្សាយមូលបត្ររដ្ឋ* | 0.96% | 0.96% | 0.34% | 0.32% | 0.30% |
| *ប្រាក់បញ្ញើរាជរដ្ឋាភិបាល* | 0.00% | -0.33% | 0.00% | 0.00% | 0.00% |
| *ការបង្វិលសងអាករលើតម្លៃបន្ថែម* | 0.20% | 0.20% | 0.47% | 0.47% | 0.47% |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## តារាងទី ៩៖ ការព្យាករសូចនាករវិធានហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៦-២០២៩

| សូចនាករ | អនុបាតគោល | 2026ប៉ាន់. | 2027ព្យ. | 2028ព្យ. | 2029ព្យ. |
|---|---|---|---|---|---|
| **១. យុទ្ធាហិរញ្ញវត្ថុសាធារណៈ** | | | | | |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស. | **55%** | 19.25% | 19.21% | 19.21% | 19.04% |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផ.ស.ស. | **40%** | 17.89% | 17.91% | 17.85% | 17.94% |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ | **180%** | 25.66% | 25.10% | 24.30% | 23.73% |
| អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ | **15%** | 1.96% | 1.89% | 1.84% | 1.77% |
| អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ចំណូលថវិកាជាតិ | **18%** | 8.98% | 8.87% | 8.92% | 8.83% |
| អនុបាតតម្លៃចារឹកនៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស. | **65%** | 26.92% | 27.27% | 27.51% | 27.57% |
| **២. វិធានប្រតិបត្តិ** | | | | | |
| ឱនភាពថវិកាសរុប | **-5%** | -3.36% | -1.79% | -1.53% | -1.26% |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

# ៥

# ហានិភ័យហិរញ្ញវត្ថុសាធារណៈ

**ហានិភ័យហិរញ្ញវត្ថុសាធារណៈ** សំដៅដល់ព្រឹត្តិការណ៍ ឬ ការប៉ះទង្គិចណាមួយ ដែលធ្វើឱ្យស្ថានភាពហិរញ្ញវត្ថុសាធារណៈប្រែប្រួល ដោយពុំបានគ្រោងទុក ដូចជា ការប្រមូលចំណូល សម្រេចបានទាបជាងការ-គ្រោងទុក និង/ឬ ធ្វើឱ្យទំហំនៃចំណាយសរុបច្រើនជាងការកំណត់ ដែលជាលទ្ធផលធ្វើឱ្យឱនភាពថវិការីកធំ ។ ការវាយតម្លៃហានិភ័យហិរញ្ញវត្ថុសាធារណៈ រួមមាន ការវិភាគអំពីមូលដ្ឋាននៃហានិភ័យ, ការប៉ាន់ប្រមាណនូវភាពអាចកើតមានឡើង និងទំហំនៃកម្មវិបាក ព្រមទាំងភ្ជាប់មកជាមួយនូវការរៀបចំ និងអនុវត្តយន្តការគ្រប់គ្រងចាំបាច់នានា ។

ផ្អែកលើការប្រមូលផ្តុំទិន្នន័យ និងការវិភាគ ដោយមានការចូលរួមពីអគ្គនាយកដ្ឋានពាក់ព័ន្ធ, ហានិភ័យហិរញ្ញវត្ថុសាធារណៈ ក្នុង **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩** នេះ ត្រូវបានបែងចែកជា ៨ ហានិភ័យធំៗ ។ ជារួម, **ហានិភ័យម៉ាក្រូសេដ្ឋកិច្ច** និង **ហានិភ័យពីវិស័យហិរញ្ញវត្ថុ** ជាហានិភ័យតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់ ដោយមានទំហំកម្មវិបាកធំ និងមានលទ្ធភាពកម្រិតខ្ពស់ ផ្អែកតាមការវិវត្តនៃស្ថានភាពសង្គម-សេដ្ឋកិច្ចជាក់ស្តែង ។ រីឯហានិភ័យហិរញ្ញវត្ថុសាធារណៈជាក់លាក់មួយចំនួនទៀត ក៏ត្រូវបានពិនិត្យ និងវាយតម្លៃ ផងដែរ ។ ក្នុងនោះ, **ហានិភ័យស្តីពីភាពជឿទុកចិត្តបាននៃក្របខ័ណ្ឌ** មានទាំងលទ្ធភាព និងទំហំនៃកម្មវិបាក ក្នុងកម្រិតមធ្យម; ខណៈ **ហានិភ័យបំណុលរបស់រដ្ឋាភិបាល**, **ហានិភ័យពីសហគ្រាសសាធារណៈ**, **ហានិភ័យពីវិនិយោគសាធារណៈ**, **និង** **ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ** ត្រូវបានវាយតម្លៃថាស្ថិតក្នុងលទ្ធភាពកម្រិតមធ្យម និងទំហំនៃកម្មវិបាក កម្រិតទាប; និងជាចុងក្រោយ **ហានិភ័យនៃការធានារបស់រដ្ឋកើតចេញពីគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP)** ត្រូវបានវាយតម្លៃក្នុងកម្រិតទាប ទាំងលើលទ្ធភាព និងទំហំនៃកម្មវិបាក ។

### តារាងទី ១០៖ សេចក្តីសង្ខេបកម្រិតលទ្ធភាព និងទំហំកម្មវិបាកនៃហានិភ័យ

| កម្រិតលទ្ធភាព | ទំហំកម្មវិបាក | |
|---|---|---|
| ខ្ពស់ | ខ្ពស់ | **ហានិភ័យម៉ាក្រូសេដ្ឋកិច្ច** ប្រឈមនឹងកត្តាចម្បង ៥ រួមមាន៖ ១). ភាពតានតឹងភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចពិសេសសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា, ២). ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃរបបពាណិជ្ជកម្មសកល, ៣). ភាពមិនច្បាស់លាស់ នៃស្ថានភាពព្រំដែនកម្ពុជា-ថៃ, ៤). ការថមថយកំណើនសេដ្ឋកិច្ចសកល, និង ៥). ភាពមិនជោគជ័យនៃវិធានការកែទម្រង់ ។ |

| | | |
|---|---|---|
| ខ្ពស់ | ខ្ពស់ | **ហានិភ័យពីវិស័យហិរញ្ញវត្ថុ** ប្រឈមទៅនឹងហានិភ័យសំខាន់ៗ ២ រួមមាន៖ ១). ការធ្លាក់ចុះនៃសេដ្ឋកិច្ច និងការថមថយនៃកំណើនឥណទាន, និង ២). ការថយចុះនូវគុណភាពទ្រព្យសកម្ម ខណៈអនុបាតឥណទានមិនដំណើរការកើនឡើង ។ |
| មធ្យម | មធ្យម | **ភាពជឿទុកចិត្តបាននៃក្របខ័ណ្ឌ** ត្រូវរងឥទ្ធិពលពីភាពមិនប្រាកដប្រជាខ្ពស់នៃសេដ្ឋកិច្ច និងគោលនយោបាយជាតិ និងអន្តរជាតិ បង្កើតជាបញ្ហាប្រឈមដល់ការប៉ាន់ស្មានការប្រមូលចំណូល, លទ្ធផលនៃការប្រមូលចំណូលជាក់ស្តែង, និងការកើនឡើងនៃតម្រូវការចំណាយ ។ |
| មធ្យម | ទាប | **ហានិភ័យចំណូលរបស់រដ្ឋាភិបាល** រងសម្ពាធពីភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល, ការកើនឡើងសម្ពាធអតិផរណា, អត្រាការប្រាក់ខ្ពស់នៅក្នុងទីផ្សារ និងការកែសម្រួលគោលនយោបាយក្នុងការផ្តល់ហិរញ្ញប្បទានដល់កម្ពុជា បូករួមនឹងការត្រៀមខ្លួនចាកចេញពីក្រុមប្រទេសអភិវឌ្ឍតិចតួច របស់កម្ពុជា ។ |
| មធ្យម | ទាប | **ហានិភ័យពីសហគ្រាសសាធារណៈ** អាចបណ្តាលមកពីលក្ខខណ្ឌសេដ្ឋកិច្ច និងនយោបាយអន្តរជាតិ និងក្នុងស្រុក ដែលអាចធ្វើឱ្យមានប៉ះពាល់ដល់ស្ថានភាពហិរញ្ញវត្ថុ ក៏ដូចជាលទ្ធភាពសងត្រលប់ មករាជរដ្ឋាភិបាលវិញ ។ |
| មធ្យម | ទាប | **ហានិភ័យពីវិនិយោគសាធារណៈ** អាចកើតមានឡើងទាំងចំពោះ គម្រោងវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស និង ដោយថវិកាថ្នាក់ជាតិ, ក្នុងករណីមានចន្លោះប្រហោងក្នុងការគ្រប់គ្រង និងអនុវត្តគម្រោង ។ |
| មធ្យម | ទាប | **ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ** ពិសេសការកើនឡើងកម្តៅ និងលទ្ធភាពដែលអាចឈានដល់គ្រោះរាំងស្ងួត នឹងធ្វើឱ្យប៉ះពាល់ដល់វិស័យសេដ្ឋកិច្ចមួយចំនួន ពិសេស វិស័យកសិកម្ម ។ |
| ទាប | ទាប | **ភាពជាដៃគូរវាងរដ្ឋ និងឯកជន** អាចបង្កើតជាហានិភ័យតាមរយៈកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ ២ ប្រភេទដល់រាជរដ្ឋាភិបាល៖ ១). កាតព្វកិច្ចហិរញ្ញវត្ថុផ្ទាល់ដែលបច្ចុប្បន្ន រាជរដ្ឋាភិបាលពុំមាន; និង ២). កាតព្វកិច្ចបំណុលជាយថាហេតុដោយក្នុងនោះ ការធានាទូទាត់របស់រដ្ឋ ត្រូវបានធ្វើឡើងតែចំពោះគម្រោងក្នុងវិស័យថាមពល ប៉ុណ្ណោះ ។ |

## ក. ហានិភ័យម៉ាក្រូសេដ្ឋកិច្ច

**ហានិភ័យម៉ាក្រូសេដ្ឋកិច្ច** សំដៅដល់ព្រឹត្តិការណ៍ ឬការវិវត្តណាមួយ ដែលបង្កជាផលអវិជ្ជមានដោយផ្ទាល់ និងប្រយោល ដល់កំណើនសេដ្ឋកិច្ចជាតិ ដែលជាមូលដ្ឋានសម្រាប់ការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ។ ក្នុងន័យនេះ ការប្រែប្រួលនៅក្នុងកម្រិតណាមួយ រាប់បញ្ចូលទាំងកត្តាខាងក្នុង និងខាងក្រៅ នឹងមានផលជះទាំងវិជ្ជមាន និងអវិជ្ជមានដល់ការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ពោលទាំងផ្នែកចំណូល និងផ្នែកចំណាយ ។ ជារួម, ហានិភ័យម៉ាក្រូសេដ្ឋកិច្ច នឹងជះឥទ្ធិពលដោយផ្ទាល់ និងប្រយោល ដល់សមតុល្យថវិការដ្ឋ (Overall budget balance), ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមានកម្មវិបាកក្នុងការធ្វើព្យាសកម្មនៃទិសដៅគោលនយោបាយសំខាន់ៗ របស់រាជរដ្ឋាភិបាល ដែលផ្សារភ្ជាប់ទៅនឹងលទ្ធភាពនៃថវិកា ។ សម្រាប់រយៈពេលមធ្យមខាងមុខ, ហានិភ័យម៉ាក្រូសេដ្ឋកិច្ច ត្រូវបានវាយតម្លៃថា ហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់ ដែលជាចរន្តនៃផលប៉ះពាល់មិនកម្រិតត្រឹមកំណើនសេដ្ឋកិច្ច និង សូចនាករសង្គមគន្លឹះៗ ជាអាទិ៍ អត្រាអ្នកគ្មានការងារធ្វើ និងអត្រាវិសមភាពសង្គម តែប៉ុណ្ណោះទេ; ប៉ុន្តែ, ក៏នឹងនាំមកនូវផលប៉ះពាល់ទៅលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផងដែរ ។ ក្នុងន័យនេះ, ហានិភ័យម៉ាក្រូសេដ្ឋកិច្ច មានលទ្ធភាពកើតឡើងក្នុងកម្រិតខ្ពស់ និងមានទំហំកម្មវិបាកក្នុងកម្រិតខ្ពស់ ដែលបង្កឡើងដោយ កត្តាចម្បងចំនួន ៥ រួមមាន៖

១). **ភាពតានតឹងភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចពិសេសសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា** បាន និងកំពុងបង្កជាបញ្ហាប្រឈម តាមរយៈការបង្កជាសម្ពាធមកលើសេដ្ឋកិច្ចសកល និងតំបន់ រាប់ទាំងកម្ពុជា ផងដែរ ។ ក្នុងនោះ, ច្រវាក់ផ្គត់ផ្គង់សកលត្រូវបានបន្ទប់បង្អាក់ ពិសេសក្នុងវិស័យថាមពល ខណៈតម្រូវការសកល, វិហូរទេសចរណ៍ និងទំនុកចិត្តវិនិយោគិន ជាដើម ក៏រងនូវផលប៉ះទង្គិច ដែលទាំងអស់នេះសុទ្ធសឹងជាកត្តាដែលមានវេទយិតភាពខ្ពស់ ទៅនឹងវិស័យជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ។ ជាមួយគ្នានេះ, ការបន្តហក់ឡើងខ្ពស់នៃថ្លៃប្រេងឥន្ធនៈអន្តរជាតិ ដែលជាកម្មវិបាកនៃសង្គ្រាមនេះ ក៏បានបង្កើតនូវសម្ពាធអតិផរណា ដែលដាក់បន្ទុកបន្ថែមលើជីវភាពប្រជាជន ពិសេសទៅលើក្រុមប្រជាជនដែលស្ថិតនៅក្បែរ និងក្រោមបន្ទាត់ភាពក្រីក្រ,

២). **ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃរបបពាណិជ្ជកម្មសកល** ពិសេសតាមរយៈការដាក់ចេញនូវពន្ធគយជាសកល (Global tariff) ក៏ផ្តល់ជាមិស្សភាពបន្ថែមទៀតដល់វិស័យបម្រើការនាំចេញកម្ពុជា ពិសេសវិស័យកាត់ដេរ និងមិនមែនកាត់ដេរ ដែលពឹងផ្អែកខ្លាំងលើតម្រូវការខាងក្រៅ រួមបញ្ចូលទាំងទីផ្សារសហរដ្ឋអាម៉េរិក ។ ជាមួយគ្នានេះ, ការបន្តស្ថិតក្នុងការស៊ើបអង្កេតឧបាស្រ័យពាណិជ្ជកម្មរបស់សហរដ្ឋអាម៉េរិក លើផលិតផលនាំចេញសំខាន់ៗមួយចំនួន រួមមាន គ្រឿងសង្ហារិមធ្វើអំពីឈើ, ផលិតផលធ្វើពីអាលុយមីញ៉ូម និងគ្រឿងបន្លាស់រថយន្ត ក៏នៅតែផ្តល់មិស្សភាពខ្ពស់ដល់វិស័យបម្រើការនាំចេញរបស់កម្ពុជាផងដែរ ពិសេសវិស័យកម្មន្តសាលមិនមែនកាត់ដេរ ។ ត្បិតវិស័យកម្មន្តសាលមិនមែនកាត់ដេរបន្តមានកំណើនរឹងមាំ ប៉ុន្តែបើមានការប្រែប្រួលនូវរបបពន្ធ ឬផ្លាស់ប្តូរនូវ អត្រាពន្ធណាមួយពីភាគីអាម៉េរិក នោះវិស័យនេះនឹងទទួលការប៉ះទង្គិចភ្លាមៗ ដែលស្តែងឱ្យឃើញច្បាស់ថា វិស័យនេះមានកំណើនខ្ពស់ ប៉ុន្តែនៅមានភាពផុយស្រួយ ហើយងាយនឹងរងគ្រោះ (High growth but fragile and vulnerable),

៣). **ការថមថយសន្ទុះកំណើនសេដ្ឋកិច្ចសកល** ពិសេសនៅសហភាពអឺរ៉ុប ក៏អាចប៉ះពាល់ដល់តម្រូវការ និងការបញ្ជាទិញ ពិសេសផលិតផលកាត់ដេររបស់កម្ពុជាផងដែរ, ដែលការណ៍នេះនឹងធ្វើឱ្យប៉ះពាល់ដល់ទស្សនវិស័យនៃកំណើនវិស័យកាត់ដេរ ជារួម,

៤). **ភាពមិនច្បាស់លាស់នៃស្ថានភាពព្រំដែនកម្ពុជា-ថៃ** ក្នុងន័យថាអាចវិវត្តទៅរកការប៉ះទង្គិចប្រដាប់អាវុធថ្មី ឬការធ្វើវិទ្ធង្សនាសេដ្ឋកិច្ចមកលើកម្ពុជា ដែលនឹងធ្វើឱ្យចំនួនប្រជាពលរដ្ឋភៀសសឹក ហក់ខ្ពស់ឡើងមកវិញ, បន្ទប់បង្អាក់ដល់សកម្មភាពផលិតកម្មនៅតាមតំបន់ព្រំដែន និងផលិតកម្មថៃបូកមួយ, និងការត្រលប់មកបន្ថែមទៀតនៃពលករទេសន្តរប្រវេសន៍ដែលកំពុងធ្វើការនៅប្រទេសថៃ ដែលធ្វើឱ្យប៉ះពាល់កាន់តែធ្ងន់ធ្ងរដល់ប្រាក់បង្វែរងកជន ព្រមទាំងអត្រាអ្នកគ្មានការងារធ្វើ ។ ទន្ទឹមនេះ, ការប៉ះទង្គិចប្រដាប់អាវុធជាថ្មីម្តងទៀត ក៏នឹងដាក់សម្ពាធដល់ផ្នែកចំណាយសាធារណៈផងដែរ តាមរយៈតម្រូវការអន្តរាគមន៍គាំពារសង្គម ខណៈពេលដែលលម្ហវិកាសម្រាប់ចំណាយវិនិយោគសាធារណៈ ក៏កាន់តែស្រេកស្រុតទៅៗ, និង

៥). **ភាពមិនជោគជ័យនៃការកែទម្រង់ផ្ទៃក្នុង** ដែលបណ្តាលឱ្យបញ្ហាប្រឈមជារចនាសម្ព័ន្ធផ្ទៃក្នុងរបស់កម្ពុជា នៅបន្តរាំងស្ទះដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច, ការពង្រឹងភាពប្រកួតប្រជែង, ការពង្រឹងគុណភាពនៃកម្លាំងពលកម្ម ដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារ, និងការចាប់យកឧស្សាហកម្ម

តម្លៃបន្ថែមខ្ពស់ ជាពិសេសឧស្សាហកម្មដើមខ្សែ (Upstream industries) និងឧស្សាហកម្មប្រតិគមន៍ ដើម្បីថ្លក់ភ្ជាប់ឧស្សាហកម្មទាំងនោះ ទៅនឹងខ្សែច្រវាក់ផលិតកម្មក្នុងស្រុក ។

យ៉ាងណាមិញ, រាជរដ្ឋាភិបាលនៅតែបន្តខិតខំប្រឹងប្រែងរក្សាស្ថិរភាព និងកំណើនសេដ្ឋកិច្ចជាតិ ពិសេសតាមរយៈការកាត់បន្ថយការពឹងផ្អែកលើកត្តាខាងក្រៅ, ការបង្កើនសមត្ថភាព និងពង្រឹងឯករាជ្យភាពនៃកម្លាំងសេដ្ឋកិច្ចក្នុងស្រុក, ការបង្វែរទិសដៅដឹកជញ្ជូន (Re-routing), ការផ្លាស់ប្តូរមធ្យោបាយដឹកជញ្ជូន, និងការធ្វើពិពិធកម្មនៃច្រវាក់ផលិតកម្ម និងនាំចេញ ពិសេសការធ្វើពិពិធកម្មនៃទេសចរណ៍ ជាដើម ។

### ប្រអប់ទី១៖ ការវិភាគវេទយិតភាពនៃសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា

ដូចបានគូសបញ្ជាក់នៅក្នុងផ្នែកខាងលើ, ស្ថានការណ៍ជារួម នៅតែមានភាពមិនប្រាកដប្រជា និងភាពចល័តខ្ពស់ ក្នុងន័យថាស្ថានភាពនៅតំបន់មជ្ឈិមបូព៌ាអាចនឹងប្រែប្រួលទៅក្នុងទិសដៅណាមួយហួសជាងការរំពឹងទុក និងមិនអាចប៉ាន់ប្រមាណបាន ។ ក្នុងន័យនេះ, ករណីដែលថាស្ថានការណ៍នៅតំបន់មជ្ឈិមបូព៌ាមានការកើនកម្តៅខ្លាំងឡើងវិញ ដែលនាំឱ្យមានសង្គ្រាមកាន់តែមានប្រពលភាព (Intensity) ខ្លាំងទៅៗ នោះនឹងកាន់តែបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដែលជាលទ្ធផលធ្វើឱ្យថ្លៃប្រេងឥន្ធនៈហក់ឡើងខ្ពស់ខ្លាំង ។ បើផ្អែកតាមស្ថាប័នអន្តរជាតិធំៗ រួមទាំងធនាគារពិភពលោក, ក្នុងករណីដែលសង្គ្រាមបង្កផលប៉ះពាល់ខ្លាំងដល់ហេដ្ឋារចនាសម្ព័ន្ធ និងបន្ទប់បង្អាក់ដល់ការដឹកជញ្ជូនប្រេងឥន្ធនៈ ដល់ជិតដំណាច់ឆ្នាំ ២០២៦ នោះថ្លៃប្រេងឥន្ធនៈអន្តរជាតិជាមធ្យម ក្នុងឆ្នាំ ២០២៦ អាចហក់ឡើងក្នុងចន្លោះពី ៨៨ ទៅ ១០០ ដុល្លារអាម៉េរិក/បារ៉ែល ។ ក្នុងករណីដែលបង្កផលប៉ះពាល់ធ្ងន់ធ្ងរ នោះថ្លៃប្រេងឥន្ធនៈអន្តរជាតិ ជាមធ្យម ក្នុងឆ្នាំ ២០២៦ នេះ អាចហក់ឡើងក្នុងចន្លោះ ប្រមាណ ១១០ ទៅ ១៣៥ ដុល្លារអាម៉េរិក/បារ៉ែល ។ ដើម្បីជាមូលដ្ឋានក្នុងការវិភាគវេទយិតភាព, សេណារីយ៉ូទី១ សន្មតថាថ្លៃប្រេងឥន្ធនៈអន្តរជាតិ ក្នុងឆ្នាំ ២០២៦ នឹងហក់ឡើងដល់ជាមធ្យម ប្រមាណ ៩៥ ដុល្លារអាម៉េរិក/បារ៉ែល ខណៈដែល សេណារីយ៉ូទី២ ថ្លៃប្រេងនឹងបន្តហក់ឡើងខ្ពស់ដល់ជាមធ្យម ប្រមាណ ១១០ ដុល្លារអាម៉េរិក/បារ៉ែល ។

**ឈរលើមូលដ្ឋាននេះ, កំណើនសេដ្ឋកិច្ចកម្ពុជា ត្រូវបានរំពឹងថានឹងថមថយមកនៅប្រមាណ ៣,៦% ខណៈអត្រាអតិផរណា នឹងកើនដល់ប្រមាណ ៥,០% ក្នុងសេណារីយ៉ូទី១, ខណៈដែលសេណារីយ៉ូទី២ កំណើនសេដ្ឋកិច្ច នឹងបន្តថមថយបន្ថែមទៀត មកត្រឹមប្រមាណ ២,៦% ហើយអត្រាអតិផរណា អាចនឹងកើនដល់ប្រមាណ ៦,២% ។** ជារួម ក្នុងសេណារីយ៉ូទាំងពីរ កម្រិតខ្ពស់នៃថ្លៃប្រេងឥន្ធនៈមិនត្រឹមតែបង្កសម្ពាធលើផ្នែកផ្គត់ផ្គង់ (Supply-side shocks) ប៉ុណ្ណោះទេ ប៉ុន្តែក៏ប៉ះពាល់ដល់ផ្នែកតម្រូវការ (Demand-side shocks) ផងដែរ តាមរយៈការកើនថ្លៃដើមផលិតកម្ម ការថមថយនៃអំណាចទិញ និងការធ្លាក់ចុះនៃទំនុកចិត្តវិនិយោគ ។ សម្រាប់កម្ពុជា ដែលពឹងផ្អែកខ្លាំងលើការនាំចូលប្រេងឥន្ធនៈ ផលប៉ះពាល់នឹងមានភាពច្បាស់លាស់ និងធ្ងន់ធ្ងរជាងមុន ជាពិសេសលើវិស័យដែលប្រើប្រាស់ថាមពលខ្ពស់ ។ ក្នុងករណីថ្លៃប្រេងបន្តកើនឡើងខ្ពស់ ឬកើតមានការខ្វះខាតផ្គត់ផ្គង់ប្រេងតែម្តង នឹងប៉ះពាល់ដោយផ្ទាល់ដល់សកម្មភាពសេដ្ឋកិច្ច ដូចជា វិស័យដឹកជញ្ជូន, វិស័យផលិតកម្ម ឧស្សាហកម្ម, វិស័យទេសចរណ៍, វិស័យកសិកម្ម, និងវិស័យលក់ដុំ-រាយ និងការថមថយការចាយវាយ និងការប្រើប្រាស់ក្នុងស្រុក ជារួម ។ ក្នុងន័យនេះ, សេណារីយ៉ូទាំងពីរបង្ហាញឱ្យឃើញថា ហានិភ័យពីថ្លៃប្រេងឥន្ធនៈខ្ពស់ អាចបង្កផលប៉ះពាល់ជាស៊េរី (Cascading effects) ទៅលើសេដ្ឋកិច្ចទាំងមូល តាមរយៈបណ្តាញច្រវាក់ផលិតកម្ម និងការប្រើប្រាស់ ដែលទាមទារឱ្យមានការត្រៀមខ្លួនប្រកបដោយស្មារតីបុរេសកម្មខ្ពស់ នៃផ្នែកវិធានការគោលនយោបាយ ដើម្បីទប់ទល់ និងកាត់បន្ថយផលប៉ះពាល់ទាំងនេះ ។

## ខ. ហានិភ័យពីវិស័យហិរញ្ញវត្ថុ

**ហានិភ័យពីវិស័យហិរញ្ញវត្ថុ** សំដៅដល់ការកើតមានវិបត្តិហិរញ្ញវត្ថុ នៃគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ ដែលអាចបង្កើតជាកាតព្វកិច្ចបំណុលដោយផ្ទាល់ និងប្រយោល និងបង្កើនចំណាយរបស់រាជរដ្ឋាភិបាល ។ ក្នុងករណីវិស័យហិរញ្ញវត្ថុមានវិបត្តិ, រាជរដ្ឋាភិបាលត្រូវបាត់បង់ប្រាក់ចំណូលជាតិ និងបង្កើនចំណាយមួយផ្នែកធំ សំដៅរក្សាស្ថិរភាពសង្គម-សេដ្ឋកិច្ច ពិសេសផ្តល់ការគាំទ្រដល់ស្ថាប័នហិរញ្ញវត្ថុដែលមានវិបត្តិ ដែលការណ៍នេះនឹងបង្កបានជាសម្ពាធក្នុងកម្រិតខ្ពស់ដល់ស្ថិរភាពហិរញ្ញវត្ថុសាធារណៈ ។ ក្នុងន័យនេះ, ការប្រែប្រួលក្នុងវិស័យហិរញ្ញវត្ថុ មានផលជះខ្ពស់ដល់ស្ថានភាពហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាស្ថានភាពម៉ាក្រូ-សេដ្ឋកិច្ចកម្ពុជា, ទាំងដោយផ្ទាល់ និងដោយប្រយោល, តាមរយៈឥទ្ធិពលសាយភាយ (Spillover effect) ដល់សកម្មភាពរស់នៅរបស់ប្រជាពលរដ្ឋ ក៏ដូចជាវិស័យដទៃទៀត ។ ដូចគ្នាដែរ, ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងនយោបាយអន្តរជាតិ ក៏ផ្តល់ផលប៉ះពាល់ដោយផ្ទាល់ និងប្រយោល ដល់ស្ថិរភាពនៃវិស័យហិរញ្ញវត្ថុផងដែរ ។

ទោះជាយ៉ាងនេះក្តី, ការប្រែប្រួលអត្រាការប្រាក់ពិភពលោក ក្នុងឆ្នាំ ២០២០-២០២៥ មិនបានជះឥទ្ធិពលគួរឱ្យកត់សម្គាល់ដល់អត្រាការប្រាក់បញ្ញើ និងឥណទាន ក្នុងប្រព័ន្ធធនាគារកម្ពុជាឡើយ ដោយសារប្រភពមូលនិធិចម្បង របស់វិស័យធនាគារ គឺប្រាក់បញ្ញើក្នុងស្រុក ដែលមានទំហំប្រមាណ ៦៦% ក្នុងឆ្នាំ ២០២០ និងបានកើនដល់ ៧១% ក្នុងឆ្នាំ ២០២៥ ។ ការណ៍នេះបង្ហាញថា ប្រព័ន្ធធនាគារកម្ពុជាពឹងផ្អែកកាន់តែខ្លាំងលើមូលនិធិក្នុងស្រុក ដែលមានស្ថិរភាព និងអាចជួយកាត់បន្ថយការពឹងផ្អែកលើមូលនិធិពីក្រៅប្រទេស ព្រមទាំងពង្រឹងភាពធន់ និងចីរភាពនៃមូលដ្ឋានហិរញ្ញវត្ថុរបស់ប្រព័ន្ធធនាគារ ។

យ៉ាងណាមិញ, សម្រាប់រយៈពេលមធ្យមខាងមុខ, ហានិភ័យពីវិស័យហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាមានលទ្ធភាពកើតឡើងក្នុងកម្រិតខ្ពស់ និងមានកម្មវិបាកលើហិរញ្ញវត្ថុសាធារណៈក្នុងកម្រិតខ្ពស់ ដោយប្រឈមទៅនឹងហានិភ័យសំខាន់ៗ ២ រួមមាន៖ ១). **ការធ្លាក់ចុះនៃសេដ្ឋកិច្ច និងការថមថយនៃកំណើនឥណទាន (Slow growth of credits)** ដោយសារកត្តាមួយចំនួន ដូចជា៖ ការធ្លាក់ចុះនៃការនាំចេញ ការថយចុះនូវការផ្ញើរប្រាក់ (Lower remittance) និងផលប៉ះពាល់ពីសង្គ្រាមឈ្លានពានដោយយោធាថៃ ជាដើម ដែលធ្វើឱ្យតម្រូវការឥណទានធ្លាក់ចុះ ខណៈគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ រឹតបន្តឹងការបញ្ចេញឥណទាន, និង ២). **ការថយចុះនូវគុណភាពទ្រព្យសកម្ម (Asset quality deterioration) ខណៈអនុបាតឥណទានមិនដំណើរការ (NPL) កើនឡើង** ដែលបណ្តាលមកពីការដកចេញនូវការអនុគ្រោះផ្នែកបទប្បញ្ញត្តិ បន្ទាប់ពីកម្ពុជាបានចាកចេញពីវិបត្តិជំងឺកូវីដ-១៩ (អនុបាត NPLs មានកម្រិត ៨,៨% ឬ ប្រមាណ ៥,៥ ប៊ីលានដុល្លារអាម៉េរិក គិតត្រឹមដំណាច់ខែតុលា ឆ្នាំ២០២៥), ការថយចុះនៃកំណើនឥណទាន, និងការដាក់ចេញវិធានការអនុគ្រោះជាបន្តបន្ទាប់ សម្រាប់រយៈពេល ៣ - ៥ឆ្នាំ ខាងមុខ អាចនឹងធ្វើឱ្យ NPLs កើនដល់កម្រិតប្រមាណ ១០% ។

ក្នុងន័យនេះ, ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បានពង្រឹងការតាមដានស្ថានភាពហិរញ្ញវត្ថុ និងហានិភ័យសំខាន់ តាមរយៈ ១). ត្រួតពិនិត្យជាប្រចាំចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ តាមរយៈការត្រួតពិនិត្យលើឯកសារ និងដល់ទីកន្លែង, ២). ការតាមដានជាប្រចាំលើស្ថានភាពទូទៅ ភាពធន់ និងស្ថិរភាពនៃប្រព័ន្ធធនាគារទាំងមូល តាមរយៈ ការអនុវត្តក្របខ័ណ្ឌនៃការត្រួតពិនិត្យផ្អែកលើហានិភ័យ និងទស្សនៈអនាគត, ៣). ការដាក់ចេញបទប្បញ្ញត្តិថ្មី និងកែសម្រួលបទប្បញ្ញត្តិដែលមានស្រាប់ជាបន្តបន្ទាប់ ដើម្បីធានាវឌ្ឍនភាពនៃប្រព័ន្ធធនាគារ និងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព, និង

**៤).** កែសម្រួលសេចក្តីណែនាំស្តីពី ការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា និងសាយប័រ (Cyber) របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុឱ្យស្របទៅតាមការវិវត្តនៃបច្ចេកវិទ្យា និងហានិភ័យដែលអាចកើតមាន ។

## គ. ហានិភ័យនៃការធានារបស់រដ្ឋកើតចេញពីភាពជាដៃគូរវាងរដ្ឋ និងឯកជន

គម្រោងការអនុវត្តយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (Public-Private Partnerships - PPP) សំដៅដល់គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និង/ឬ គម្រោងផ្តល់សេវាសាធារណៈ ដែលអនុវត្តក្រោមក្របខ័ណ្ឌកិច្ចសន្យា PPP រវាងភាគីរដ្ឋ និងឯកជន ដោយដៃគូឯកជនត្រូវធ្វើការវិនិយោគ ទទួលបន្ទុកហានិភ័យមួយចំណែក និងទទួលអត្ថប្រយោជន៍ផ្អែកលើសមិទ្ធកម្ម និងលក្ខខណ្ឌនៃកិច្ចសន្យា ។ ជារួម, គម្រោង PPP អាចបង្កើតជាហានិភ័យតាមរយៈកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ ចំនួន ២ ប្រភេទដល់រាជរដ្ឋាភិបាល៖ **១). កាតព្វកិច្ចហិរញ្ញវត្ថុផ្ទាល់** ដែលបច្ចុប្បន្ន រាជរដ្ឋាភិបាលពុំមាន; និង **២). កាតព្វកិច្ចបំណុលជាយថាហេតុ** ។ ក្នុងនោះ, ការទាមទារទូទាត់លើការធានារបស់រដ្ឋ ឬ ការរំលាយកិច្ចសន្យាមុនកាលកំណត់ អាចបង្កើតជា កាតព្វកិច្ចបំណុលជាយថាហេតុ ដែលអាចបង្កជាសម្ពាធដល់ស្ថិរភាពហិរញ្ញវត្ថុសាធារណៈ ។ កាតព្វកិច្ចនេះក៏អាចកើតមានឡើង ក្នុងលក្ខខណ្ឌការអនុវត្តកិច្ចសន្យារបស់ដៃគូមានភាពរាំងស្ទះដោយសារកត្តាណាមួយ រួមមាន សកម្មភាពរបស់រាជរដ្ឋាភិបាល, ការផ្លាស់ប្តូរច្បាប់ និងហានិភ័យប្រធានសក្តិ, ជាពិសេស ប្រធានសក្តិខាងនយោបាយជាដើម ។

គិតត្រឹមឆ្នាំចុងឆ្នាំ ២០២៥, គម្រោង PPP មានចំនួនប្រមាណ ៦៣ គម្រោង និងទុនវិនិយោគសរុបប្រមាណ ១៨ ៥០៧ លានដុល្លារអាមេរិក ក្នុងរង្វង់ ៣៧% នៃ ផ.ស.ស. ។ ទន្ទឹមនេះ, គម្រោង PPP ចំនួន ១៩ ស្ថិតក្នុងដំណាក់កាលសិក្សា និងវាយតម្លៃ ដែលស្ថិតក្នុងវិស័យដឹកជញ្ជូន, ភស្តុភារកម្ម, សេវាសាធារណៈ, ថាមពល, អាកាសចរណ៍, ការគ្រប់គ្រងសំណល់, ទេសចរណ៍ និងប្រព័ន្ធធារាសាស្ត្រ ជាដើម ដែលសុទ្ធសឹងជាវិស័យអាទិភាព ។ ក្នុងឆ្នាំ ២០២៦ និង ២០២៧, កាតព្វកិច្ចបំណុលជាយថាហេតុសរុបដែលចេញពីគម្រោង PPP ត្រូវបានព្យាករថាមានចំនួន ៣ ៤៤៨ លានដុល្លារអាមេរិក (៦,៤% នៃ ផ.ស.ស.) និង ៤ ១០៤ លានដុល្លារអាមេរិក (៧,១% នៃ ផ.ស.ស.) រៀងគ្នា ដែលមួយផ្នែកធំកើតចេញពីគម្រោងក្នុងវិស័យថាមពល, វិស័យដឹកជញ្ជូន, និង វិស័យអាកាសចរណ៍ ។ ទោះជាយ៉ាងនេះក្តី, លទ្ធភាពដែលអាចកើតឡើងនៃកាតព្វកិច្ចបំណុលជាយថាហេតុមានកម្រិតទាប និងមានទំហំកម្មវិបាកក្នុងកម្រិតទាប និងអាចគ្រប់គ្រងបាន ។ ជាក់ស្តែង, កន្លងមក ការផ្តល់ការធានាលើការទូទាត់ពីរាជរដ្ឋាភិបាលចំពោះគម្រោងក្នុងវិស័យថាមពល ពុំដែលកើតមាននោះទេ ។ ទន្ទឹមនេះ, ការប្រែប្រួលនៃនយោបាយអន្តរជាតិ, ទំនាស់ព្រំដែនកម្ពុជា-ថៃ និងហានិភ័យនៃប្រធានសក្តិ បង្កជាផលប៉ះពាល់ដោយប្រយោលប៉ុណ្ណោះ ដល់ការរៀបចំអភិវឌ្ឍ និងអនុវត្តគម្រោង PPP ។

ជាមួយគ្នានេះ, ក្រោមអធិការកិច្ចរបស់អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រាល់គម្រោង PPP ដែលបានអនុម័តបន្ទាប់ពីច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន ចូលជាធរមាន គឺតម្រូវឱ្យមានការសិក្សាសមិទ្ធិលទ្ធភាពរបស់គម្រោង ដែលជាការសិក្សាលើគ្រប់ទិដ្ឋភាព រួមទាំងទិដ្ឋភាពហិរញ្ញវត្ថុ, ទំហំនៃការគាំទ្រពីរាជរដ្ឋាភិបាល, ព្រមទាំងកំណត់នូវហានិភ័យរបស់គម្រោង និងយន្តការបញ្ចៀសហានិភ័យទាំងនោះ មុននឹងសម្រេចអនុវត្តក្រោមយន្តការ PPP ។ ស្របគ្នានេះ, បន្ទាប់ពីកិច្ចសន្យា PPP ត្រូវបានចុះហត្ថលេខា គណៈកម្មាធិការសម្រាប់គ្រប់គ្រងកិច្ចសន្យា PPP នឹងត្រូវបង្កើតឡើង ដែលមានសមាសភាពកម្រិតថ្នាក់ដឹកនាំពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នសាមី ដើម្បីដឹកនាំ និងត្រួតពិនិត្យការអនុវត្តរួម នៃគម្រោង សំដៅធានាអនុលោមភាព និងការបំពេញកាតព្វកិច្ចរបស់គូភាគីនៃកិច្ចសន្យា ។

លើសពីនេះ, ដើម្បីត្រៀមលក្ខណៈកាត់បន្ថយការប៉ះទង្គិចពីហានិភ័យបំណុលយថាហេតុ, រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការគោលនយោបាយមួយចំនួន រួមមានៈ **១).** ការសិក្សាពិនិត្យលទ្ធភាពក្នុងការរៀបចំបង្កើត "ថវិកាបម្រុងសម្រាប់ដោះស្រាយបំណុលជាយថាហេតុ (Contingent Liability Reserve Fund) ដែលកើតចេញពីគម្រោង PPP" ដូចមានចែងក្នុងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់គម្រោង PPP, **២).** ការកំណត់ពិតាននៃការធានាទូទាត់សរុបប្រចាំឆ្នាំចំពោះគម្រោងថ្មី មិនលើសពី ១០% នៃចំណូលថវិកាជាតិនាឆ្នាំកន្លងទៅ, **៣).** ការបន្តមិនផ្តល់ការធានាឥណទាន (Credit/Loan Guarantee) ដោយផ្ទាល់ពីរដ្ឋចំពោះវិស័យឯកជន, **៤).** ការប្រើប្រាស់យន្តការស្ថាប័នសម្រាប់ការគ្រប់គ្រងគម្រោង ដើម្បីទប់ស្កាត់ និងបញ្ចៀសកម្មវិបាក ដែលអាចកើតមានឡើងពីគម្រោង រួមមាន ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន, នីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោង PPP, ក្រុមការងារបច្ចេកទេសអន្តរក្រសួងស្ថាប័ន ដើម្បីពិនិត្យ និងវាយតម្លៃលើកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈនិងបំណុលជាយថាហេតុ ដែលកើតចេញពីគម្រោង PPP, និង **៥).** ការតាមដានជាប្រចាំ និងការពង្រឹងការអនុវត្តច្បាប់ និងយន្តការពាក់ព័ន្ធនានា ។

## ឃ. ហានិភ័យបំណុលរបស់រដ្ឋាភិបាល

**ហានិភ័យបំណុលរបស់រដ្ឋាភិបាល** មានលទ្ធភាពកើតឡើងក្នុងកម្រិតមធ្យម ដោយសារកត្តាសំខាន់ៗមួយចំនួន ដូចជា ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល, ការកើនសម្ពាធអតិផរណា, ការបន្តរក្សាកម្រិតអត្រាការប្រាក់ខ្ពស់នៅក្នុងទីផ្សារ រួមទាំងវិបត្តិអាកាសធាតុ, និងការកែសម្រួលគោលនយោបាយក្នុងការផ្តល់ហិរញ្ញប្បទានដល់កម្ពុជារបស់ស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍមួយចំនួន ជាដើម, ដែលអាចបង្កើនបន្ទុកបំណុល និងបន្ទុកចំណាយរបស់រាជរដ្ឋាភិបាល ហើយបង្កជាសម្ពាធដល់ថវិកាជាតិ ។ ជាមួយគ្នានេះ, ការត្រៀមខ្លួនចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច (LDC) របស់កម្ពុជា អាចនឹងនាំឱ្យបាត់បង់ថែមទៀតនូវប្រភពហិរញ្ញប្បទានដែលមានកម្រិតសម្បទានខ្ពស់ ព្រមទាំងការធ្លាក់ចុះនៃជំនួយហិរញ្ញប្បទានឥតសំណង ដែលអាចធ្វើឱ្យឱនភាពថវិកាមានការរីកធំ ។

ទោះជាយ៉ាងនេះក្តី, ហានិភ័យបំណុលនេះមានទំហំកម្មវិបាកក្នុងកម្រិតទាប នៅឡើយ និងនៅតែបន្តរក្សាបាននូវចីរភាព សម្រាប់រយៈពេលខ្លី និងមធ្យមខាងមុខ ផ្អែកតាមការពិនិត្យលើសូចនាករគន្លឹះមួយចំនួន ។ ជាក់ស្តែងក្នុងឆ្នាំ ២០២៥ (ប៉ាន់ស្មាន), ស្ថានភាពបំណុលសាធារណៈ ផ្អែកតាមសូចនាករបំណុលគន្លឹះៗចំនួន ៥ នៃការវិភាគចីរភាពចំណុល (Debt Sustainability Analysis – DSA) នៅតែបន្តបង្ហាញចីរភាព និងស្ថិតក្រោមអនុបាតគោលដែលមានកំណត់ ។

ជាមួយគ្នានេះ, សន្និធិបំណុលសាធារណៈសរុប មានទំហំប្រមាណ ១៣ ០៥៤ លានដុល្លារអាមេរិក ឬ ១៨,៣% នៃ ផ.ស.ស. (តម្លៃបច្ចុប្បន្ន) ក្នុងនោះ សន្និធិបំណុលសាធារណៈក្រៅប្រទេសប្រមាណ ១២ ៨០៧ លានដុល្លារអាមេរិក និងសន្និធិបំណុលសាធារណៈក្នុងប្រទេសប្រមាណ ២៤៧ លានដុល្លារអាមេរិក ក្នុងវិស័យសរុបចំនួន ១០ ដោយក្នុងនោះមានវិស័យធំៗចំនួន ៥ គឺ វិស័យដឹកជញ្ជូន, វិស័យអាទិភាពផ្សេងៗ, វិស័យធារាសាស្ត្រ, វិស័យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ, និងវិស័យថាមពល ។ សម្រាប់ឆ្នាំ ២០២៦-២០២៨, សន្និធិបំណុលសាធារណៈ ជាមធ្យម មានទំហំប្រមាណ ១៩,២% នៃផ.ស.ស. (តម្លៃបច្ចុប្បន្ន) ធៀបនឹងអនុបាតគោល ៥៥% នៃ ផ.ស.ស. ពោលគឺ កម្ពុជានៅមានលម្ហសារពើពន្ធធំសម្រាប់ការខ្ចីបន្ថែម ។ គិតត្រឹមដំណាច់ឆ្នាំ២០២៥ នេះ, មធ្យមទម្ងន់អត្រាការប្រាក់នៃសន្និធិបំណុលសាធារណៈសរុប មានត្រឹមកម្រិត ១,២០% ក្នុងមួយឆ្នាំប៉ុណ្ណោះ ហើយរយៈពេលមធ្យមដល់ឥណប្រតិទាននៃចង្កោមបំណុលក៏នៅមានរយៈពេលវែង (ជាមធ្យម ១០ ឆ្នាំ) រីឯ

សមាសភាគបំណុល ប្រមាណ ៩៨,៧៥% នៃបំណុលសាធារណៈសរុប ក៏ជាប្រភេទការប្រាក់ថេរ ។ ទន្ទឹមនេះ, ការឱ្យប្រាក់គេខ្ចីរបស់រាជរដ្ឋាភិបាល ក៏ពុំទទួលផលប៉ះពាល់ធ្ងន់ធ្ងរដែរ ដោយឥណទានក្នុងវិស័យធំៗ ចំនួន ៥ ដែលទទួលបានកម្ចីពីរាជរដ្ឋាភិបាល, រួមមាន វិស័យថាមពល, វិស័យទឹកស្អាត, វិស័យហិរញ្ញវត្ថុ និងធនាគារ, វិស័យដឹកជញ្ជូន និងវិស័យទូរគមនាគមន៍ ដែលមានទំហំទឹកប្រាក់សរុបប្រមាណ ២ ៩៨០ លានដុល្លារអាមេរិក (ប៉ាន់ស្មានក្នុងឆ្នាំ ២០២៥) ដែលនៅតែបន្តមានលទ្ធភាព និងបានទូទាត់សេវាបំណុលតាមកាលកំណត់ ។ ទន្ទឹមនេះ, បើទោះបីការផ្តល់ហិរញ្ញប្បទានឥតសំណងដល់កម្ពុជា រំពឹងថាកាន់តែថមថយពិតមែន (ឆ្នាំ ២០២៤ ថយចុះប្រមាណ ៨ ពិន្ទុភាគរយ ឬ ប្រមាណ ១២៣ ប៊ីលានរៀល ធៀបឆ្នាំ ២០២៣), ក៏ប៉ុន្តែ កម្ពុជាពុំបានពឹងផ្អែកខ្លាំងលើប្រភពហិរញ្ញប្បទាននេះឡើយ ។

ជាមួយគ្នានេះ, តាមរយៈការអនុវត្តវិធានការជាយុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលបានដាក់ចេញក្នុង **យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤-២០២៨** និងការអនុវត្តយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង/កម្មវិធីហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ និងមូលនិធិទ្រទ្រង់ថវិកា, ក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ កម្ពុជានៅតែអាចបន្តកៀរគរហិរញ្ញប្បទាន និងធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានបន្ថែម ដែលមានកម្រិតសម្បទាន និងលក្ខខណ្ឌអនុគ្រោះ រួមទាំងហិរញ្ញប្បទានឥតសំណងសម្រាប់វិនិយោគសាធារណៈ តាមរយៈការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងការធានាទុកចិត្តបាននូវការអនុវត្តគម្រោង/កម្មវិធី ។

## ង. ហានិភ័យពីសហគ្រាសសាធារណៈ

**សហគ្រាសសាធារណៈ (ស.ស.)** គឺសំដៅដល់សហគ្រាសដែលមានដើមទុន និងភាគហ៊ុនទាំងអស់ ១០០% ឬ ភាគច្រើនជារបស់រដ្ឋចាប់ពី ៥១% ឡើងទៅ និងបង្កើតឡើងក្នុងគោលបំណងស្វែងរកប្រាក់ចំណេញផង និងចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលផង រួមចំណែកធ្វើឱ្យមានកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ គិតត្រឹមឆ្នាំ ២០២៥ នេះ **ស.ស.** នៅកម្ពុជាមានចំនួន ២៧, ក្នុងចំណោមនោះមានសហគ្រាសចំនួន ២២ ដែលមានដើមទុនរដ្ឋ ១០០%, ចំនួន ២ ជាក្រុមហ៊ុនចម្រុះរដ្ឋ, និងសហគ្រាសចំនួន ៣ ទៀត រួមមាន រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ, កំពង់ផែស្វយ័តក្រុងព្រះសីហនុ និងកំពង់ផែស្វយ័តភ្នំពេញ ត្រូវបានអនុញ្ញាតឱ្យធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដើម្បីប្រមូលធនធានសម្រាប់បំពេញសេចក្តីត្រូវការវិនិយោគរបស់ខ្លួន ។

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទ ២០២៤ គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ, **ស.ស.** ចំនួន ២៦ (ដោយពុំគិតបញ្ចូលសហគ្រាសហ្វូណនតេជោ ដែលបង្កើតថ្មីនៅដើមឆ្នាំ២០២៥) មានទ្រព្យសកម្មសរុបចំនួនប្រមាណ ៣០ ០៣៥ ប៊ីលានរៀល ក្នុងនោះដើមទុនផ្ទាល់របស់ **ស.ស.** មានចំនួនសរុបប្រមាណ ១២ ៨១៧ ប៊ីលានរៀល និងបំណុលអាជីវកម្ម និងការខ្ចីសម្រាប់វិនិយោគមានចំនួនសរុបប្រមាណ ១៧ ២១៧ ប៊ីលានរៀល ។

ផ្អែកតាមលទ្ធផលអាជីវកម្មនៃ **ស.ស.** ក្នុងឆ្នាំ ២០២៤, ក្នុងចំណោមសហគ្រាសទាំង ២៦ គឺមានសហគ្រាសចំនួន ២០ ដែលមានលទ្ធផលហិរញ្ញវត្ថុវិជ្ជមាន (ចំណេញ) មុនបង់ពន្ធ ។ ក្នុងនោះ, មានសហគ្រាសធំៗ ចំនួន ៨ ដែលមានលទ្ធផលល្អប្រសើរជាកត់សម្គាល់ មានចំណេញមុនបង់ពន្ធសរុប ក្នុងទំហំប្រមាណ ១ ២៣៣ ប៊ីលានរៀល រួមមានៈ អគ្គិសនីកម្ពុជា, កំពង់ផែស្វយ័តក្រុងព្រះសីហនុ, កំពង់ផែស្វយ័តក្រុងភ្នំពេញ, រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ, សាជីវកម្មធានាឥណទានកម្ពុជា, ធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា,

ទូរគមនាគមន៍កម្ពុជា, និងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ជាដើម ។ ចំណែកសហគ្រាស ចំនួន ៦ ទៀត ដែលមានលទ្ធផលហិរញ្ញវត្ថុអវិជ្ជមាន (ខាត) គឺមានទំហំតូចប៉ុណ្ណោះ (សរុបប្រមាណ ២០ ប៊ីលានរៀល) ។

ជាមួយគ្នានេះ, ហានិភ័យពី **ស.ស.** អាចកើតមានឡើងក្នុងកម្រិតមធ្យម ជាមួយនឹងភាពមិនច្បាស់លាស់នៃលក្ខខណ្ឌសេដ្ឋកិច្ច និងនយោបាយអន្តរជាតិ និងក្នុងស្រុក ដែលអាចធ្វើឱ្យមានប៉ះពាល់ដល់ស្ថានភាពហិរញ្ញវត្ថុ ក៏ដូចជាលទ្ធភាពសងរបស់ឥណាយិក មករាជរដ្ឋាភិបាលវិញ ។ យ៉ាងណាមិញ, ទំហំ នៃកម្មវិបាកពីហានិភ័យនេះស្ថិតក្នុងកម្រិតទាបនៅឡើយ ដោយ **ស.ស.** មានស្វ័យភាពលើហិរញ្ញវត្ថុ, ការងារ និងការគ្រប់គ្រងរបស់ខ្លួន ខណៈបច្ចុប្បន្នពុំទាន់មាន **ស.ស.** ណាមួយទទួលលទ្ធផលខូចខាតធ្ងន់ធ្ងរនៅឡើយ ។ ជាក់ស្តែង, អគ្គិសនីកម្ពុជា (EDC) ដែលជា **ស.ស.** ធំមួយក្នុងចំណោម **ស.ស.** ទាំង ២៦, នៅតែបន្តបង្ហាញនិន្នាការរឹងមាំ និងមានចីរភាពក្នុងប្រតិបត្តិការអាជីវកម្ម ។ ជាមួយគ្នានេះ, បំណុលរបស់ **ស.ស.** គឺស្ថិតក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផងដែរ ពោលគឺ **ស.ស.** ពុំមានសិទ្ធិស្នើសុំខ្ចីដោយផ្ទាល់ពីដៃគូអភិវឌ្ឍន៍ នោះទេ ។ ជាមួយគ្នានេះ, ដើម្បីជាវិធានការត្រៀមខ្លួនទៅនឹងហានិភ័យ និងសម្រាប់ប្រើប្រាស់ក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល, **ស.ស.** បានត្រៀមកញ្ចប់ថវិកាបម្រុងតាមវិស័យសំខាន់ៗ ដូចជាវិស័យថាមពល, វិស័យទឹកស្អាត, វិស័យហិរញ្ញវត្ថុ, និងវិស័យសាធារណៈផ្សេងៗ សម្រាប់តម្រូវការប្រើប្រាស់ក្នុងគ្រាមានវិបត្តិ និងគ្រប់គ្រងហានិភ័យ តាមរយៈការអនុវត្តនូវ **«យុទ្ធសាស្ត្រស្តីពីការកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ ឆ្នាំ២០២៥-២០៣០»** ដែលបានអនុម័ត និងត្រៀមក្នុងការផ្សព្វផ្សាយអនុវត្ត នឹងដើរតួនាទីសំខាន់ក្នុងការពង្រឹងលទ្ធផលរបស់ **ស.ស.** ។

## ច. ហានិភ័យពីការវិនិយោគសាធារណៈ

**ហានិភ័យពីការវិនិយោគសាធារណៈ** អាចកើតមានឡើងទាំងចំពោះ **គម្រោងវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស** និង **ដោយថវិកាថ្នាក់ជាតិ** ។ ក្នុងនោះ, **ហានិភ័យពីគម្រោងវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស** អាចមានកម្មវិបាកដល់ហិរញ្ញវត្ថុសាធារណៈ ក្នុងករណីមានចន្លោះប្រហោងក្នុងការគ្រប់គ្រង និងអនុវត្តគម្រោង រួមមាន ការប៉ាន់ប្រមាណខ្ពស់ពេក (Overestimation) ឬ ការប៉ាន់ប្រមាណទាបពេក (Underestimation) លើការគ្រោងចំណាយ និងពេលវេលាអនុវត្តគម្រោង, ការពន្យារពេលអនុវត្តគម្រោងដោយសារកត្តាសត្យានុម័ត ឬការប្រែប្រួលនៃស្ថានភាពទាំងក្នុង និងក្រៅប្រទេស ឬការផ្លាស់ប្តូរវិសាលភាព និង/ឬ ប្លង់រចនាលម្អិតនៃគម្រោង, សមត្ថភាពគ្រប់គ្រង និងបច្ចេកទេស ក្នុងការគ្រប់គ្រងគម្រោងមានកម្រិត ។

ក្នុងឆ្នាំ ២០២៦, គម្រោងវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងបន្ថែម ក្នុងទំហំប្រមាណ ៣ ៥៩៧ លានដុល្លារអាម៉េរិក ដែលក្នុងនោះមានវិស័យធំៗ ៣ រួមមាន៖ វិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងដឹកជញ្ជូន, វិស័យថាមពល, និងវិស័យធារាសាស្ត្រ ។ ជាមួយគ្នានេះ, គិតត្រឹមឆ្នាំ ២០២៥, គម្រោងវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស មានទឹកប្រាក់សេសសល់ (Undisbursed amount) សរុបប្រមាណ ៥ ៨៩៩ លានដុល្លារអាម៉េរិក ដែលស្ថិតក្នុងវិស័យធំៗ ៥ រួមមាន៖ វិស័យដឹកជញ្ជូន ប្រមាណ ១ ៣៧៩ លានដុល្លារអាម៉េរិក, វិស័យទឹកស្អាត ប្រមាណ ៧៧៦ លានដុល្លារអាម៉េរិក, វិស័យថាមពល ប្រមាណ ៧២០ លានដុល្លារអាម៉េរិក, វិស័យធារាសាស្ត្រ ប្រមាណ ៥៧៨ លានដុល្លារអាម៉េរិក និងវិស័យហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត ប្រមាណ ៩២២ លានដុល្លារអាម៉េរិក ព្រមទាំងវិស័យផ្សេងទៀត ប្រមាណ ១ ៥២៤ លានដុល្លារអាម៉េរិក ។

ដូចគ្នាដែរ, **ហានិភ័យពីការវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ** អាចកើតមានឡើងដោយការខូចខាតទ្រព្យសម្បត្តិ ឬ ការពន្យារពេល ក្នុងការអនុវត្តគម្រោងវិនិយោគ ។ សម្រាប់បរិការណ៍កម្ពុជា, គម្រោងវិនិយោគដែលប្រើប្រាស់ថវិកាជាតិជំពូក ២១ (គម្រោងវិនិយោគផ្ទាល់) ភាគច្រើន មានលំនាំត្រឹមជាគម្រោងជួសជុល និងការស្តារឡើងវិញ ព្រមទាំងការលើកកម្ពស់កម្រិតគុណភាពហេដ្ឋារចនាសម្ព័ន្ធ ដែលបានវិនិយោគ ។ ជាមួយគ្នានេះ, ជាការអនុវត្តកន្លងមក, ការពន្យារពេល ការអនុវត្តគម្រោងគឺមានចំនួនតិចតួច ដែលកើតចេញពី ផលប៉ះពាល់នៃគ្រោះធម្មជាតិ ដូចជាជំនន់ទឹកភ្លៀង ឬភ្លៀងធ្លាក់ខ្លាំងក្នុងរដូវវស្សា ជាដើម ។

លើមូលដ្ឋាននេះ, ហានិភ័យពីវិនិយោគសាធារណៈជារួម ត្រូវបានវាយតម្លៃថា មានទំហំនៃកម្មវិបាកក្នុងកម្រិតទាប និងលទ្ធភាពកើតមានក្នុងកម្រិតមធ្យម ដែលអាចនឹងបង្កលក្ខណៈមិនសមស្របដល់ការអនុវត្តគម្រោង, ការអនុវត្តថវិកាមានកម្រិតទាបធៀបនឹងការគ្រោងទុក (Under-Execution), និងធ្វើឱ្យខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធ ។ ដើម្បីជៀសវាង និងកាត់បន្ថយកម្មវិបាកពីហានិភ័យនេះ, រាជរដ្ឋាភិបាលបានដាក់ចេញនូវ **យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ឆ្នាំ២០២៥-២០២៨** សំដៅធានាបាននូវការគ្រប់គ្រង ការបែងចែក និងប្រើប្រាស់ធនធានសាធារណៈប្រកបដោយសមធម៌ និងតម្លាភាព ។ លើសពីនេះ, រាជរដ្ឋាភិបាល ក៏បានរៀបចំ និង អនុវត្តវិធានការ មួយចំនួនដូចជា៖ ១). **វិធានការជៀសវាងហានិភ័យ** (Risk Avoidance) ដោយកំណត់ពិតាននៃការខ្ចី, សម្រិតសម្រាំងតែឥណទានសម្បទានដែលមានលក្ខខណ្ឌអនុគ្រោះ, ជ្រើសរើសគម្រោងដោយផ្អែកលើភាពចាំបាច់ និងអាទិភាពរបស់រាជរដ្ឋាភិបាល, និងធានាបានភាពត្រៀមខ្លួនរួចរាល់ក្នុងដំណាក់កាលរៀបចំគម្រោង (Feasibility Study, CBA, DSA), ២). **វិធានការកាត់បន្ថយហានិភ័យ** (Risk Mitigation) ដោយពង្រឹងការគ្រប់គ្រងគម្រោង និងសមត្ថភាពមន្ត្រីអនុវត្តគម្រោង, កែលម្អប្រព័ន្ធលទ្ធកម្មឱ្យមានតម្លាភាព និងភាពប្រកួតប្រជែង, និងរៀបចំថវិកាបដិភាគ (Counterpart Fund) ជាមុន, ៣). **វិធានការផ្ទេរហានិភ័យ** (Risk Transfer) ដោយផ្ទេរនូវហានិភ័យគម្រោង តាមរយៈគម្រោងវិនិយោគសាធារណៈជាមួយវិស័យឯកជន តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន, ការធានារ៉ាប់រងសំណង់ និងធានាកិច្ចសន្យា, និងប្រើលក្ខខណ្ឌកិច្ចសន្យាស្តង់ដារ (FIDIC), ៤). **វិធានការតាមដាន និងគ្រប់គ្រងហានិភ័យ** (Risk Monitoring & Control) ដោយតាមដាន និងវាយតម្លៃគម្រោងជាប្រចាំ (M&E), អភិវឌ្ឍ និងប្រើប្រព័ន្ធព័ត៌មាន និងហិរញ្ញវត្ថុគម្រោង, និង ពិនិត្យធ្វើសវនកម្មផ្ទៃក្នុង និងក្រៅ, និង ៥). **វិធានការផ្នែកសង្គម និងបរិស្ថាន** ដោយអនុវត្ត ESIA / EIA តាមស្តង់ដារអន្តរជាតិ, រៀបចំផែនការសំណង់ និងផែនការគ្រប់គ្រងបរិស្ថាន, និងបង្កើនការចូលរួមពីសហគមន៍ និងភាគីពាក់ព័ន្ធ ។

## ធ. ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ, សេដ្ឋកិច្ចកម្ពុជាបានបន្តទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ។ ជាក់ស្តែង, វិស័យសេដ្ឋកិច្ចកម្ពុជាដែលងាយស្រួលរងគ្រោះជាងគេ គឺ វិស័យកសិកម្ម ដែលក្នុងនោះ, ការកើនកម្តៅ និងលទ្ធភាពដែលអាចឈានដល់គ្រោះរាំងស្ងួត នឹងធ្វើឱ្យប៉ះពាល់ដល់ការបង្កបង្កើនផលពោលគឺការដាំដុះក្នុងរដូវវស្សា និងប៉ះពាល់ដល់កម្រិតទឹកទន្លេ និងបឹង ដែលជារួមបន្ទច់បង្អាក់ដល់ផលិតកម្មផលចាប់ទឹកសាបផងដែរ ។ បន្ថែមពីនេះ, ការប្រែប្រួលអាកាសធាតុក៏អាចនឹងដាក់សម្ពាធបន្ថែមមកលើហិរញ្ញវត្ថុសាធារណៈ តាមរយៈតម្រូវការវិនិយោគសាធារណៈលើសការគ្រោងទុក ដើម្បីប្រើប្រាស់ក្នុងករណីបន្ទាន់ ក៏ដូចជាការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមានតម្រូវការក្នុងការថែទាំ និងផ្លាស់ប្តូរថ្មី ។ ទន្ទឹមនេះ, បញ្ហាប្រឈម

នេះជាបញ្ហាប្រឈមកម្រិតសកល ដែលតម្រូវឱ្យមានការដោះស្រាយរួមគ្នា ក្នុងកម្រិតតំបន់ និង សកល ជាពិសេស ពីបណ្តាប្រទេសអភិវឌ្ឍន៍ ។

ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ អាចកើតមានឡើងក្នុងកម្រិតមធ្យម ខណៈជាទំហំនៃកម្មវិបាក ស្ថិតក្នុងកម្រិតទាបនៅឡើយ ដោយរាជរដ្ឋាភិបាលបានបន្តដាក់ចេញនូវវិធានការជាបន្តបន្ទាប់ តាមរយៈការរៀបចំដាក់ចេញនូវ **ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឆ្នាំ ២០២៤-២០៣៣** (CCCSP 2024-2033), ការបន្តពង្រឹងប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ ដឹកនាំដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ព្រមទាំងការបន្តតម្រង់ទិសចំណាយវិនិយោគសាធារណៈ ដល់ការកែលម្អហេដ្ឋារចនាសម្ព័ន្ធដែលមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការបន្តត្រៀមបម្រុងធនធានថវិកាជួសម្រាប់អន្តរាគមន៍គ្រោះធម្មជាតិ ផងដែរ ។

## ជ. ភាពជឿទុកចិត្តបាននៃក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ

ស្ថានភាពមិនប្រាកដប្រជាខ្ពស់នៃសេដ្ឋកិច្ច និងគោលនយោបាយជាតិ និងអន្តរជាតិ បានបន្តបង្កើតជាបញ្ហាប្រឈមដល់ការប៉ាន់ស្មានការប្រមូលចំណូល, លទ្ធផលនៃការប្រមូលចំណូលជាក់ស្តែង, និងការកើនឡើងនៃតម្រូវការចំណាយ ។ ស្របគ្នានេះ, រាជរដ្ឋាភិបាល បាន និងកំពុងដាក់ចេញនូវគោលនយោបាយទ្រទ្រង់ជាបន្តបន្ទាប់ រួមមាន ការកាត់បន្ថយអត្រា និងការអនុគ្រោះពន្ធ ដែលការណ៍ទាំងនេះ បង្កឱ្យការប្រមូលចំណូលអាចនឹងមិនសម្រេចបានដូចទៅតាមការគ្រោង ខណៈតម្រូវការចំណាយថ្មីៗបន្ថែមទៀត កើតមានឡើងដោយមិនអាចរំពឹងទុក ។ បន្ថែមលើនេះ, ភាពមានកម្រិតក្នុងការប្រមូលចងក្រងទិន្នន័យ, ទាំងគុណភាព, វិសាលភាព និងភាពទាន់ពេល, និងកត្តាសមត្ថភាពមន្ត្រីជំនាញ ក៏អាចចូលរួមបង្កឱ្យមានចន្លោះប្រហោងជាប្រព័ន្ធក្នុងការវិភាគ និងព្យាករក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ផងដែរ ។ ជារួម, ហានិភ័យនេះមានផលជះក្នុងកម្រិតមធ្យមដល់ស្ថិរភាពហិរញ្ញវត្ថុសាធារណៈ និងមានលទ្ធភាពកើតក្នុងកម្រិតមធ្យម ។ ដើម្បីអាចកាត់បន្ថយទាំងកម្រិតកម្មវិបាក និងភាពអាចកើតឡើងនៃហានិភ័យនេះ, រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើវិធានការមួយចំនួនរួមមាន៖ **១**). ការបន្តតាមដានប្រកបដោយភាពបុរេសកម្មខ្ពស់ លើការប្រែប្រួលនៃលក្ខខណ្ឌសេដ្ឋកិច្ច និងសង្គម; **២**). ការអភិវឌ្ឍធនធានមនុស្ស សំដៅបង្កើនភាពទុកចិត្តបានក្នុងការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ; និង **៣**). ការពង្រឹងតួនាទីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាស្ថាប័នត្រួតពិនិត្យកណ្តាល (Central Oversight Body) ដើម្បីជួយសម្រួលដល់ការប្រមូល, ត្រួតពិនិត្យ និងគ្រប់គ្រងទិន្នន័យ ទន្ទឹមនឹងការប្រមូលផ្តុំជាតុចូលអន្តរកម្មពីភាគីពាក់ព័ន្ធ ដើម្បីពង្រឹងភាពធន់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

# ៦

# សេចក្តីសន្និដ្ឋាន

**«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៧-២០២៩»** ឬ **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩** ត្រូវបានរៀបចំឡើងយ៉ាងគត់មត់ អនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង **យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា** ។ **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩** ត្រូវបានរៀបចំក្នុងគោលបំណងរួមចំនួន ៣ គឺ ៖ **១)**. ជំរុញប្រសិទ្ធភាព និងតម្លាភាពថវិកា, ទាំងកម្រិតវិភាជន៍ និងប្រតិបត្តិការ, សំដៅធានាចីរភាពហិរញ្ញវត្ថុសាធារណៈ, **២)**. ពង្រឹងភាពធន់សង្គម-សេដ្ឋកិច្ច ដែលមានលទ្ធភាពឆ្លើយតបបានរហ័សទៅនឹងវិបត្តិ នាពេលអនាគត ក្នុងបរិការណ៍ដែលមានភាពមិនប្រាកដប្រជាខ្ពស់, និង **៣)**. ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ដើម្បីជំរុញសម្ទុះនៃការអភិវឌ្ឍជាតិ ប្រកបដោយ ចីរភាព និងបរិយាប័ន្ន និងសំដៅសម្រេចឱ្យបាននូវចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា ។

ផ្អែកលើស្ថានភាពនាពេលថ្មីៗនេះ, សេដ្ឋកិច្ចកម្ពុជា ឆ្នាំ ២០២៦ ត្រូវបានវាយតម្លៃនឹងសម្រេចបានកំណើន ក្នុងអត្រា ៤,២% ប៉ុណ្ណោះ ទាបជាងការព្យាករ ៥% ដែលបានគ្រោងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦ ។ សម្រាប់ឆ្នាំ ២០២៧, សេដ្ឋកិច្ចកម្ពុជា ត្រូវបានព្យាករថានឹងងើបឡើងវិញសន្សឹមៗ ជាមួយអត្រាកំណើន ៥,០% ខណៈដែលក្នុងរយៈពេលមធ្យមខាងមុខ (២០២៨-២០២៩) កំណើននឹងបន្តនិន្នាការកើនឡើង ក្នុងរង្វង់ ៥,៥% ។ ចំពោះអត្រាអតិផរណា ក្នុងរយៈពេលខាងមុខ (២០២៧-២០២៩) ត្រូវបានព្យាករថានឹងស្ថិតក្នុង រង្វង់ប្រមាណ ២,៥% ស្របគ្នាទៅនឹងនិន្នាការសេដ្ឋកិច្ច ខណៈដែលថ្លៃទំនិញអន្តរជាតិក៏រំពឹងថានឹងបន្តរក្សាបានប្រក្រតីភាព រីឯអត្រាប្តូរប្រាក់ផ្លូវការ រំពឹងថានឹងរក្សាបានក្នុងរង្វង់ ៤ ០៥០ រៀល/ដុល្លារអាមេរិក ក្នុងកម្រិតអាចគ្រប់គ្រងបាន ។ ទោះជាយ៉ាងនេះក្តី, ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជា កំពុងត្រូវបានបន្តហ៊ុមព័ទ្ធដោយហានិភ័យ និង ភាពមិនប្រាកដប្រជាខ្ពស់ ទាំងខាងក្នុងប្រទេស និងក្រៅប្រទេស ដែលមិនក្រោមចំណុះការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ជាអាទិ៍ វិបត្តិថាមពលសកល, ភាពតានតឹងភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ច, និងការផ្លាស់ប្តូរនៃរបបពាណិជ្ជកម្មសកល, ភាពមិនច្បាស់លាស់នៃស្ថានភាពព្រំដែន ព្រមទាំងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និង គ្រោះធម្មជាតិ ។

ក្នុងបរិការណ៍នេះ, គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់រយៈពេលមធ្យមខាងមុខ ត្រូវបានរៀបចំឡើងដោយប្រកាន់យកនូវការបន្តអនុវត្ត **«ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈអព្យាក្រឹត»** ដើម្បីធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម ដោយផ្តោតជាសំខាន់ លើការបន្តរក្សាស្ថិរភាពសេដ្ឋកិច្ច និងតុល្យភាពថវិកា ខណៈថែរក្សាអធិបតេយ្យជាតិ និងបូរណភាពទឹកដីរបស់ប្រទេសកម្ពុជា ។ **ជាមួយ**

**នឹងការគិតគូរនេះ, ការប្រមូលចំណូលចរន្តត្រូវបានគ្រោងថានឹងមានកំណើនជាមធ្យម ក្នុងរង្វង់ ៧,៤% សម្រាប់ឆ្នាំ ២០២៧-២០២៩ ដែលក្នុងនោះ សម្រាប់ឆ្នាំ ២០២៧ មានកំណើន ៧,៥%, សមមូលនឹង ១៤,៧៦% នៃ ផ.ស.ស. ។ ចំណាយសាធារណៈសរុប ត្រូវបានរំពឹងថានឹងមានកំណើនជាមធ្យម ៣,២% ក្នុងមួយឆ្នាំ ដែលក្នុងនោះ សម្រាប់ឆ្នាំ ២០២៧ ថមថយប្រមាណ -១,៨% ពីច្បាប់ថវិកាឆ្នាំ ២០២៦ សមមូលនឹង ១៧,០៣% នៃ ផ.ស.ស. ។ ឱនភាពថវិកានឹងស្ថិតក្នុងរង្វង់ -១,៥៣% នៃ ផ.ស.ស. ជាមធ្យម សម្រាប់ឆ្នាំ ២០២៧-២០២៩ ដែលក្នុងនោះ សម្រាប់ឆ្នាំ ២០២៧ មានទំហំប្រមាណ -១,៧៩% នៃ ផ.ស.ស. ។** ជាលទ្ធផល, ស្ថានភាពហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ត្រូវបានវាយតម្លៃថា នឹងនៅតែបន្តមានភាពរឹងមាំ និងមានចីរភាព ដោយអនុលោមបានទៅតាមវិធានហិរញ្ញវត្ថុសាធារណៈ ។ ក្របខ័ណ្ឌនេះ ក៏នឹងក្លាយជាមូលដ្ឋានសម្រាប់ការរៀបចំនូវ «**ក្របខ័ណ្ឌថវិការយៈពេលមធ្យម ២០២៧-២០២៩**» និង «**សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៧**» ។

ជាការសន្និដ្ឋានរួម, ស្ថិតក្នុងបរិការណ៍មិនច្បាស់លាស់ទាំងអស់នេះ, រាជរដ្ឋាភិបាល នឹងបន្តខិតខំពង្រីក និងបន្តពង្រឹងមូលដ្ឋានខាងក្នុងឱ្យកាន់តែមានភាពប្រកួតប្រជែង, បង្កើនពិពិធកម្ម, និងពង្រឹងភាពធន់ នៃសង្គម-សេដ្ឋកិច្ច ពិសេសបន្តធ្វើអាទិភាវូបនីយកម្មចំណាយ ដោយបន្តចាត់ទុកការការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី ជាអាទិភាពសំខាន់បំផុត ព្រមទាំងតម្រង់ទិសដៅគោលនយោបាយផ្តោតចម្បងលើការរក្សាលំនឹងជីវភាពប្រជាជន, ជំរុញជវភាពនៃកំណើនសេដ្ឋកិច្ច និងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រឈមនឹងហានិភ័យដែលនឹងកើតឡើងក្នុងពេលខាងមុខ ជាយថាហេតុ ។ រាជរដ្ឋាភិបាល នឹងបន្តតាមដានការវិវត្តនៃស្ថានការណ៍ និងវាយតម្លៃឡើងវិញពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ នៅពាក់កណ្តាលឆ្នាំ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំ **សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០២៧** ។ ក្នុងស្ថានភាពដែលមានការវិវត្តប្រសើរ, រាជរដ្ឋាភិបាលនឹងបន្តប្រើប្រាស់ក្របខ័ណ្ឌនេះ ។ ក្នុងករណីស្ថានការណ៍កាន់តែអាក្រក់, រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពកែសម្រួលក្របខ័ណ្ឌនេះ តាមស្ថានភាពជាក់ស្តែង ក្នុងន័យធានាឱ្យបាននូវភាពជឿទុកចិត្តបាននៃថវិកា និងឆ្លុះបញ្ចាំងពីស្ថានភាពពិត ។ ទន្ទឹមនឹងនេះ, រាជរដ្ឋាភិបាល នឹងបន្តត្រៀមខ្លួន ប្រកបដោយស្មារតីប្រុងប្រយ័ត្ន, បុរេសកម្ម និងបត់បែនខ្ពស់ ក្នុងការរៀបចំ និង ដាក់ចេញនូវគោលនយោបាយ និងវិធានការអន្តរាគមន៍សំដៅឆ្លើយតប និងសម្របតាមការវិវត្តនូវសភាពការណ៍ ឱ្យបានទាន់ពេល និងកាន់តែមានប្រសិទ្ធភាពខ្ពស់ ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ក៖ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២៣-២០២៩

| សូចនាករ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ប | ២០២៧ព្យ | ២០២៨ព្យ | ២០២៩ព្យ |
|---|---|---|---|---|---|---|---|
| **ផ.ស.ស. ថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល)** | **174,027** | **188,766** | **205,757** | **219,939** | **235,883** | **253,501** | **273,312** |
| ផ.ស.ស. សម្រាប់ម្នាក់ (ដុល្លារអាមេរិក) | 2,477 | 2,675 | 2,918 | 3,064 | 3,234 | 3,423 | 3,638 |
| **កំណើន ផ.ស.ស. ពិត (%)** | **5.0%** | **6.0%** | **5.3%** | **4.2%** | **5.0%** | **5.3%** | **5.6%** |
| អត្រាបរិត្តិផរណា ផ.ស.ស. (កំណើនប្រចាំឆ្នាំ) | 2.3% | 2.3% | 3.5% | 2.5% | 2.8% | 3.3% | 3.1% |
| **អត្រាអតិផរណា (កំណើនជាមធ្យមប្រចាំឆ្នាំ)** | **2.1%** | **0.8%** | **2.6%** | **3.8%** | **2.6%** | **2.5%** | **2.5%** |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លារអាមេរិក) | 4,110 | 4,070 | 4,011 | 4,029 | 4,041 | 4,050 | 4,058 |
| ការនាំចេញ (%នៃ ផ.ស.ស.) | 55.7% | 57.7% | 61.1% | 60.7% | 61.8% | 63.3% | 64.9% |
| ការនាំចូល (%នៃ ផ.ស.ស.) | -62.7% | -67.4% | -72.0% | -72.1% | -73.5% | -75.3% | -77.2% |
| សមតុល្យពាណិជ្ជកម្ម (%នៃ ផ.ស.ស.) | -7.1% | -9.7% | -10.9% | -11.4% | -11.8% | -12.0% | -12.3% |
| សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរ) (%នៃ ផ.ស.ស.) | 1.3% | 0.5% | -3.6% | -7.4% | -7.3% | -6.9% | -6.5% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | 19,998 | 22,511 | 27,530 | 29,169 | 30,867 | 33,159 | 36,221 |
| ចំនួនខែនៃការនាំចូល | 10.1 | 9.6 | 9.8 | 8.2 | 8.0 | 7.9 | 7.8 |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និង ធនាគារជាតិនៃកម្ពុជា (២០២៣- ២០២៥), និងការព្យាករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២៦-២០២៩)*

## ឧបសម្ព័ន្ធ ខ៖ ក្របខ័ណ្ឌចំណូល-ចំណាយរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៩

### ខ១. ជាប៊ីលានរៀល

| សូចនាករ | 2025ប. | 2026ច្បា. | 2026កែ. | 2027ព្យ. | 2028ព្យ. | 2029ព្យ. |
|---|---|---|---|---|---|---|
| **ចំណូលសរុប** | **33,523** | **32,747** | **33,533** | **35,950** | **38,432** | **41,443** |
| **ចំណូលចរន្តសរុប** | **30,934** | **31,610** | **32,396** | **34,825** | **37,259** | **40,115** |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 12,629 | 12,049 | 12,351 | 13,834 | 14,875 | 16,078 |
| អគ្គនាយកដ្ឋានពន្ធដារ | 14,335 | 15,280 | 15,731 | 16,478 | 17,530 | 18,746 |
| ចំណូលមិនមែនសារពើពន្ធ | 3,970 | 4,281 | 4,315 | 4,514 | 4,854 | 5,291 |
| **ចំណូលផ្សេងៗ** | **2,589** | **1,137** | **1,137** | **1,125** | **1,172** | **1,328** |
| **ចំណាយសរុប** | **36,168** | **40,913** | **40,913** | **40,175** | **42,301** | **44,899** |
| **ចំណាយចរន្តសរុប** | **25,927** | **27,317** | **27,317** | **29,268** | **30,785** | **32,375** |
| បន្ទុកបុគ្គលិក | 11,531 | 11,628 | 11,628 | 12,579 | 12,894 | 13,190 |
| បន្ទុកមិនមែនបុគ្គលិក | 14,396 | 15,689 | 15,689 | 16,689 | 17,891 | 19,184 |
| **ចំណាយមូលធនសរុប** | **10,241** | **13,596** | **13,596** | **10,907** | **11,517** | **12,524** |
| ហិរញ្ញប្បទានក្នុងប្រទេស | 4,597 | 6,546 | 6,546 | 4,431 | 4,995 | 5,739 |
| ហិរញ្ញប្បទានក្រៅប្រទេស | 5,644 | 7,050 | 7,050 | 6,477 | 6,522 | 6,785 |
| **អតិរេកចរន្ត** | **5,008** | **4,293** | **5,079** | **5,557** | **6,474** | **7,740** |
| **ឱនភាពថវិកា** | **-2,645** | **-8,167** | **-7,380** | **-4,225** | **-3,870** | **-3,456** |

### ខ២. កំណើនប្រចាំឆ្នាំ

| សូចនាករ | 2025ប. /2024 | 2026ច្បា. /2025ប. | 2026កែ. /2025ប. | 2027ព្យ. /2026កែ. | 2028ព្យ. | 2029ព្យ. |
|---|---|---|---|---|---|---|
| **ចំណូលសរុប** | **11.9%** | **-2.3%** | **0.0%** | **7.2%** | **6.9%** | **7.8%** |
| **ចំណូលចរន្តសរុប** | **10.5%** | **2.2%** | **4.7%** | **7.5%** | **7.0%** | **7.7%** |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 20.9% | -4.6% | -2.2% | 12.0% | 7.5% | 8.1% |
| អគ្គនាយកដ្ឋានពន្ធដារ | 2.2% | 6.6% | 9.7% | 4.7% | 6.4% | 6.9% |
| ចំណូលមិនមែនសារពើពន្ធ | 13.1% | 7.8% | 8.7% | 4.6% | 7.5% | 9.0% |
| **ចំណូលផ្សេងៗ** | **30.4%** | **-56.1%** | **-56.1%** | **-1.0%** | **4.2%** | **13.2%** |
| **ចំណាយសរុប** | **8.5%** | **13.1%** | **13.1%** | **-1.8%** | **5.3%** | **6.1%** |
| **ចំណាយចរន្តសរុប** | **10.5%** | **5.4%** | **5.4%** | **7.1%** | **5.2%** | **5.2%** |
| បន្ទុកបុគ្គលិក | 4.5% | 0.8% | 0.8% | 8.2% | 2.5% | 2.3% |
| បន្ទុកមិនមែនបុគ្គលិក | 15.9% | 9.0% | 9.0% | 6.4% | 7.2% | 7.2% |
| **ចំណាយមូលធនសរុប** | **3.6%** | **32.8%** | **32.8%** | **-19.8%** | **5.6%** | **8.7%** |
| ហិរញ្ញប្បទានក្នុងប្រទេស | 5.5% | 42.4% | 42.4% | -32.3% | 12.7% | 14.9% |
| ហិរញ្ញប្បទានក្រៅប្រទេស | 2.0% | 24.9% | 24.9% | -8.1% | 0.7% | 4.0% |

## ខ៣. ជាភាគរយនៃ ផ.ស.ស.

| សូចនាករ | 2025ប. | 2026ច្បា. | 2026កែ. | 2027ព្យ. | 2028ព្យ. | 2029ព្យ. |
|---|---|---|---|---|---|---|
| **ចំណូលសរុប** | **16.29%** | **14.89%** | **15.25%** | **15.24%** | **15.16%** | **15.16%** |
| **ចំណូលចរន្តសរុប** | **15.03%** | **14.37%** | **14.73%** | **14.76%** | **14.70%** | **14.68%** |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 6.14% | 5.48% | 5.62% | 5.86% | 5.87% | 5.88% |
| អគ្គនាយកដ្ឋានពន្ធដារ | 6.97% | 6.95% | 7.15% | 6.99% | 6.92% | 6.86% |
| ចំណូលមិនមែនសារពើពន្ធ | 1.93% | 1.95% | 1.96% | 1.91% | 1.91% | 1.94% |
| **ចំណូលផ្សេងៗ** | **1.26%** | **0.52%** | **0.52%** | **0.48%** | **0.46%** | **0.49%** |
| **ចំណាយសរុប** | **17.58%** | **18.60%** | **18.60%** | **17.03%** | **16.69%** | **16.43%** |
| **ចំណាយចរន្តសរុប** | **12.60%** | **12.42%** | **12.42%** | **12.41%** | **12.14%** | **11.85%** |
| បន្ទុកបុគ្គលិក | 5.60% | 5.29% | 5.29% | 5.33% | 5.09% | 4.83% |
| បន្ទុកមិនមែនបុគ្គលិក | 7.00% | 7.13% | 7.13% | 7.07% | 7.06% | 7.02% |
| **ចំណាយមូលធនសរុប** | **4.98%** | **6.18%** | **6.18%** | **4.62%** | **4.54%** | **4.58%** |
| ហិរញ្ញប្បទានក្នុងប្រទេស | 2.23% | 2.98% | 2.98% | 1.88% | 1.97% | 2.10% |
| ហិរញ្ញប្បទានក្រៅប្រទេស | 2.74% | 3.21% | 3.21% | 2.75% | 2.57% | 2.48% |
| **អតិរេកចរន្ត** | **2.43%** | **1.95%** | **2.31%** | **2.36%** | **2.55%** | **2.83%** |
| **ឱនភាពថវិកា** | **-1.29%** | **-3.71%** | **-3.36%** | **-1.79%** | **-1.53%** | **-1.26%** |

# ឧបសម្ព័ន្ធ គៈ ការវិភាជចំណាយថ្នាក់ជាតិតាមវិស័យ

## គ១. ជាប៊ីលានរៀល

| សូចនាករ | 2025ច្បា. | 2026ច្បា. | 2027ព្យ. | 2028ព្យ. | 2029ព្យ. |
|---|---|---|---|---|---|
| **ចំណាយសរុបថ្នាក់ជាតិ** | **35,398** | **38,453** | **37,484** | **39,390** | **41,744** |
| **វិស័យរដ្ឋបាលទូទៅ** | **3,452** | **3,408** | **3,741** | **4,083** | **4,289** |
| ចំណាយចរន្ត | 3,240 | 3,189 | 3,524 | 3,853 | 4,046 |
| ចំណាយមូលធន | 212 | 220 | 216 | 230 | 243 |
| **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់** | **5,641** | **5,741** | **6,399** | **6,650** | **6,897** |
| ចំណាយចរន្ត | 5,625 | 5,687 | 6,382 | 6,623 | 6,856 |
| ចំណាយមូលធន | 16 | 55 | 17 | 27 | 41 |
| **វិស័យសង្គមកិច្ច** | **10,615** | **10,989** | **11,363** | **12,305** | **12,920** |
| ចំណាយចរន្ត | 9,433 | 9,853 | 10,239 | 11,082 | 11,535 |
| ចំណាយមូលធន | 1,183 | 1,136 | 1,124 | 1,223 | 1,385 |
| **វិស័យសេដ្ឋកិច្ច** | **8,017** | **8,234** | **7,737** | **8,140** | **8,858** |
| ចំណាយចរន្ត | 1,838 | 1,858 | 1,878 | 1,923 | 1,968 |
| ចំណាយមូលធន | 6,179 | 6,376 | 5,859 | 6,216 | 6,890 |
| **ចំណាយផ្សេងៗ** | **7,673** | **10,080** | **8,244** | **8,212** | **8,780** |
| ចំណាយចរន្ត | 3,767 | 4,655 | 5,092 | 4,975 | 5,446 |
| ចំណាយមូលធន | 3,906 | 5,426 | 3,153 | 3,237 | 3,334 |

## គ២. កំណើនប្រចាំឆ្នាំ

| សូចនាករ | 2025ច្បា. | 2026ច្បា. | 2027ព្យ. | 2028ព្យ. | 2029ព្យ. |
|---|---|---|---|---|---|
| **ចំណាយសរុបថ្នាក់ជាតិ** | **0.0%** | **8.6%** | **-2.5%** | **5.1%** | **6.0%** |
| **វិស័យរដ្ឋបាលទូទៅ** | **0.8%** | **-1.3%** | **9.8%** | **9.2%** | **5.0%** |
| ចំណាយចរន្ត | 0.0% | -1.6% | 10.5% | 9.3% | 5.0% |
| ចំណាយមូលធន | 14.0% | 3.5% | -1.5% | 6.5% | 5.6% |
| **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់** | **-0.3%** | **1.8%** | **11.4%** | **3.9%** | **3.7%** |
| ចំណាយចរន្ត | 0.0% | 1.1% | 12.2% | 3.8% | 3.5% |
| ចំណាយមូលធន | -53.4% | 242.1% | -68.9% | 59.0% | 51.9% |
| **វិស័យសង្គមកិច្ច** | **6.0%** | **3.5%** | **3.4%** | **8.3%** | **5.0%** |
| ចំណាយចរន្ត | 0.0% | 4.5% | 3.9% | 8.2% | 4.1% |
| ចំណាយមូលធន | 102.3% | -4.0% | -1.0% | 8.8% | 13.2% |
| **វិស័យសេដ្ឋកិច្ច** | **0.6%** | **2.7%** | **-6.0%** | **5.2%** | **8.8%** |
| ចំណាយចរន្ត | 0.0% | 1.1% | 1.1% | 2.4% | 2.3% |
| ចំណាយមូលធន | 0.8% | 3.2% | -8.1% | 6.1% | 10.8% |
| **ចំណាយផ្សេងៗ** | **-7.8%** | **31.4%** | **-18.2%** | **-0.4%** | **6.9%** |
| ចំណាយចរន្ត | 0.0% | 23.6% | 9.4% | -2.3% | 9.5% |
| ចំណាយមូលធន | -14.3% | 38.9% | -41.9% | 2.7% | 3.0% |

## គ៣. ជាភាគរយនៃ ផ.ស.ស.

| សូចនាករ | 2025ច្ប. | 2026ច្ប. | 2027ព្យ. | 2028ព្យ. | 2029ព្យ. |
|---|---|---|---|---|---|
| **ចំណាយសរុបថ្នាក់ជាតិ** | **17.20%** | **17.48%** | **15.89%** | **15.54%** | **15.27%** |
| **វិស័យរដ្ឋបាលទូទៅ** | **1.68%** | **1.55%** | **1.59%** | **1.61%** | **1.57%** |
| ចំណាយចរន្ត | 1.57% | 1.45% | 1.49% | 1.52% | 1.48% |
| ចំណាយមូលធន | 0.10% | 0.10% | 0.09% | 0.09% | 0.09% |
| **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់** | **2.74%** | **2.61%** | **2.71%** | **2.62%** | **2.52%** |
| ចំណាយចរន្ត | 2.73% | 2.59% | 2.71% | 2.61% | 2.51% |
| ចំណាយមូលធន | 0.01% | 0.02% | 0.01% | 0.01% | 0.02% |
| **វិស័យសង្គមកិច្ច** | **5.16%** | **5.00%** | **4.82%** | **4.85%** | **4.73%** |
| ចំណាយចរន្ត | 4.58% | 4.48% | 4.34% | 4.37% | 4.22% |
| ចំណាយមូលធន | 0.57% | 0.52% | 0.48% | 0.48% | 0.51% |
| **វិស័យសេដ្ឋកិច្ច** | **3.90%** | **3.74%** | **3.28%** | **3.21%** | **3.24%** |
| ចំណាយចរន្ត | 0.89% | 0.84% | 0.80% | 0.76% | 0.72% |
| ចំណាយមូលធន | 3.00% | 2.90% | 2.48% | 2.45% | 2.52% |
| **ចំណាយផ្សេងៗ** | **3.73%** | **4.58%** | **3.50%** | **3.24%** | **3.21%** |
| ចំណាយចរន្ត | 1.83% | 2.12% | 2.16% | 1.96% | 1.99% |
| ចំណាយមូលធន | 1.90% | 2.47% | 1.34% | 1.28% | 1.22% |